ព័ត៌មានអំពីការបោះឆ្នោត
តាមសំបុត្រត្រូវបានភ្ជាប់
មកជាមួយ!

# រដ្ឋម៉ាសាជូសេត

# ព័ត៌មាន សម្រាប់ អ្នកបោះឆ្នោត

## សំណួរអំពី ការបោះឆ្នោតឆ្នាំ2022

## ការបោះឆ្នោតរបស់រដ្ឋ

ថ្ងៃអង្គារ ទី8 ខែវិច្ឆិកា ឆ្នាំ2022

**VoteInMA.com**

*បោះពុម្ពដោយ*

**William Francis Galvin** (វីល្លាម ប្រ្វាន់ស៊ីស ហ្គាល់វីន)

លេខាធិការខំមិនវែល

# *The Commonwealth of Massachusetts*

## *Secretary of the Commonwealth*

*State House, Boston, Massachusetts 02133*

*William Francis Galvin*
*Secretary of the Commonwealth*


អ្នកបោះឆ្នោតជាទីរាប់អាន!

ខ្ញុំបានអនុវត្តនីតិវិធីថ្មីដើម្បីផ្តល់ជម្រើសជាច្រើនទៀតជូនដល់អ្នកបោះ
ក្នុងឆ្នាំនេះ ដើម្បីជួយឱ្យអ្នកបោះឆ្នោតបានចូលរួម ខ្ញុំបានអនុវត្តនីតិវិធីថ្មីដើម្បីផ្តល់ជម្រើសជាច្រើនទៀតជូនដល់អ្នកបោះ ចំណែកអ្នកដែលជ្រើសរើសធ្វើការបោះឆ្នោតដោយ
ឆ្នោត។ អ្នកបោះឆ្នោតគ្រប់រូបមានជម្រើសក្នុងការបោះឆ្នោតតាមសំបុត្រ ចំណែកអ្នកដែលជ្រើសរើសធ្វើការបោះឆ្នោតដោយ ការបោះឆ្នោតមុនថ្ងៃបោះ
ផ្ទាល់ នឹងមានកាលបរិច្ឆេទបោះឆ្នោតមុនថ្ងៃបោះឆ្នោតជាច្រើនថ្ងៃបន្ថែមទៀតដើម្បីជ្រើសរើស។ ការបោះឆ្នោតមុនថ្ងៃបោះ ការិយាល័យបោះឆ្នោតទាំងអស់ នឹង
ឆ្នោត នឹងត្រូវធ្វើឡើងចាប់ពីថ្ងៃទី22 ខែតុលា ដល់ថ្ងៃទី4 ខែវិច្ឆិកា។ នៅថ្ងៃបោះឆ្នោត ការិយាល័យបោះឆ្នោតទាំងអស់ នឹង
បើកទ្វារចាប់ពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់។

ប្រសិនបើអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយទេ ឬត្រូវការចុះឈ្មោះសាជាថ្មី ដោយសារអ្នកបានផ្លាស់ទីលំនៅ
អ្នកអាចចុះឈ្មោះបោះឆ្នោតបានតាមរយៈ **www.VoteInMA.com**។ ច្បាប់របស់រដ្ឋតម្រូវឱ្យអ្នកត្រូវធ្វើការចុះឈ្មោះបោះឆ្នោត
ត្រឹមថ្ងៃទី29 ខែតុលា ឆ្នាំ2022 ដើម្បីឱ្យមានឈ្មោះរបស់អ្នកនៅលើបញ្ជីបោះឆ្នោត។ អ្នកក៏អាចធ្វើការត្រួតពិនិត្យស្ថានភាពនៃ
ការចុះឈ្មោះបោះឆ្នោតរបស់អ្នកបានផងដែរនៅលើគេហទំព័ររបស់យើងខ្ញុំ។

នៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតរបស់រដ្ឋ នឹងមានសំណួរអំពីការបោះឆ្នោតនៅទូទាំងរដ្ឋចំនួនយ៉ាងតិចបី។ កូនសៀវភៅ
ណែនាំអំពីព័ត៌មានផ្លូវការសម្រាប់អ្នកបោះឆ្នោតឆ្នាំ2022 មានរៀបរាប់អំពីសំណួរនីមួយៗ ដែលមានអត្ថបទសេចក្តីព្រាងច្បាប់
ឬវិសោធនកម្មច្បាប់ សេចក្តីថ្លែងការដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោតគាំទ្រ និងការបោះឆ្នោតជំទាស់ ខ្លឹមសារ
សង្ខេប និងអំណះអំណាងគាំទ្រ និងប្រឆាំងទៅនឹងសំណួរនីមួយៗ។ ព័ត៌មាននេះនឹងជួយអ្នកក្នុងការសម្រេចចិត្តនៅមុន
ពេលបោះឆ្នោត។ ប្រសិនបើអ្នកចង់ អ្នកថែមទាំងអាចយកកូនសៀវភៅណែនាំនេះតាមខ្លួនចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោត
បានថែមទៀតផង។

សៀវភៅណែនាំនេះមានព័ត៌មានសំខាន់ៗអំពីការបោះឆ្នោតដែលនឹងចូលមកដល់ក្នុងពេលខាងមុខ។ ជម្រើសដែលអ្នក
ជ្រើសរើសនៅក្នុងការបោះឆ្នោតនេះ នឹងបង្កើតបានជាបុព្វហេតុរបស់រដ្ឋាភិបាលសម្រាប់ប្រជាជាតិយើង រដ្ឋ និងសហគមន៍
ក្នុងមូលដ្ឋានរបស់យើង។ ថ្នាក់ដឹកនាំដែលអ្នកជ្រើសរើស នឹងធ្វើការសម្រេចចិត្តសំខាន់ៗដែលមានឥទ្ធិពលទៅលើអ្នកនិង
គ្រួសាររបស់អ្នក។ ខ្ញុំសូមជំរុញឱ្យអ្នកចូលរួមក្នុងដំណើរការនេះ ដោយសារការបោះឆ្នោតរបស់អ្នកពិតជាមានសារៈសំខាន់
ណាស់។

សូមធ្វើការបោះឆ្នោត និងអនុវត្តសិទ្ធិសំខាន់បំផុតនៃប្រព័ន្ធប្រជាធិបតេយ្យរបស់យើង។

ដោយសេចក្តីគោរពអំពីខ្ញុំ

William Francis Galvin (វីល្លាម ហ្វ្រាន់ស៊ីស ហ្គាល់វីន)
លេខាធិការខំមិនវែល

# តារាងមាតិកា

មុខតំណែងដែលត្រូវបោះឆ្នោតក្នុងឆ្នាំ2022 .... 5
ប្រតិទិនការបោះឆ្នោតឆ្នាំ2022 .... 6
កាលបរិច្ឆេទសំខាន់ៗដែលត្រូវចងចាំ .... 7
សំណួរ 1 - ប្រាក់ពន្ធបន្ថែមលើប្រាក់ចំណូលជាងមួយលានដុល្លារ .... 8
សំណួរ 2 - និយ័តកម្មលើធានារ៉ាប់រងធ្មេញ .... 10
សំណួរ 3 - ការពង្រីកការផ្តល់ជូនអាជ្ញាប័ណ្ណសម្រាប់ការលក់គ្រឿងស្រវឹង .... 15
សំណួរបន្ថែមអំពីការបោះឆ្នោត .... 18
ការបោះឆ្នោតក្នុងឆ្នាំ2022 .... 19
ការចុះឈ្មោះអ្នកបោះឆ្នោត .... 19
ការបោះឆ្នោតតាមសំបុត្រ .... 20
ការបោះឆ្នោតជាមុនដោយផ្ទាល់ .... 21
ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត .... 22
សំណួរដែលបានសាកសួរជាញឹកញាប់ .... 23
សន្តិសុខនៃការបោះឆ្នោត .... 24
ធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត! .... 25
អ្នកបោះឆ្នោតជាមន្ត្រីយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស .... 25
កម្រងសិទ្ធិអ្នកបោះឆ្នោតនៃរដ្ឋម៉ាសាជូសេត .... 26
តើអ្នកធ្លាប់ជាជនរងគ្រោះនៃការឆបោកក្នុងការវិនិយោគដែរឬទេ? .... 27
សេវាកម្មនានារបស់លេខាធិការខំមិនវែល .... 28
បញ្ជីត្រួតពិនិត្យសម្រាប់អ្នកបោះឆ្នោត .... 30

¡Atención! Si desea recibir este folleto en Español, llame al 617-727-2828 o al 1-800-462-VOTE (8683).

請注意！如果您希望索取本手冊的中文譯本，請致電 617-727-2828 或 1-800-462-8683。

Chú ý! Nếu bạn muốn nhận tập sách này bằng tiếng Việt, vui lòng gọi 617-727-2828 hoặc 1-800-462-VOTE (8683)

សូមយកចិត្តទុកដាក់! ប្រសិនបើអ្នកចង់បានឯកសារនេះជាភាសាខ្មែរ សូមអ្នកទូរស័ព្ទទៅលេខ 617-727-2828 ឬ 1-800-462-VOTE (8683) ។

អភិបាល និងអភិបាលរង

អគ្គរដ្ឋអាជ្ញា

រដ្ឋលេខាធិការ

ហេរញ្ញិក

សវនករ

តំណាងនៅព្រឹទ្ធសភា

ក្រុមប្រឹក្សា

សមាជិកព្រឹទ្ធនៅក្នុងសភាធម្មនុញ្ញ

តំណាងនៅក្នុងសភាធម្មនុញ្ញ

មេធាវីមណ្ឌល

អាជ្ញាសាលា

ស្នងការខោនធី
(ខោនធី Barnstable, Bristol, Dukes, Norfolk និង Plymouth តែប៉ុណ្ណោះ) ឬ
គណៈរដ្ឋាភិបាល Franklin (ខោនធី Franklin តែប៉ុណ្ណោះ)

ការចុះបញ្ជីប័ណ្ណកម្មសិទ្ធិ
(មណ្ឌល Bristol ភាគខាងត្បូងប៉ុណ្ណោះ)

## ខែតុលា

| អាទិត្យ | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| | | | | | | 1 |
| 2 | 3 | 4 | 5 | 6 | 7 | 8 |
| 9 | 10 | 11 | 12 | 13 | 14 មានកាលវិភាគសម្រាប់ការបោះឆ្នោតមុនកាលកំណត់នៅក្នុងតំបន់ | 15 |
| 16 | 17 | 18 | 19 | 20 | 21 | 22 ការបោះឆ្នោតមុនពេល រយៈពេលនៃការបោះឆ្នោតមុនកាលកំណត់ចាប់ផ្តើម |
| 23 ការបោះឆ្នោតមុនពេល | 24 | 25 | 26 | 27 | 28 | 29 កាលបរិច្ឆេទផុតកំណត់សម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោត |

## ខែវិច្ឆិកា

| អាទិត្យ | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| 30 ការបោះឆ្នោតមុនពេល | 31 | 1 កាលបរិច្ឆេទផុតកំណត់សម្រាប់ដាក់ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ | 2 | 3 | 4 រយៈពេលនៃការបោះឆ្នោតមុនកាលកំណត់ចប់ | 5 |
| 6 | 7 | 8 ថ្ងៃ បោះឆ្នោត | 9 | 10 | 11 ទិវាអតីតយុទ្ធជន | 12 ថ្ងៃចុងក្រោយ ដែលសន្លឹកឆ្នោតក្នុងស្រុក មកដល់ |
| 13 | 14 | 15 | 16 | 17 | 18 ថ្ងៃចុងក្រោយដែលសន្លឹកឆ្នោតមកពីក្រៅស្រុកត្រូវមកដល់ | 19 |

# កាលបរិច្ឆេទសំខាន់ៗដែលត្រូវចងចាំ

**ថ្ងៃទី14 ខែតុលា៖ មានកាលវិភាគសម្រាប់ការបោះឆ្នោតមុនកាលកំណត់នៅក្នុងតំបន់**

ការបោះឆ្នោតមុនកាលបរិច្ឆេទកំណត់ និងទីតាំងបោះឆ្នោតសម្រាប់ទីក្រុងនិងទីប្រជុំជននីមួយៗ នឹងត្រូវបង្ហោះនៅលើគេហទំព័រ **www.VoteInMA.com** មិនឱ្យលើសពីថ្ងៃទី14 ខែតុលា ឡើយ។ ពិនិត្យមើលព័ត៌មានរបស់សហគមន៍របស់អ្នក ដើម្បីស្វែងយល់ថា អ្នកអាចធ្វើការបោះឆ្នោតមុនថ្ងៃបោះឆ្នោតបាននៅកន្លែងណា និងនៅពេលណា។

**ថ្ងៃទី22 ខែតុលា - ថ្ងៃទី4 ខែវិច្ឆិកា រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត**

ការបោះឆ្នោតមុនថ្ងៃបោះឆ្នោតទី8 ខែវិច្ឆិកា ឆ្នាំ2022 ចាប់ផ្តើមពីថ្ងៃទី22 ខែតុលា និងបញ្ចប់ទៅវិញនៅថ្ងៃទី4 ខែវិច្ឆិកា។

រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត រួមមានពេលពីរសប្តាហ៍ ហើយសហគមន៍នីមួយៗ នឹងផ្តល់ម៉ោងមួយចំនួនសម្រាប់ការបោះឆ្នោតនៅថ្ងៃចុងសប្តាហ៍។

តារាងពេលវេលានៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ខុសគ្នាទៅតាមទីក្រុងនិងទីប្រជុំជន។ សូមកុំភ្លេចពិនិត្យមើលតារាងពេលវេលាសហគម៍របស់អ្នក នៅពេលអ្នកមានគម្រោងធ្វើការបោះឆ្នោត។

**ថ្ងៃទី29 ខែតុលា៖ កាលបរិច្ឆេទផុតកំណត់សម្រាប់ការចុះឈ្មោះបោះឆ្នោត**

ថ្ងៃចុងក្រោយសម្រាប់ចុះឈ្មោះបោះឆ្នោត ធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន ប្តូរឈ្មោះ ឬប្តូរគណបក្សរបស់អ្នកសម្រាប់ការបោះឆ្នោតនៅថ្ងៃទី8 ខែវិច្ឆិកា ឆ្នាំ2022 គឺមានរយៈពេល 10ថ្ងៃ នៅមុនថ្ងៃបោះឆ្នោត។

ម៉ោងសម្រាប់ការចុះឈ្មោះបោះឆ្នោតដោយផ្ទាល់ នឹងត្រូវធ្វើឡើងនៅតាមទីក្រុង និងទីប្រជុំជន រហូតដល់ម៉ោង 5 ល្ងាច នៅថ្ងៃទី29 ខែតុលា។

ការចុះឈ្មោះបោះឆ្នោតតាមអនឡាញ នឹងត្រូវបើករហូតដល់ម៉ោង 11:59 យប់ នៅថ្ងៃទី29 ខែតុលា។

ទម្រង់នៃការចុះឈ្មោះបោះឆ្នោតត្រូវវាយត្រាកំណត់ត្រឹមថ្ងៃទី29 ខែតុលា។

**ថ្ងៃទី1 ខែវិច្ឆិកា៖ កាលបរិច្ឆេទផុតកំណត់សម្រាប់ដាក់ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ**

ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្ររបស់អ្នក ត្រូវមកដល់ការិយាល័យបោះឆ្នោតត្រឹមម៉ោង 5 ល្ងាច នៅថ្ងៃទី1 ខែវិច្ឆិកា ដើម្បីឱ្យតបតាមគេផ្ញើសន្លឹកឆ្នោតទៅអ្នក។ ត្រាប្រៃសណីយ៍ មិនគ្រប់គ្រាន់ទៅតាមកាលបរិច្ឆេទកំណត់ទេ។ ប្រសិនបើអ្នកផ្ញើពាក្យស្នើសុំរបស់អ្នក ត្រូវប្រាកដថា អ្នកបានដាក់ពាក្យស្នើសុំយ៉ាងហោចណាស់មួយសប្តាហ៍មុនកាលបរិច្ឆេទផុតកំណត់។

សូមផ្តល់អនុសាសន៍ឱ្យអ្នកដាក់ពាក្យសុំសន្លឹកឆ្នោតឱ្យបានមុនកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី1 ខែវិច្ឆិកា ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកត្រូវផ្ញើចេញទៅក្រៅទីប្រជុំជន ឬប្រសិនបើអ្នកមានគម្រោងផ្ញើសន្លឹកឆ្នោតត្រឡប់មកវិញតាមប្រៃសណីយ៍។

**ថ្ងៃទី8 ខែវិច្ឆិកា៖ ថ្ងៃបោះឆ្នោត**

ថ្ងៃបោះឆ្នោត គឺធ្វើឡើងនៅថ្ងៃទី8 ខែវិច្ឆិកា។ ការបោះឆ្នោតនឹងចាប់ផ្តើមនៅម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់ នៅទូទាំងរដ្ឋម៉ាសាជូសេត។

ប្រសិនបើអ្នកនឹងបោះឆ្នោតតាមសំបុត្រ សន្លឹកឆ្នោតរបស់អ្នកត្រូវវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី8 ខែវិច្ឆិកា ដើម្បីអាចរាប់បញ្ចូលបាន។ ដោយសារសន្លឹកឆ្នោតអាចត្រូវការពេលរហូតដល់ 7 ថ្ងៃ ដើម្បីឱ្យសេវាប្រៃសណីយ៍អាមេរិកអាចប្រគល់ជូនបាន យើងសូមណែនាំឱ្យអ្នកផ្ញើសន្លឹកឆ្នោតរបស់អ្នកយ៉ាងតិចមួយសប្តាហ៍មុនថ្ងៃបោះឆ្នោត។

ការប្រគល់សន្លឹកឆ្នោតដោយផ្ទាល់ដៃជូនដល់ការិយាល័យបោះឆ្នោត ឬប្រអប់សំបុត្រ អាចតែធ្វើឡើងត្រឹមពេលបិទការបោះឆ្នោតនៅម៉ោង 8 យប់ នៅថ្ងៃបោះឆ្នោត។

**ថ្ងៃទី12 ខែវិច្ឆិកា៖ ថ្ងៃចុងក្រោយដែលសន្លឹកឆ្នោតក្នុងស្រុកមកដល់**

ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកមកពីក្នុងសហរដ្ឋអាមេរិក សន្លឹកឆ្នោតនោះត្រូវមកដល់ការិយាល័យបោះឆ្នោតក្នុងស្រុក ត្រឹមម៉ោង 5 ល្ងាច នៅថ្ងៃទី12 ខែវិច្ឆិកា ដើម្បីរាប់បញ្ចូល។

សន្លឹកឆ្នោតដែលមកដល់ បន្ទាប់ពីការបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត នឹងអាចរាប់បញ្ចូលបានតែក្នុងករណីដែលសន្លឹកឆ្នោតទាំងនោះ មានវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី8 ខែវិច្ឆិកា ប៉ុណ្ណោះ។

**ថ្ងៃទី18 ខែវិច្ឆិកា៖ ថ្ងៃចុងក្រោយដែលសន្លឹកឆ្នោតមកពីក្រៅស្រុកត្រូវមកដល់**

ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកមកពីក្រៅសហរដ្ឋអាមេរិក សន្លឹកឆ្នោតនោះត្រូវមកដល់ការិយាល័យបោះឆ្នោតក្នុងស្រុក ត្រឹមម៉ោង 5 ល្ងាច នៅថ្ងៃទី18 ខែវិច្ឆិកា ដើម្បីរាប់បញ្ចូល។

សន្លឹកឆ្នោតដែលផ្ញើមកពីក្រៅប្រទេសដែលមកដល់ក្រោយពីការបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត នឹងអាចរាប់បញ្ចូលបានតែក្នុងករណីដែលសន្លឹកឆ្នោតទាំងនោះ មានវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី8 ខែវិច្ឆិកា ប៉ុណ្ណោះ។ សន្លឹកឆ្នោតដែលមកដល់ក្រោយថ្ងៃទី12 ខែវិច្ឆិកា ក៏ត្រូវមានវាយត្រាប្រៃសណីយ៍ច្បាស់ៗពីក្រៅប្រទេសផងដែរ។

# 1

## សំណួរទី1៖ សំណើវិសោធនកម្មរដ្ឋធម្មនុញ្ញ

# ប្រាក់ពន្ធបន្ថែមលើប្រាក់ចំណូលជាងមួយលានដុល្លារ

*តើអ្នកយល់ស្របនឹងការអនុម័តលើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម ដែលត្រូវបានអនុម័តដោយសភាធម្មនុញ្ញក្នុងសម័យប្រជុំរួមគ្នារវាងព្រឹទ្ធសភានិងរដ្ឋសភា នៅថ្ងៃទី12 ខែមិថុនា ឆ្នាំ2019 (សំឡេងគាំទ្រ 147 - សំឡេងជំទាស់ 48) និងក្នុងសម័យប្រជុំម្តងទៀតនាថ្ងៃទី9 ខែមិថុនា ឆ្នាំ2021 (សំឡេងគាំទ្រ 159 - សំឡេងជំទាស់ 41)?*

**សង្ខេប ▶**
តាមតម្រូវការផ្លូវច្បាប់ ខ្លឹមសារសង្ខេប ត្រូវបានសរសេរ ដោយ អគ្គរដ្ឋ អាជ្ញា។

សំណើវិសោធនកម្មរដ្ឋធម្មនុញ្ញ នឹងត្រូវចែងអំពីពន្ធលើប្រាក់ចំណូលបន្ថែមចំនួន 4% លើចំណែកប្រាក់ចំណូលគិតពន្ធប្រចាំឆ្នាំក្នុងទំហំទឹកប្រាក់លើសពី 1$ លានដុល្លារអាមេរិក។ កម្រិតប្រាក់ចំណូលនេះ នឹងត្រូវកែប្រែជារៀងរាល់ឆ្នាំ តាមវិធីដូចគ្នាដែលបានប្រើសម្រាប់កម្រិតពន្ធប្រាក់ចំណូលរបស់សហព័ន្ធ ដើម្បីឆ្លុះបញ្ចាំងពីកំណើននៃថ្លៃចំណាយសម្រាប់ការរស់នៅ។ ប្រាក់ចំណូលទទួលបានពីពន្ធនេះ នឹងត្រូវប្រើសម្រាប់ការអប់រំសាធារណៈ មហាវិទ្យាល័យ និងសាកលវិទ្យាល័យក្នុងមូលដ្ឋាន ស្ថិតនៅក្រោមច្បាប់រដ្ឋ និងសម្រាប់ការជួសជុលថែទាំផ្លូវ ស្ពាន និងការដឹកជញ្ជូនសារធារណៈ។ សំណើវិសោធនកម្មនេះ នឹងអនុវត្តចំពោះឆ្នាំពន្ធដារ ដែលចាប់ផ្តើមនៅថ្ងៃ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2023។

---

**ការចូលរួមចំណែកពីការបោះឆ្នោតរបស់អ្នក ▶**
តាមរយៈការតម្រូវដោយច្បាប់ សេចក្តីថ្លែងការដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងលេខាធិការរដ្ឋ។

ខំមិនវែល។

*ការបោះឆ្នោតគាំទ្រ* នឹងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋ ដើម្បីគិតពន្ធបន្ថែមចំនួន 4% លើចំណែកប្រាក់ចំណូលជាងមួយលានដុល្លារ ដែលត្រូវប្រើប្រាស់លើការអប់រំ និងការដឹកជញ្ជូន ស្ថិតនៅក្រោមច្បាប់រដ្ឋ។

*ការបោះឆ្នោតជំទាស់* នឹងគ្មានការកែប្រែរដ្ឋធម្មនុញ្ញដែលពាក់ព័ន្ធនឹងប្រាក់ចំណូលឡើយ។

---

**របាយការណ៍ផលប៉ះពាល់សារពើពន្ធ ▶**
តាមការតម្រូវពីច្បាប់ របាយការណ៍ផលប៉ះពាល់សារពើពន្ធ ត្រូវសរសេរដោយការិយាល័យប្រតិបត្តិរដ្ឋបាល និងហិរញ្ញវត្ថុ។

សំណើបង្កើនអត្រាពន្ធបន្ទាប់បន្សំទៅលើអ្នកបង់ពន្ធជាបុគ្គលជាក់លាក់ ត្រឹម 80%។ ការផ្លាស់ប្តូរអាចបង្កើនប្រាក់ចំណូលរដ្ឋត្រឹម 1.2$ ប៊ីលានដុល្លារ ក្នុងពេលប៉ុន្មានឆ្នាំខាងមុខ ដែលមានប្រមាណជា 2.4% នៃកញ្ចប់ថវិការដ្ឋប្រចាំថ្ងៃដែលមានក្នុងពេលបច្ចុប្បន្ននេះ។ ក៏ប៉ុន្តែ ប្រាក់ចំណូលប្រចាំថ្ងៃដែលបង្កើតឡើងតាមរយៈពន្ធបន្ថែម នឹងខុសគ្នាខ្លាំង ហើយមិនអាចប៉ាន់ស្មានដឹងបានពីមួយឆ្នាំទៅមួយឆ្នាំ។ ជាងនេះ កត្តាដែលមិនអាចកំណត់បានភាគច្រើន អាចធ្វើឱ្យមានការផ្លាស់ប្តូរជាច្រើនលើផលប៉ះពាល់នៃលើសំណើដែលមានចំពោះរដ្ឋ និងហិរញ្ញវត្ថុក្រុង។ ឧទាហរណ៍ អ្នកបង់ពន្ធអាចសម្រេចផ្លាស់ប្តូរផ្ទះ ឬអាជីវកម្មរបស់ពួកគេទៅកាន់រដ្ឋមួយផ្សេងទៀត ឬកែតម្រូវស្ថានភាពនៃការប្រកាសពន្ធ ឬពេលវេលានៃការកំណត់ប្រាក់ចំណូលរបស់ពួកគេ ដើម្បីកាត់បន្ថយបន្ទុកពន្ធដាររបស់ពួកគេ។

**អំណះអំណាង▶**

ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវសរសេរដោយ ដោយអ្នកគាំទ្រ និង អ្នកបដិសេធលើ សំណួរនីមួយៗ និងឆ្លុះបញ្ចាំងពី ទស្សនៈរបស់ពួកគេ។ ខុំមិនវែលនៃ រដ្ឋម៉ាសាជូសេត ពុំបានគាំទ្រចំពោះ ទឡ្ហីករណ៍ទាំងនេះទេ ហើយក៏ មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃ សេចក្តីថ្លែងការដែលបានធ្វើឡើងនៅក្នុង ទឡ្ហីករណ៍ទាំងនេះដែរ។ ឈ្មោះរបស់ បុគ្គល និង ស្ថាប័នដែល បានសរសេរសេចក្តីថ្លែងការនីមួយៗ និងមតិយោបល់ ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃផ្សេងទៀត អំពីសេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យ លេខាធិការខុំមិនវែល។

*បោះឆ្នោតគាំទ្រ៖* តាមរយៈការបោះឆ្នោតគាំទ្រលើសំណួរទី1 អ្នកនឹងត្រូវប្រាកដថា អ្នកដែលមានជាងគេបំផុតក្នុងរដ្ឋម៉ាសាជូសេត (អ្នកដែលរកបានប្រាក់ច្រើនជាង 1 លានដុល្លារក្នុងមួយឆ្នាំ) ត្រូវបង់ពន្ធឱ្យបានសមស្របនិងត្រឹមត្រូវ។ វិធានពន្ធដារក្នុងពេលបច្ចុប្បន្ន អនុញ្ញាតឱ្យសេដ្ឋីប្រាក់លាន បង់ប្រាក់ពន្ធតិចតួចជាងយើងរាល់គ្នា។ សំណួរទី1 "ពន្ធលើសេដ្ឋីប្រាក់លាន" នឹងធ្វើឱ្យអ្នកដែលមានទ្រព្យសម្បត្តិច្រើន បង់ពន្ធបន្ថែម 4 ភាគរយលើចំណែកប្រាក់ចំណូលប្រចាំឆ្នាំរបស់ពួកគេដែលលើសពី 1$ ដុល្លារ។

ប្រាក់បន្ថែមត្រូវបានធានាដោយរដ្ឋធម្មនុញ្ញថានឹងត្រូវប្រើលើការដឹកជញ្ជូន និងការអប់រំសាធារណៈ។ សំណួរទី1 មានន័យថាកូនចៅរបស់អ្នកអាចចូលរៀននៅសាលាល្អបាន។ យើងអាចជួសជុលផ្លូវ ពង្រីកការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើឱ្យថ្លៃចូលរៀននៅមហាវិទ្យាល័យកាន់មានតម្លៃសមរម្យ។ ផ្លូវល្អ និងសាលារៀនល្អ ជួយឱ្យអាជីវកម្មខ្នាតតូចរបស់យើងរីកចម្រើន បង្កើតការងារថ្មី និងកសាងសង្គមជាតិដែលរឹងមាំ។ សំណួរទី1 មានថាជាការបង្កើតឱកាសសម្រាប់មនុស្សគ្រប់គ្នា។

បោះឆ្នោតគាំទ្រចំពោះសំណួរទី1។ មានតែអ្នកមានខ្លាំងប៉ុណ្ណោះ ដែលនឹងត្រូវបង់ពន្ធ - មិនមែនយើងគ្រប់គ្នាឡើយ។

**Cynthia Roy**
**Fair Share Massachusetts**
**PO Box 15**
**Readville, MA 02137**
**(508) 319-9642**
**FairShareMA.com**

*បោះឆ្នោតជំទាស់៖* អាជីវកម្មតូចៗ គ្រួសារកសិករ ម្ចាស់ផ្ទះ និង និវត្តជន ជំរុញឱ្យជំទាស់នឹងសំណួរទី 1

- សំណួរ 1 បង្កើនអត្រាពន្ធប្រាក់ចំណូលរដ្ឋជិតទ្វេដងលើម្ចាស់អាជីកម្មតូចៗ ក្រុមហ៊ុនធំៗ និងនិវត្តជនរាប់សិបម៉ឺននាក់។
- សំណួរ 1 ចាត់ទុកប្រាក់ចំណូលមួយលើក (ការលក់ផ្ទះ ការវិនិយោគ អាជីវកម្ម ប្រាក់សោធនិវត្តន៍ និងមរតក) ជាប្រាក់ចំណូល។ ចំណុចនេះនឹងបង្ខំឱ្យពលរដ្ឋជាច្រើនធ្លាក់ចូលទៅក្នុងកម្រិតពន្ធថ្មីខ្ពស់ខ្លាំងក្នុងពេលតែមួយរំពេច ដោយបង្ហិន ប្រាក់សន្សំរបស់ម្ចាស់អាជីវកម្មខ្នាតតូច និងម្ចាស់ផ្ទះរាប់សិបឆ្នាំដែលការចូលនិវត្តន៍របស់ពួកគេពឹងផ្អែកលើការវិនិយោគ។
- អត្រាអតិផរណា ការពិបាកក្នុងការខ្សែសង្វាក់ផ្គត់ផ្គង់ និងបញ្ហាជំងឺកូវីដ-19 ដែលកំពុងបន្ត ធ្វើឱ្យកាលៈទេសៈបច្ចុប្បន្ននេះក្លាយជាពេលវេលាដ៏អាក្រក់បំផុតសម្រាប់ការបង្កើនពន្ធដ៏ច្រើនបែបនេះ ជាពិសេសនៅពេលដែលរដ្ឋម៉ាសាជូសេតមានកញ្ចប់ថវិកាលើសដ៏ច្រើនសន្ធឹកសន្ធាប់រួចទៅហើយ!
- គ្មានការធានាដាច់ខាតណាមួយថាប្រាក់ចំណូលដែលទទួលបានសំបុកពន្ធដ៏ធំនេះទេ នឹងប្រាកដជាបង្កើនការចំណាយលើការអប់រំនិងការដឹកជញ្ជូននោះទេ។ អ្នកនយោបាយចាយវាយតាមតែពួកគេត្រូវការ គ្មានការទទួលខុសត្រូវនោះទេ។

អង្គការដែលតំណាងឱ្យអាជីវកម្មខ្នាតតូច និងគ្រួសារកសិករជាង 20,000 ជំរុញឱ្យ៖ **បោះឆ្នោតជំទាស់ចំពោះសំណួរទី1**។

**Paul D'Amore,** អ្នកតំណាងអាជីវកម្មខ្នាតតូច
**Coalition To Stop The Tax Hike Amendment**
**198 Tremont Street, Office 135**
**Boston, MA 02116**
**www.NoQuestion1.com**

អត្ថបទវិសោធនកម្មពេញលេញ

មាត្រា 44 នៃរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាជូសេត ត្រូវធ្វើវិសោធនកម្មដោយបន្ថែមកថាខណ្ឌខាងក្រោម នៅខាងចុងកថាខណ្ឌនេះ៖

ដើម្បីផ្តល់ធនធាននានាសម្រាប់ការអប់រំសាធារណៈដែលមានគុណភាព និងថ្លៃមហាវិទ្យាល័យនិងសាកលវិទ្យាល័យរដ្ឋដែលមានតម្លៃសមរម្យ និងសម្រាប់ការជួសជុល និងការថែទាំផ្លូវ ស្ពាន និងការដឹកជញ្ជូនសារធារណៈ ប្រាក់ចំណូលទាំងអស់ដែលទទួលបានស្របតាមកថាខណ្ឌនេះ នឹងត្រូវចំណាយឱ្យបានសមស្របតែក្នុងគោលបំណងទាំងនេះប៉ុណ្ណោះ។ បន្ថែមពីលើពន្ធលើប្រាក់ចំណូលដែលបានអនុម័តក្នុងមាត្រានេះ ត្រូវមានពន្ធបន្ថែមចំនួន 4 ភាគរយទៀត លើចំណែកពន្ធប្រាក់ចំណូលប្រាក់ប្រចាំឆ្នាំដែលលើពី 1,000,000$ (មួយលានដុល្លារ) ដែលបានរាយការណ៍ក្នុងការប្រកាសពន្ធណាមួយដែលពាក់ព័ន្ធនឹងប្រាក់ចំណូលទាំងនោះ។ ដើម្បីធានាថា ពន្ធបន្ថែមនេះ បន្តអនុវត្តតែទៅលើអ្នកបង់ពន្ធដែលមានប្រាក់ចំណូលខ្ពស់បំផុតរបស់ខុំមិនវែលកម្រិតប្រាក់ចំណូល 1,000,000$ (មួយលានដុល្លារ) នេះត្រូវធ្វើការកែសម្រួលជារៀងរាល់ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីការបង្កើនថ្លៃចំណាយនៃការរស់នៅ តាមវិធីសាស្ត្រតែមួយដែលបានប្រើសម្រាប់កម្រិតពន្ធប្រាក់ចំណូលរបស់សហព័ន្ធ។ កថាខណ្ឌនេះ ត្រូវអនុវត្តចំពោះឆ្នាំពន្ធដារទាំងអស់ ដោយចាប់ផ្តើមនៅថ្ងៃ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2023។

# 2

### សំណួរទី2៖ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# បទបញ្ញត្តិអំពីធានារ៉ាប់រងធ្មេញ

*តើអ្នកយល់ស្របនឹងច្បាប់ដែលបានសង្ខេបខាងក្រោមទេ ដែលគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយសមាជិកសភា ឬសភាតំណាងរាស្ត្រនៅថ្ងៃ មុនថ្ងៃទី3 ខែឧសភា ឆ្នាំ2022 ឡើយ?*

**សង្ខេប▶** តាមតម្រូវការផ្លូវច្បាប់ ខ្លឹមសារសង្ខេប ត្រូវបានសរសេរ ដោយ អគ្គរដ្ឋ អាជ្ញា។

សំណើច្បាប់នេះ នឹងណែនាំដល់អង្គភាពធានារ៉ាប់រងនៃស្ទងការរដ្ឋម៉ាសាជូសេត ឱ្យអនុម័ត ឬបដិសេធលើអត្រានៃគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រ ហើយនឹងតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងធ្មេញបំពេញលក្ខខណ្ឌនៃអត្រាខាតបង់ខាងវេជ្ជសាស្ត្រសរុបប្រចាំឆ្នាំសម្រាប់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដែលខ្លួនបានធានារ៉ាប់រងចំនួន 83 ភាគរយ។ អត្រាខាតបង់ផ្នែកទន្តសាស្ត្រ នឹងធ្វើការវាស់ស្ទង់ចំនួនប្រាក់បុព្វលាភរ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងធ្មេញចំណាយលើការចំណាយនិងការកែលម្អគុណភាពធ្មេញរបស់សមាជិកខ្លួន ដែលផ្ទុយទៅនឹងខ្ទង់ចំណាយរដ្ឋបាល។ ប្រសិនបើផលធៀបនៃការខាតបង់ផ្នែកទន្តសាស្ត្រសរុបប្រចាំឆ្នាំរបស់ក្រុមហ៊ុន តិចជាង 83 ភាគរយ នោះក្រុមហ៊ុននឹងត្រូវតម្រូវឱ្យសងប្រាក់បុព្វលាភរ៉ាប់រងដែលលើសនោះទៅកាន់បុគ្គល ឬក្រុមដែលខ្លួនរ៉ាប់រង។ សំណើច្បាប់នេះ នឹងអនុញ្ញាតឱ្យស្ទងការធ្វើការលើកលែង ឬកែតម្រូវប្រាក់សង តែក្នុងករណីដែលគេបានសម្រេចថា ការចេញប្រាក់សំណងនោះនឹងនាំឱ្យមានបញ្ហាខ្វះខាតខាងហិរញ្ញវត្ថុចំពោះក្រុមហ៊ុនធានារ៉ាប់រងប៉ុណ្ណោះ។

សំណើច្បាប់នេះនឹងអនុវត្តចំពោះគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដោយមិនគិតថាតើគម្រោងនោះត្រូវបានចេញដោយផ្ទាល់ដោយក្រុមហ៊ុនណាមួយ តាមរយៈភ្នាក់ងារធានារ៉ាប់រង ឬតាមរយៈអន្តរការីណាម្នាក់។ សំណើច្បាប់នេះ នឹងមិនអនុវត្តចំពោះគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដែលបានចេញរួច ផ្តល់ជូនរួច ឬបន្តថ្មីចំពោះក្រុមធានារ៉ាប់រងខ្លួនឯង ឬកន្លែងដែលក្រុមហ៊ុនកំពុងធ្វើជាអ្នកគ្រប់គ្រងជាភាគីទីបីឡើយ។

សំណើច្បាប់នេះនឹងតម្រូវឱ្យក្រុមហ៊ុនដែលផ្តល់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រធ្វើការប្រគល់ជូនព័ត៌មានអំពីអត្រាខាតបង់ទន្តសាស្ត្របច្ចុប្បន្ន និងដែលមានការព្យាករណ៍ ការចំណាយរដ្ឋបាល និងព័ត៌មានហិរញ្ញវត្ថុដទៃផ្សេងទៀតដល់ស្ទងការ។ ក្រុមហ៊ុននីមួយៗនឹងត្រូវតម្រូវឱ្យប្រគល់របាយការណ៍ហិរញ្ញវត្ថុលម្អិតមួយច្បាប់ជូនដល់អង្គភាពធានារ៉ាប់រង ដោយលម្អិតពីចំណុចមួយៗទៅតាមទំហំក្រុមទីផ្សារ និងខ្សែអាជីវកម្ម។ ក្រុមហ៊ុនមួយដល់ផ្តល់ទាំងសេវារដ្ឋបាលដល់ក្រុមស្វ័យធានារ៉ាប់រងមួយក្រុម ឬច្រើនក្រុម ក៏នឹងត្រូវតម្រូវឱ្យដាក់នូវឯកសារឧបសម្ព័ន្ធភ្ជាប់ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយមានព័ត៌មានអំពីអាជីវកម្មស្វ័យធានារ៉ាប់រង។ សំណើច្បាប់នឹងដាក់ពិន័យការយឺតយ៉ាវលើក្រុមហ៊ុនណាមួយដែលពុំបានដាក់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួននៅថ្ងៃ ឬមុនថ្ងៃទី1 មេសា។

អង្គភាពនឹងត្រូវតម្រូវឱ្យប្រកាសទិន្នន័យជាសាធារណៈ ធ្វើការចេញខ្លឹមសារសង្ខេបប្រចាំឆ្នាំជូនដល់គណៈកម្មការច្បាប់ជាក់លាក់ និងដើម្បីធ្វើការផ្លាស់ប្តូរទិន្នន័យជាមួយគណៈកម្មការធិការគោលនយោបាយសុខាភិបាល។ ស្ទងការនឹងត្រូវតម្រូវឱ្យជ្រើសយកស្តង់ដានានាដែលតម្រូវឱ្យមានការចុះបញ្ជីបុគ្គល ឬអង្គភាពដែលមិនទទួលបានអាជ្ញាប័ណ្ណ ឬចុះបញ្ជីដោយស្ទងការ និងជ្រើសរើសលក្ខខណ្ឌវិនិច្ឆ័យសម្រាប់វិធីសាស្ត្ររាយការណ៍និងការបែងចែកដែលមានលក្ខណៈឯកសណ្ឋានភាពតាមស្តង់ដាក្នុងចំណោមក្រុមហ៊ុននានា។

សំណើច្បាប់នេះនឹងអាចឱ្យស្ទងការធ្វើការអនុម័តលើគោលនយោបាយអត្ថប្រយោជន៍ទន្តសាស្ត្រសម្រាប់គោលបំណងនៃការផ្តល់ជូនទៅខាងបុគ្គល ឬក្រុម។ ស្ទងការនឹងត្រូវតម្រូវឱ្យអនុម័តយកបទបញ្ញត្តិនានាដើម្បីកំណត់ពីលក្ខខណ្ឌវិនិច្ឆ័យសិទ្ធិទទួលបាន។

សំណើច្បាប់នឹងត្រូវតម្រូវឱ្យក្រុមហ៊ុនដាក់អត្រាគោលនៃផលិតផលជាក្រុម និងការផ្លាស់ប្តូរណាមួយលើកត្តាអត្រាជាក្រុម ដែលនឹងត្រូវចូលជាធរមាននៅថ្ងៃទី1 ខែមករា ក្នុងឆ្នាំនីមួយៗ ឬមុនថ្ងៃទី1 ខែកក្កដា ក្នុងឆ្នាំបន្ទាប់។ ស្ទងការនឹងត្រូវតម្រូវឱ្យបដិសេធសំណើផ្លាស់ប្តូរណាមួយចំពោះអត្រាគោលដែលមានចំនួនច្រើនលើសលប់ មិនគ្រប់គ្រាន់ ឬមិនសមហេតុផល ពាក់ព័ន្ធនឹងការគិតថ្លៃអត្ថប្រយោជន៍នោះ។ ស្ទងការក៏នឹងត្រូវតម្រូវឱ្យបដិសេធលើការផ្លាស់ប្តូរណាមួយចំពោះកត្តាអត្រាក្រុម ដែលមិនត្រឹមត្រូវ ឬដែលមិនពិត។

សំណើច្បាប់ចែងពីលក្ខខណ្ឌវិនិច្ឆ័យ (ប្រសិនបើបំពេញតាមលក្ខខណ្ឌនេះ) ដែលនឹងត្រូវតម្រូវឱ្យសន្មតបដិសេធលើអត្រារបស់ក្រុមហ៊ុន រួមបញ្ចូលទាំងករណីដែលអត្រាខាតបង់ផ្នែកទន្តសាស្ត្រសរុបសម្រាប់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដែលបានផ្តល់ដោយក្រុមហ៊ុនមួយ តិចជាង 83 ភាគរយ។

សំណើច្បាប់នេះនឹងត្រូវបង្កើតនីតិវិធីដែលតម្រូវឱ្យអនុវត្តតាម ប្រសិនបើអត្រាដែលបានស្នើនោះ ត្រូវបានសន្មតថាបានបដិសេធ ឬប្រសិនបើស្ទងការបដិសេធអត្រានោះ។

សំណើច្បាប់នឹងត្រូវតម្រូវឱ្យអង្គភាពបើកសវនាការមួយ ប្រសិនបើក្រុមហ៊ុនរាយការណ៍ពីអត្រាខាតបង់មូលធនផ្អែកលើហានិភ័យផ្អែកលើមូលដ្ឋានអង្គភាពរួមបញ្ចូលគ្នាដែលលើសពី 700 ភាគរយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

សំណើច្បាប់នឹងត្រូវតម្រូវឱ្យស្ទងការធ្វើប្រកាសឱ្យប្រើបទបញ្ញត្តិដែលមានសង្គតិភាពជាមួយនឹងលក្ខខណ្ឌរបស់ខ្លួនត្រឹមថ្ងៃទី1 ខែតុលា ឆ្នាំ2023។ សំណើច្បាប់នឹងអនុវត្តចំពោះគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រទាំងអស់ដែលបានចេញរួច បានចូលជាធរមាន បានប្រគល់ជូន ឬបានបន្តជាថ្មីនៅថ្ងៃ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2024។

# សំណួរទី2៖ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

**ការចូលរួមចំណែកពីការបោះឆ្នោតរបស់អ្នក▶**

តាមរយៈការតម្រូវដោយច្បាប់ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងលេខាខំមិនវែល។

*ការបោះឆ្នោតជំទាស់* នឹង កំណត់បទបញ្ញត្តិលើអត្រាធានារ៉ាប់រងធ្មេញ រួមបញ្ចូលទាំងការតម្រូវឱ្យក្រុមហ៊ុនធ្វើការចំណាយយ៉ាងតិច 83% នៃប្រាក់បុព្វលាភរ៉ាប់រងលើការចំណាយផ្នែកទន្តសាស្ត្ររបស់សមាជិក និងការកែលម្អគុណភាព ជាជាងការចំណាយរដ្ឋបាល ហើយត្រូវធ្វើការផ្លាស់ប្តូរដទៃទៀតចំពោះបទបញ្ញត្តិធានារ៉ាប់រងធ្មេញ។

*ការបោះឆ្នោតជំទាស់* នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរចំពោះច្បាប់ដែលពាក់ព័ន្ធបទបញ្ញត្តិដែលអនុវត្តចំពោះក្រុមហ៊ុនធានារ៉ាប់រងឡើយ។

**របាយការណ៍ផលប៉ះពាល់សារពើពន្ធ▶**

តាមការតម្រូវពីច្បាប់ របាយការណ៍ផលប៉ះពាល់សារពើពន្ធ ត្រូវសរសេរដោយការិយាល័យប្រតិបត្តិរដ្ឋបាល និងហិរញ្ញវត្ថុ។

វិធានការណ៍ដែលបានស្នើឡើង ពុំអាចដឹងពីផលប៉ះពាល់សារពើពន្ធជាសារវ័ន្តចំពោះហិរញ្ញវត្ថុរដ្ឋ និងហិរញ្ញវត្ថុរដ្ឋាភិបាលក្រុងឡើយ។

**ទទ្បីករណ៍▶**

ដូចបានចែងដោយច្បាប់ ទទ្បីករណ៍ 150 ពាក្យ ត្រូវសរសេរដោយ ដោយអ្នកគាំទ្រ និង អ្នកបដិសេធលើ សំណួរនីមួយៗ និងឆ្លុះបញ្ចាំងពី ទស្សនៈរបស់ពួកគេ។ ខំមិនវែលនៃ រដ្ឋម៉ាសាជូសេត ពុំបានគាំទ្រចំពោះ ទទ្បីករណ៍ទាំងនេះទេ ហើយក៏ មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃ សេចក្តីថ្លែងការដែលបានធ្វើឡើងនៅក្នុង ទទ្បីករណ៍ទាំងនេះដែរ។ ឈ្មោះរបស់ បុគ្គល និង ស្ថាប័នដែល បានសរសេរសេចក្តីថ្លែងការនីមួយៗ និងមតិយោបល់ ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃផ្សេងទៀត អំពីសេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យ លេខាធិការខំមិនវែល។

*បោះឆ្នោតគាំទ្រ៖* ការបោះឆ្នោតគាំទ្រ ពង្រីកច្បាប់នៃការការពារអតិថិជនដែលមានរួចជាស្រេចសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងវេជ្ជសាស្ត្រ ទៅដល់ក្រុមហ៊ុនធានារ៉ាប់រងធ្មេញ។

ការបោះឆ្នោតគាំទ្រធានានានូវការរ៉ាប់រងបានល្អប្រសើរ និងតម្លៃចំពោះអតិថិជន ជាជាងការខាតបង់របស់ក្រុមហ៊ុនដែលគ្មានហេតុផល។

ឧទាហរណ៍ យោងទៅតាមទម្រង់ 990 ឆ្នាំ2019 របស់ខ្លួន ក្រុមហ៊ុន Delta Dental (ក្នុងរដ្ឋម៉ាសាជូសេតតែមួយ) បានបង់ប្រាក់រង្វាន់ផ្តាច់មុខ ប្រាក់កម្រៃជើងសារ និងប្រាក់ទូទាត់ដល់ក្រុមហ៊ុនបុត្តសម្ព័ន្ធចំនួន 382$ លានដុល្លារ ហើយចំណាយតែ 177$ លានដុល្លារសម្រាប់ការថែទាំអ្នកជំងឺ។

ការបោះឆ្នោតគាំទ្រ នឹងលុបបំបាត់វិសមភាពនេះ។ ស្រដៀងគ្នានឹងធានារ៉ាប់រងវេជ្ជសាស្ត្រដែរ ច្បាប់នេះនឹងត្រូវតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងបែងចែកប្រាក់បុព្វលាភរ៉ាប់រងយ៉ាងតិច 83% នៃប្រាក់បុព្វលាភដែលបានបង់រួចទៅខាងការថែទាំអ្នកជំងឺ ឬសងប្រាក់បុព្វលាភរ៉ាប់រងនោះទៅឱ្យអ្នកជំងឺ ដើម្បីបំពេញតាមស្តង់ដានេះ។

ក្រុមហ៊ុនធានារ៉ាបរង នឹងព្យាយាមធ្វើយ៉ាងណាឱ្យអ្នកបោះឆ្នោតភាន់ច្រឡំ ដោយថា ប្រាក់បុព្វលាភធានារ៉ាប់រងនឹងត្រូវបង្កើន។ នេះមិនមែនជាការពិតទេ ដោយសារផ្នែក 2(d) នៃច្បាប់នេះ មិនអនុញ្ញាតឱ្យមានការបង្កើនលើសពីសន្ទស្សន៍តម្លៃទំនិញដោយគ្មានការយល់ព្រមពីរដ្ឋនោះទេ។

បញ្ឈប់ភាពឥតប្រយោជន៍នៃសាជីវកម្ម។

បោះឆ្នោតគាំទ្រដើម្បីធានារ៉ាប់រងធ្មេញដែលត្រឹមត្រូវយុត្តិធម៌។

**Dr. Patricia Brown, DMD, MPH**
**The Committee on Dental Insurance Quality**
**30 College Ave**
**Somerville, MA 02144**
**(617) 437-7333**
**www.fairdentalinsurance.org**

*បោះឆ្នោតជំទាស់៖* សំណួរនេះនឹងបង្កើនថ្លៃចំណាយសម្រាប់ក្រុមគ្រួសារនិងនិយោជិតក្នុងរដ្ឋម៉ាសាជូសេត (ការបង្កើនប្រាក់បុព្វលាភរ៉ាប់រងចំនួន 38% នៅក្នុងការសិក្សាឯករាជ្យមួយ) ហើយអាចនាំឱ្យមនុស្សរ៉ាប់សិបពាន់នាក់មិនអាចទទួលបានការថែទាំធ្មេញ។ នៅពេលដែលតម្លៃទំនិញឡើងថ្លៃកប់ពពក យើងពុំត្រូវការបទបញ្ញតិថ្មីដែលនឹងបង្កើនថ្លៃចំណាយ និងកាត់បន្ថយជម្រើសនោះទេ។

នៅក្នុងប្រទេសនេះ គ្មានច្បាប់ឯណាដូចសំណួរក្នុងសន្លឹកឆ្នោតនេះទេ។ តាមពិត អង្គនីតិបញ្ញត្តិរដ្ឋម៉ាសាជូសេត បានលុបចោលច្បាប់ស្រដៀងគ្នានេះក្នុងឆ្នាំ2011 ដោយសារបានបញ្ជាក់ថាមានបញ្ហាច្រើន និងគ្មានអត្ថប្រយោជន៍ជាក់ស្តែងដល់អ្នកប្រើប្រាស់។ សមាជិកសភាសហព័ន្ធ បានដកច្បាប់នោះចេញពី Obamacare ហើយប្រាក់កម្រៃជើងសារពិសេសក្នុងរដ្ឋម៉ាសាជូសេត ត្រូវបានត្រួតពិនិត្យ និងបដិសេធលើលក្ខខណ្ឌស្រដៀងគ្នានេះ។ ជាងនេះទៅទៀត រដ្ឋបានតម្រូវជាស្រេចឱ្យមានការរាយការណ៍ពីគម្រោងទន្តសាស្ត្រ។

**Louis Rizoli**
**Committee To Protect Public**
**Access To Quality Dental Care**
**120 Arcadia Rd.**
**Westwood, MA 02090**
**(781) 769-4742**
**Protectmydentalcare.com**

**អត្ថបទទាំងស្រុងនៃសំណើច្បាប់នេះ**

ផ្នែកទី 1. ច្បាប់ទូទាត់ត្រូវធ្វើការកែប្រែដោយដាក់បញ្ចូលបន្ទាប់ពីជំពូក 176W នូវជំពូកបន្ទាប់៖

ជំពូក 176X

គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រ

ផ្នែក 1. ដូចប្រើនៅក្នុងជំពូកនេះ ពាក្យខាងក្រោម ត្រូវមានអត្ថន័យដូចតទៅ លើកលែងតែមានការតម្រូវជាក់ច្បាស់ពីបរិបទផ្សេង៖

"ក្រុមហ៊ុនធានារ៉ាប់រង" ជាក្រុមហ៊ុនធានារ៉ាប់រង ឬស្ថាប័នដទៃដែលផ្តល់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រនៅក្នុងខំមិនវែល។

**អត្ថបទទាំងស្រុងនៃសំណើច្បាប់នេះ** (ត)

"ស្នងការ" ស្នងការនៃអង្គភាពធានារ៉ាប់រង។

"អ្នកសម្របសម្រួលទិញធានារ៉ាប់រង" ជាអ្នកសម្របសម្រួលទិញធានារ៉ាប់រងសុខភាពរបស់ខំមិនវែល ដែលមានចែងក្នុងជំពូក 176Q។

"គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រ" គម្រោងទន្តសាស្ត្រដាច់ដោយឡែក ដែលរ៉ាប់រងលើការវះកាត់មាត់ធ្មេញ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ដែលបានរ៉ាប់រងដោយបុគ្គលណាម្នាក់ បុគ្គលទូទៅ បណ្តាញ ឬក្រុមគោលនយោបាយសុខភាព ធានារ៉ាប់រងគ្រោះថ្នាក់និងជំងឺដែលចេញដោយក្រុមធានារ៉ាប់រងដែលបានទទួលបានអាជ្ញាប័ណ្ណ ឬដែលទទួលបានការអនុញ្ញាតឱ្យទូទាត់ធានារ៉ាប់រងគ្រោះថ្នាក់និងសុខភាពស្ថិតក្រោមជំពូក 175។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ដែលរ៉ាប់រងដោយគម្រោងសេវាកម្មទន្តសាស្ត្រលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយសាជីវកម្មសេវាវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញ ស្ថិតក្រោមជំពូក 176B។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ ដែលរ៉ាប់រងដោយគម្រោងសេវាកម្មទន្តសាស្ត្រលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយសាជីវកម្មសេវាទន្តសាស្ត្រដែលរៀបចំនៅក្រោមជំពូក 176E។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ ដែលរ៉ាប់រងដោយគម្រោងកិច្ចសន្យាថែទាំសុខភាពមាត់ធ្មេញលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយអង្គការថែទាំសុខភាព ដែលរៀបចំឡើងនៅក្រោមជំពូក 176G។ ឬការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ ដែលរ៉ាប់រងដោយគម្រោងទន្តសាស្ត្រផ្អែកតាមការចង់បានអ្នកផ្តល់សេវាលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយការរៀបចំអ្នកផ្តល់សេវាតាមការចង់បាន ដែលរៀបចំក្រោមជំពូក 176I។ តាមបទបញ្ញត្តិ ស្នងការអាចកំណត់ការរ៉ាប់រងផ្នែកទន្តសាស្ត្រផ្សេងទៀតថាជាគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់គោលបំណងនេះជំពូកនេះ។

"អតិថិជនស្វ័យធានារ៉ាប់រង" គឺជាក្រុមស្វ័យធានារ៉ាប់រង ដែលក្រុមហ៊ុនធានារ៉ាប់រងផ្តល់សេវាកម្មរដ្ឋបាល។

"ក្រុមស្វ័យធានារ៉ាប់រង" ជាក្រុមហ៊ុនដែលមានធានារ៉ាប់រងខ្លួនឯង ឬបង់ប្រាក់ខ្លួនឯងចំពោះគម្រោងសុខភាពក្រុម។

"អ្នកគ្រប់គ្រងជាភាគីទីបី" ជាបុគ្គល ឬស្ថាប័ន (ជំនួសមុខឱ្យក្រុមហ៊ុនធានារ៉ាប់រង រកម្មវិធីទន្តសាស្ត្ររបស់ MassHealth ឬអ្នកទិញអត្ថប្រយោជន៍ទន្តសាស្ត្រ ) ដែលផ្តល់សេវារដ្ឋបាល រួមបញ្ចូលទាំងការទទួល និងការប្រមូលថ្លៃចំណាយវិភាគទាន ឬប្រាក់បុព្វលាភរ៉ាប់រងសម្រាប់កែតម្រូវ ឬកំណត់ការទាមទារចំពោះពលរដ្ឋរបស់ខំមិនវែលនេះ។

ផ្នែក 2. (a) ដោយមិនគិតពីច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយ ដែលផ្ទុយពីនេះ ស្នងការអាចអនុម័តលើគោលនយោបាយអត្ថប្រយោជន៍ទន្តសាស្ត្រដែលបានប្រគល់ជូនទៅអង្គភាពធានារ៉ាប់រងសម្រាប់គោលបំណងនៃការផ្តល់ជូនទៅបុគ្គល និងក្រុម។ គោលនយោបាយអត្ថប្រយោជន៍ទន្តសាស្ត្រនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងនៃជំពូកនេះ ហើយអាចរួមបញ្ចូលនូវបណ្តាញដែលខុសគ្នាពីបណ្តាញទូទៅនៃគម្រោងទន្តសាស្ត្រ។ ស្នងការត្រូវអនុម័តយកបទបញ្ញត្តិពាក់ព័ន្ធនឹងលក្ខខណ្ឌវិនិច្ឆ័យនៃសិទ្ធិទទួលបាន។

(b) ដោយមិនគិតពីច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយ ដែលផ្ទុយពីនេះ ស្នងការត្រូវតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងដែលផ្តល់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រ ប្រគល់ជូនព័ត៌មានតាមដែលស្នងការតម្រូវ ដែលត្រូវរួមបញ្ចូលនូវអត្រានៃការខាតបង់វេជ្ជសាស្ត្របច្ចុប្បន្ន និងបានព្យាករណ៍ទុកសម្រាប់គម្រោងសមាសធាតុនៃការចំណាយរដ្ឋបាលដែលបានព្យាករណ៍ទុក និងព័ត៌មានហិរញ្ញវត្ថុ រួមមានជាអាទិ៍៖ (i) ការធានាទិញ សវនកម្ម ការវាយតម្លៃ ការវិភាគហិរញ្ញវត្ថុ ការចំណាយផ្នែកហិរញ្ញវត្ថុនិងវិនិយោគ (ii) ការចំណាយលើការធ្វើទីផ្សារនិងការលក់ រួមមានជាអាទិ៍ ការផ្សាយពាណិជ្ជកម្ម ទំនាក់ទំនងសមាជិក ការចុះឈ្មោះសមាជិក និងការចំណាយទាំងអស់ពាក់ព័ន្ធនឹងផលិតករ ឈ្មួញកណ្តាល និងអ្នកប្រឹក្សាយោបល់អត្ថប្រយោជន៍ និង (iii) ការទាមទារចំណាយប្រតិបត្តិការ រួមមានជាអាទិ៍ ការវិនិច្ឆ័យក្តី ការប្តឹងឧទ្ធរណ៍ ការដោះស្រាយ និងចំណាយផ្សេងៗពាក់ព័ន្ធការបង់ប្រាក់ទាមទារ។ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយស្នងការ បើពុំដូច្នោះទេ ចំណុចខាងក្រោមត្រូវចាត់ទុកជាការចំណាយថ្លៃរដ្ឋបាលសម្រាប់គោលបំណងនៃការគណនា និងការរាយការណ៍ពីអត្រាខាតបង់ខាងវេជ្ជសាស្ត្រ៖ (i) ការចំណាយថ្លៃរដ្ឋបាលហិរញ្ញវត្ថុ (ii) ការចំណាយលើការធ្វើទីផ្សារនិងការលក់ (iii) ការចំណាយលើការចែកចាយ (iv) ការចំណាយលើប្រតិបត្តិការទាមទារ (v) ការចំណាយលើរដ្ឋបាលវេជ្ជសាស្ត្រ ដូចជា ការគ្រប់គ្រងជំងឺ ការគ្រប់គ្រងការថែទាំ ការត្រួតពិនិត្យការប្រើប្រាស់និងសកម្មភាពគ្រប់គ្រងវេជ្ជសាស្ត្រ (vi) ការចំណាយលើប្រតិបត្តិការបណ្តាញ (vii) ការចំណាយលើសប្បុរសធម៌ (viii) ថ្លៃសេវាក្រុមប្រឹក្សា ការិយាល័យ ឬសមាគម (ix) ការចំណាយលើពន្ធដាររបស់រដ្ឋនិងសហព័ន្ធ និង (x) ការចំណាយលើប្រាក់បៀវត្សរ៍។

(c) ដោយមិនគិតពីច្បាប់ទូទៅ ឬច្បាប់ពិសេសដែលផ្ទុយពីនេះ ក្រុមហ៊ុនធានារ៉ាប់រងដែលផ្តល់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រ រួមបញ្ចូលទាំងក្រុមហ៊ុនធានារ៉ាប់រងដែលទទួលបានអាជ្ញាប័ណ្ណក្រោមជំពូក 175, 176B, 176E, 176G ឬ 176I ត្រូវប្រកាសអត្រាគោលនៃផលិតផលធានារ៉ាប់រងជាក្រុម ហើយការផ្លាស់ប្តូរណាមួយចំពោះកត្តាអត្រាតម្លៃជាក្រុម ដែលត្រូវចូលជាធរមាននៅថ្ងៃទី1 ខែមករា នៃឆ្នាំនីមួយៗ នៅថ្ងៃ ឬមុនថ្ងៃទី1 ខែកក្កដា នៃឆ្នាំបន្ទាប់។ ស្នងការនឹងត្រូវបដិសេធសំណើផ្លាស់ប្តូរណាមួយចំពោះអត្រាគោលដែលមានចំនួនច្រើនលើសលប់ មិនគ្រប់គ្រាន់ ឬមិនសមហេតុផល ពាក់ព័ន្ធនឹងការគិតថ្លៃអត្ថប្រយោជន៍នោះ។ ស្នងការត្រូវបដិសេធចំពោះការផ្លាស់ប្តូរណាមួយលើកត្តាអត្រាតម្លៃជាក្រុម ដែលមិនត្រឹមត្រូវ ឬដែលមិនពិត។ ស្នងការត្រូវអនុម័តបទបញ្ញត្តិដើម្បីអនុវត្តផ្នែកនេះ។

(d) ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងប្រកាសការផ្លាស់ប្តូរអត្រាតម្លៃគោលស្ថិតក្រោមផ្នែកនេះ ហើយការចំណាយរដ្ឋបាលក្នុងនោះ (មិនរាប់បញ្ចូលពន្ធដារនិងការវាយតម្លៃ) កើនឡើងច្រើនជាងកំណើនភាគរយក្នុងឆ្នាំថ្មីៗនេះលើសន្ទស្សន៍តម្លៃផលិតផលសេវាទន្តសាស្ត្រ (មធ្យមភាគទីក្រុងភាគច្រើនរបស់សហរដ្ឋអាមេរិក អតិថិជនតាមទីក្រុងទាំងអស់ មិនមែនកែប្រែតាមរដូវកាល) ឬប្រសិនបើប្រាក់វិភាគទានរបស់ក្រុមហ៊ុនធានារ៉ាប់រងចំពោះអតិរេកនេះមានចំនួនលើសពី 1.9 ភាគរយ ឬប្រសិនបើអត្រាខាតបង់ខាងវេជ្ជសាស្ត្រសរុបសម្រាប់គម្រោងទាំងអស់ដែលផ្តល់ជូនស្ថិតក្រោមជំពូកនេះ តិចជាងភាគរយជាធរមានដែលមានចែងក្នុងផ្នែករង (e) ដូច្នេះ អត្រារបស់ក្រុមហ៊ុនធានារ៉ាប់រង (បន្ថែមពីលើការស្ថិតក្រោមលក្ខខណ្ឌដទៃនៃជំពូកនេះ) ត្រូវសន្មតថាបានបដិសេធថាមានចំនួនច្រើនលើសលប់ដោយស្នងការ ដូច្នេះមានចែងក្នុងផ្នែករងនេះ។ ប្រសិនបើផលធៀបខាតបង់ខាងវេជ្ជសាស្ត្រសម្រាប់គម្រោងទាំងអស់ដែលបានផ្តល់ជូននៅក្រោមជំពូកនេះ តិចជាងភាគរយដែលអាចអនុវត្តបានដែលមានចែងនៅក្នុងផ្នែករង (e) នោះក្រុមហ៊ុនធានារ៉ាប់រងត្រូវសងសំណងបុព្វលាភរ៉ាប់រងដែលលើសនោះទៅកាន់បុគ្គល និងក្រុមដែលខ្លួនបានធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាបរងត្រូវជូនដំណឹងក្នុងរយៈពេល 30 ថ្ងៃ

**អត្ថបទទាំងស្រុងនៃសំណើច្បាប់នេះ** (ត)

ទៅកាន់បុគ្គលនិងក្រុមដែលត្រូវបានរ៉ាប់រងនៅក្រោមគម្រោងនានាក្នុងអំឡុងរយៈពេល 12-ខែដែលពាក់ព័ន្ធ ដែលបុគ្គលនិងក្រុមនោះមានលក្ខណៈសម្បត្តិទទួលបានប្រាក់សំណងចំពោះប្រាក់បុព្វលាភរ៉ាប់រងសម្រាប់រយៈពេល 12-ខែដែលអាចអនុវត្តបាន ឬ (ប្រសិនបើបុគ្គលឬក្រុមនោះនៅតែត្រូវបានរ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងដដែល) ឥណទានលើប្រាក់បុព្វលាភសម្រាប់រយៈពេល 12-ខែ បន្ទាប់។ ចំនួនសរុបនៃប្រាក់សំណងដែលបានចេញ ត្រូវស្មើនឹងចំនួនប្រាក់បុព្វលាភរ៉ាប់រងដែលរកបានដោយក្រុមហ៊ុនធានារ៉ាប់រង ដែលលើសដែលចំនួននោះចាំបាច់សម្រាប់សម្រេចនូវផលធៀបនៃការខាតបង់ខាងវេជ្ជសាស្ត្រនៃភាគរយដែលអាចអនុវត្តបាន ដែលមានចែងក្នុងផ្នែករង (e) ដោយត្រូវធ្វើការគណនាដោយប្រើទិន្នន័យដែលបានរាយការណ៍ដោយក្រុមហ៊ុនធានារ៉ាប់រងដូចមានចែងក្រោមបទបញ្ញត្តិដែលបានប្រកាសឱ្យប្រើប្រាស់ដោយស្នងការ។ ស្នងការអាចអនុញ្ញាតឱ្យមានការលើកលែង ឬកែសម្រួលលើលក្ខខណ្ឌតម្រូវនេះ តែក្នុងករណីដែលបានកំណត់ថា ការចេញប្រាក់សំណងនោះនឹងនាំឱ្យបញ្ហាខ្វះខាតខាងហិរញ្ញវត្ថុចំពោះក្រុមហ៊ុនធានារ៉ាប់រងប៉ុណ្ណោះ។

(e) ផលធៀបនៃការខាតបង់ខាងវេជ្ជសាស្ត្រដែលមានចែងក្នុងផ្នែករង (d) ត្រូវមានចំនួន 83 ភាគរយ។

(f) ប្រសិនបើសំណើផ្លាស់ប្តូរអត្រានោះ ត្រូវបានសន្មតថាបដិសេធ៖ (i) ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងដល់និយោជិតនិងបុគ្គលទាំងអស់ដែលត្រូវបានរ៉ាប់រងស្ថិតក្រោមផលិតផលធានារ៉ាប់រងជាក្រុម ថាសំណើបង្កើននោះត្រូវបានសន្មតថាបដិសេធ ហើយត្រូវស្ថិតក្រោមសវនាការនៅក្នុងអង្គភាពធានារ៉ាប់រង (ii) ស្នងការត្រូវបើកសវនាការ និងត្រូវធ្វើការផ្សព្វផ្សាយសវនាការនោះនៅលើកាសែតនៅក្នុងទីក្រុង Boston, Brockton, Fall River, Pittsfield, Springfield, Worcester, New Bedford និង Lowell ឬត្រូវជូនដំណឹងទៅកាសែតទាំងនោះអំពីសវនាការនោះ ហើយ (iii) អគ្គរដ្ឋអាជ្ញាអាចធ្វើអន្តរាគមន៍នៅក្នុងសវនាការសាធារណៈ ឬនីតិវិធីដទៃទៀត ស្ថិតក្រោមផ្នែកនេះ ហើយអាចតម្រូវឱ្យមានព័ត៌មានបន្ថែម តាមដែលរដ្ឋអាជ្ញាចាត់ទុកថាចាំបាច់ ដើម្បីធានានូវអនុលោមភាពជាមួយនឹងផ្នែករងនេះ។ ស្នងការត្រូវអនុម័តបទបញ្ញត្តិដើម្បីបញ្ជាក់ពីកាលវិភាគនៃសវនាការដែលតម្រូវនៅក្រោមផ្នែកនេះ និងដើម្បីអនុវត្តផ្នែករង (f) នេះ។

(g) ប្រសិនបើស្នងការបដិសេធអត្រាដែលបានប្រគល់ដោយក្រុមហ៊ុនធានារ៉ាប់រង នោះស្នងការត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនធានារ៉ាប់រងមិនឱ្យលើសពី 45 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចូលធរមាននៃអត្រារបស់ក្រុមហ៊ុនធានារ៉ាប់រងទេ។ ក្រុមហ៊ុនធានារ៉ាប់រងអាចប្រគល់សំណើសុំសវនាការជូនដល់អង្គភាពធានារ៉ាប់រងក្នុងរយៈពេល 10ថ្ងៃ ក្រោយពីការជូនដំណឹងនៃការបដិសេធនោះ។ អង្គភាពត្រូវកំណត់ពេលវេលាសវនាការក្នុងរយៈពេល 15ថ្ងៃ បន្ទាប់ពីទទួលបានសំណើនោះ។ ស្នងការនឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍ក្នុងពេល 30ថ្ងៃ បន្ទាប់ពីបញ្ចប់សវនាការនោះ។ ក្រុមហ៊ុនធានារ៉ាប់រងអាចមិនអនុវត្តអត្រាដែលបានបដិសេធនោះ ឬផ្លាស់ប្តូរក្នុងពេលណាមួយ លើកលែងតែស្នងការរក្សាកែប្រែការបដិសេធនោះ ក្រោយពីសវនាការ ឬលើកលែងតែតុលាការច្រានចោលសេចក្តីសម្រេចរបស់ស្នងការ។

ផ្នែក 3. (a) ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ត្រូវប្រគល់របាយការណ៍ហិរញ្ញវត្ថុលម្អិតប្រចាំឆ្នាំជូនដល់អង្គភាព ដោយរៀបរាប់លម្អិតអំពីថ្លៃចំណាយរបស់ក្រុមហ៊ុនធានារ៉ាប់រងពីឆ្នាំប្រតិទិនចាស់។ របាយការណ៍ហិរញ្ញវត្ថុលម្អិតប្រចាំឆ្នាំ ត្រូវរួមបញ្ចូលនូវរាល់ព័ត៌មានទាំងអស់នៅក្នុងផ្នែកនេះ ហើយត្រូវរៀបរាប់ជាចំណុចៗ ត្រង់ចំណុចណាដែលអាចអនុវត្តបាន តាម៖

(i) ទំហំក្រុមទីផ្សារ រួមបញ្ចូលទាំងបុគ្គល ក្រុមតូចដែលមានសមាជិក 1 នាក់ដល់ 5 នាក់, 6 នាក់ ដល់ 10 នាក់, 11 នាក់ ដល់ 25 នាក់, និង 26 នាក់ដល់ 50 នាក់; ក្រុមធំដែលមានសមាជិកពី 50 នាក់ដល់ 100 នាក់, 101 នាក់ដល់ 500 នាក់, 501 រហូតដល់ 1000 នាក់ និងក្រុមធំដែលមានសមាជិកច្រើនជាង 1000 នាក់ និង

(ii) ខ្សែអាជីវកម្ម រួមបញ្ចូលទាំងគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដាច់ដោយឡែក ដែលរ៉ាប់រងលើការវះកាត់មាត់ធ្មេញ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ដែលបានរ៉ាប់រងដោយបុគ្គលណាម្នាក់ បុគ្គលទូទៅ បណ្តាញឬក្រុមគោលនយោបាយសុខភាព ធានារ៉ាប់រងគ្រោះថ្នាក់និងជំងឺដែលចេញដោយក្រុមធានារ៉ាប់រងដែលបានទទួលបានអាជ្ញាប័ណ្ណ ឬដែលទទួលបានការអនុញ្ញាតឱ្យទូទាត់ធានារ៉ាប់រងគ្រោះថ្នាក់និងសុខភាពស្ថិតក្រោមជំពូក 175។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ដែលរ៉ាប់រងដោយគម្រោងសេវាកម្មទន្តសាស្ត្រលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយសាជីវកម្មសេវាវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញ ស្ថិតក្រោមជំពូក 176B។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ ដែលរ៉ាប់រងដោយគម្រោងសេវាកម្មទន្តសាស្ត្រលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយសាជីវកម្មសេវាទន្តសាស្ត្រដែលរៀបចំនៅក្រោមជំពូក 176E។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ ដែលរ៉ាប់រងដោយគម្រោងកិច្ចសន្យាថែទាំសុខភាពមាត់ធ្មេញលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយអង្គការថែទាំសុខភាព ដែលរៀបចំឡើងនៅក្រោមជំពូក 176G។ ការថែទាំការវះកាត់មាត់ធ្មេញណាមួយ សេវាទន្តសាស្ត្រ នីតិវិធីព្យាបាលមាត់ធ្មេញ ឬអត្ថប្រយោជន៍ ដែលរ៉ាប់រងដោយគម្រោងទន្តសាស្ត្រផ្អែកតាមការចង់បានអ្នកផ្តល់សេវាលក្ខណៈជាបុគ្គលដាច់ដោយឡែក ឬជាក្រុម ដែលចេញដោយការរៀបចំអ្នកផ្តល់សេវាតាមការចង់បាន ដែលរៀបចំក្រោមជំពូក 176I។ និងគម្រោងធានារ៉ាប់រងសុខភាពជាក្រុមដាច់ដោយឡែក ដែលចេញដោយស្នងការស្ថិតក្រោមជំពូក 32A។

(b) របាយការណ៍ហិរញ្ញវត្ថុត្រូវរួមបញ្ចូលនូវព័ត៌មានជាអាទិ៍ដូចខាងក្រោម៖ (i) ប្រាក់បុព្វលាភរ៉ាប់រងដែលរកបានដោយផ្ទាល់ ដូចមានចែងក្នុងជំពូក 176J; ការទាមទារដោយផ្ទាល់ដែលកើតមាន ដូចមានចែងក្នុងជំពូក 176J នេះ; (ii) អត្រាខាតបង់ខាងវេជ្ជសាស្ត្រ; (iii) ចំនួនសមាជិក; (iv) ចំនួនក្រុមផ្សេងៗគ្នាដែលត្រូវបានរ៉ាប់រង; (v) ចំនួនជីវិតដែលបានរ៉ាប់រង; (vi) ផលចំណេញមូលធននិងការខាតបង់មូលធនដែលបានដឹង; (vii) ប្រាក់ចំណូលសុទ្ធ; (viii) អតិរេកបង្គរ; (ix) ប្រាក់បម្រុងបង្គរ; (x) ផលធៀបមូលធនផ្អែកលើហានិភ័យ, ផ្អែកលើរូបមន្តដែលបានបង្កើតដោយស្នងការសមាគមធានារ៉ាប់រងជាតិ; (xi) ចំណាយរដ្ឋបាលហិរញ្ញវត្ថុ រួមមាន ការធានាទិញ សវនកម្ម ការវាយតម្លៃ ការវិភាគហិរញ្ញវត្ថុ ការចំណាយផ្នែកហិរញ្ញវត្ថុនិងវិនិយោគ; (xii) ការចំណាយលើការធ្វើទីផ្សារនិងការលក់ រួមមាន ការផ្សាយពាណិជ្ជកម្ម ទំនាក់ទំនងសមាជិក ការចុះឈ្មោះសមាជិក; (xiii) ចំណាយលើការចែកចាយ រួមមាន ប្រាក់កម្រៃជើងសារ ឈ្មួញកណ្តាល ផលិតករ ឈ្មួញកណ្តាល និងអ្នកប្រឹក្សាយោបល់អត្ថប្រយោជន៍; (xiv) ការទាមទារចំណាយប្រតិបត្តិការ រួមមាន ការវិនិច្ឆ័យក្តី ការប្តឹងឧទ្ធរណ៍ ការដោះស្រាយ និងចំណាយផ្សេងៗពាក់ព័ន្ធការបង់ប្រាក់ទាមទារ; (xv) ចំណាយរដ្ឋបាលទន្តសាស្ត្រ រួមមាន ចំណាយលើការគ្រប់គ្រងជំងឺ ការត្រួតពិនិត្យការប្រើប្រាស់ និងសកម្មភាពគ្រប់គ្រងទន្តសាស្ត្រ (xvi) ចំណាយលើប្រតិបត្តិការបណ្តាញ រួមមាន ការចុះកិច្ចសន្យា ទំនាក់ទំនងទន្តពេទ្យ និងនីតិវិធីគោលនយោបាយទន្តសាស្ត្រ; (xvii) ចំណាយលើសប្បុរសធម៌ រួមមាន វិភាគទានណាមួយទៅក្នុងមូលនិធិលើកលែងពន្ធ និងអត្ថប្រយោជន៍

**អត្ថបទទាំងស្រុងនៃសំណើច្បាប់នេះ (ត)**

ដល់សហគមន៍; (xviii) ថ្លៃសេវាក្រុមប្រឹក្សា ការិយាល័យ ឬសមាគម; (xix) ចំណាយផ្សេងៗណាមួយដែលមានរៀបរាប់លម្អិតតាមខ្ទង់ចំណាយ ដោយមិនរាប់បញ្ចូលចំណុច (i) ដល់ (xviii) ទេ; (xx) ចំណាយលើប្រាក់បៀវត្សរ៍ និងចំនួននិយោជិតដែលមាននៅលើបញ្ជីបើកប្រាក់បៀវត្សរ៍របស់ក្រុមហ៊ុនធានារ៉ាប់រង; (xxi) ពន្ធដារ (ប្រសិនបើមាន) ដែលត្រូវបង់ដោយក្រុមហ៊ុនធានារ៉ាប់រងជូនដល់រដ្ឋាភិបាលសហព័ន្ធ ឬទៅកាន់ខំមិនវែលនេះ; និង (xxii) និងព័ត៌មានចាំបាច់ដទៃទៀតដែលស្នងការចាត់ទុកថាមានការចាំបាច់។

(c) ក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលតម្រូវឱ្យរាយការណ៍នៅក្រោមផ្នែកនេះ ផ្តល់សេវារដ្ឋបាលជូនដល់ក្រុមស្វ័យធានារ៉ាប់រង 1 ឬច្រើនក្រុមត្រូវ (ជាឧបសម្ព័ន្ធនៃរបាយការណ៍នោះ) រួមបញ្ចូលព័ត៌មានដូចខាងក្រោម៖ (i) ចំនួនអតិថិជនស្វ័យធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង; (ii) ចំនួនសរុបរបស់សមាជិក ដូចមានចែងក្នុងផ្នែក 1 នៃជំពូក 176J, ក្នុងអតិថិជនស្វ័យធានារ៉ាប់រងទាំងអស់របស់ក្រុមហ៊ុនធានារ៉ាប់រង, (iii) ចំនួនជីវិតសរុបដែលបានធានារ៉ាប់រងនៅក្នុងចំណោមអតិថិជនស្វ័យធានារ៉ាប់រងទាំងអស់របស់ក្រុមហ៊ុនធានារ៉ាបរង; (iv) តម្លៃសរុបនៃប្រាក់បុព្វលាភធានារ៉ាប់រងដែលរកបានដោយផ្ទាល់ ដូចមានចែងក្នុងជំពូក 176J, សម្រាប់អតិថិជនស្វ័យធានារ៉ាប់រងទាំងអស់របស់ក្រុមហ៊ុនធានារ៉ាប់រង; (v) អត្រាខាតបង់ផ្នែកវេជ្ជសាស្ត្រសរុប ដូចមានចែងក្នុងជំពូក 176J នេះ សម្រាប់អតិថិជនស្វ័យធានារ៉ាប់រងទាំងអស់របស់ក្រុមហ៊ុនធានារ៉ាប់រង; (vi) ប្រាក់ចំណូលសុទ្ធ; (vii) អតិរេកបង្គរ; (viii) ប្រាក់បម្រុងបង្គរ; (ix) ភាគរយនៃអតិថិជនស្វ័យធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលរួមបញ្ចូលនូវអត្ថប្រយោជន៍នីមួយៗ ដែលចាំបាច់សម្រាប់គម្រោងអត្ថប្រយោជន៍សុខភាពស្ថិតក្រោមជំពូក 175, 176A, 176B និង 176G; (x) ថ្លៃសេវារដ្ឋបាលដែលបានបង់ដោយអតិថិជនស្វ័យធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង និង (xi) និងព័ត៌មានចាំបាច់ដទៃទៀតដែលស្នងការចាត់ទុកថាមានការចាំបាច់។

(d) ក្រុមហ៊ុនធានារ៉ាប់រងដែលខកខានមិនបានប្រគល់របាយការណ៍នៅថ្ងៃ ឬមុនថ្ងៃទី1 ខែមេសា នឹងត្រូវវាយតម្លៃថាជាប់ពិន័យប្រគល់ឯកសារយឺត មិនលើសពី $100 ក្នុងមួយថ្ងៃ។ អង្គភាពត្រូវប្រកាសជាសាធារណៈនូវព័ត៌មានដែលប្រមូលបានស្ថិតក្រោមផ្នែកនេះ។ អង្គភាពត្រូវចេញរបាយការណ៍សង្ខេបប្រចាំឆ្នាំជូនទៅគណៈកម្មការរួមផ្នែកសេវាកម្មហិរញ្ញវត្ថុ គណៈកម្មការរួមផ្នែកហិរញ្ញប្បទានការថែទាំសុខភាព និងគណៈកម្មការព្រឹទ្ធសភា និងរដ្ឋសភាតាមវិធីនិងមធ្យោបាយនៃរបាយការណ៍ហិរញ្ញវត្ថុលម្អិតត្រឹមថ្ងៃទី15 ខែឧសភា។ ព័ត៌មានត្រូវធ្វើការផ្លាស់ប្តូរជាមួយមជ្ឈមណ្ឌលព័ត៌មានសុខាភិបាល និងធ្វើការវិភាគសម្រាប់ប្រើប្រាស់ក្រោមផ្នែក 10 នៃជំពូក 12C។ ពីពេលមួយទៅពេលមួយ អង្គភាពត្រូវតម្រូវឱ្យអ្នកបង់ប្រាក់ប្រគល់ទិន្នន័យដែលខ្លួនប្រើដើម្បីគណនាសម្រាប់ការធ្វើសវនកម្ម។

ស្នងការត្រូវអនុម័តវិធាននានាដើម្បីអនុវត្តផ្នែករងនេះ រួមមាន ស្តង់ដានិងនីតិវិធីដែលតម្រូវឱ្យមានការចុះបញ្ជីបុគ្គល ឬអង្គភាពដែលមិនទទួលបានអាជ្ញាប័ណ្ណ ឬចុះបញ្ជីដោយស្នងការ ដូចជា មន្ត្រីរដ្ឋបាលជាភាគីទីបី និងលក្ខខណ្ឌវិនិច្ឆ័យសម្រាប់វិធីសាស្ត្ររាយការណ៍និងការបែងចែកដែលមានលក្ខណៈឯកសណ្ឋានភាពតាមស្តង់ដាក្នុងចំណោមក្រុមហ៊ុនធានារ៉ាប់រង។ មុនពេលអនុម័តបទបញ្ញត្តិស្ថិតក្រោមផ្នែកនេះ អង្គភាពត្រូវប្រឹក្សាយោបល់ជាមួយទីភ្នាក់ងាររដ្ឋទៃរបស់ខំមិនវែល និងរដ្ឋាភិបាលសហព័ន្ធ និងក្រុមហ៊ុនធានារ៉ាប់រងដែលរងផលប៉ះពាល់ ដើម្បីធានាថា លក្ខខណ្ឌតម្រូវនៃការរាយការណ៍ដែលកំណត់ក្រោមបទប្បញ្ញត្តិនេះ មិនបានការជាន់គ្នា។

(e) ក្នុងឆ្នាំណាមួយ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងរាយការណ៍ពីផលធៀបមូលធនផ្អែកលើហានិភ័យចំពោះស្ថាប័នរួមបញ្ចូលគ្នាស្ថិតក្រោមផ្នែកង (a) ដែលលើសពី 700 ភាគរយ នោះអង្គភាពត្រូវមានពេលបើកសវនាការសាធារណៈក្នុងរយៈពេល 60 ថ្ងៃ។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវប្រគល់សក្ខីកម្មស្តីពីស្ថានភាពហិរញ្ញវត្ថុជារួមរបស់ខ្លួន និងតម្រូវការជាបន្តបន្ទាប់សម្រាប់អតិរេកបន្ថែម។ ក្រុមហ៊ុនធានារ៉ាប់រងក៏ត្រូវប្រគល់សក្ខីកម្មអំពីរបៀប និងចំណែកប៉ុណ្ណាដែលត្រូវបូកបង្គរជាចំនួនលើសសរុប ក្រុមហ៊ុនធានារ៉ាប់រងនឹងចាត់ចែងចំណែកដែលលើសណាមួយ ដើម្បីកាត់បន្ថយថ្លៃចំណាយនៃគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រ ឬសម្រាប់ការកែលម្អគុណភាពនៃការថែទាំធ្មេញសុវត្ថិភាពអ្នកជំងឺ ឬសកម្មភាពនៃរក្សាទុកថ្លៃចំណាយផ្នែកទន្តសាស្ត្រ មិនបានធ្វើឡើងកាលពីឆ្នាំមុន។ អង្គភាពត្រូវធ្វើការត្រួតពិនិត្យសក្ខីកម្មនោះ រួចចេញរបាយការណ៍ចុងក្រោយអំពីលទ្ធផលនៃសវនាការនោះ។

(f) ស្នងការអាចលើកលែងលើលក្ខខណ្ឌតម្រូវនៃការរាយការណ៍ជាក់លាក់ណាមួយក្នុងផ្នែកនេះ សម្រាប់ចំណាត់ថ្នាក់នៃក្រុមហ៊ុនធានារ៉ាប់រងដែលស្នងការចាត់ទុកថា លក្ខខណ្ឌតម្រូវនៃការរាយការណ៍នោះមិនអាចអនុវត្តបាន។ ក៏ប៉ុន្តែ ស្នងការត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការលើកលែងណាមួយជូនដល់គណៈកម្មការរួមផ្នែកហិរញ្ញប្បទានថែទាំសុខភាព និងគណៈកម្មការព្រឹទ្ធសភានិងរដ្ឋសភាអំពីវិធីនិងមធ្យោបាយនានា។

ផ្នែក 4. លើកលែងតែមានចែងខាងក្រោម បើពុំដូច្នោះទេ ជំពូកនេះត្រូវអនុវត្តចំពោះរាល់គម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រទាំងអស់ រួមបញ្ចូលទាំងគម្រោងដែលចេញក្រោយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់ តាមរយៈអ្នកសម្របសម្រួលទិញធានារ៉ាប់រង ឬតាមរយៈអន្តរការី។ ជំពូកនេះ មិនត្រូវអនុវត្តចំពោះគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដែលបានចេញរួច ផ្តល់ជូនរួច ឬបន្តថ្មី ចំពោះក្រុមធានារ៉ាប់រងខ្លួនឯង ឬកន្លែងដែលក្រុមហ៊ុនកំពុងធ្វើជាអ្នកគ្រប់គ្រងជាភាគីទីបីឡើយ។ គ្មានចំណុចណាមួយនៅក្នុងជំពូកនេះ ត្រូវបកស្រាយថាបានតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងដែលមិនបានចេញគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រដែលស្ថិតក្រោមជំពូកនេះ ឱ្យចេញគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រស្ថិតក្រោមជំពូកនេះឡើយ។

ផ្នែកទី 2.

ផ្នែកទី10 នៃជំពូក 12C នៃច្បាប់ទូទៅ ត្រូវបានកែប្រែដោយបញ្ចូលនៅខាងចុងកថាខណ្ឌ (4) នៃផ្នែករង (b)៖

"ឬផ្នែកទី 3 នៃជំពូកទី 176X"។

ផ្នែកទី 3.

ស្នងការការធានារ៉ាប់រង ត្រូវប្រកាសឱ្យប្រើច្បាស់ត្រឹមថ្ងៃទី1 ខែតុលា ឆ្នាំ2023 ដោយមានបទបញ្ញត្តិស្របគ្នានឹងច្បាប់នេះ។

ផ្នែកទី 4.

លើកលែងតែមានចែងនៅក្នុងច្បាប់នេះ បើពុំដូច្នោះទេ ច្បាប់នេះនឹងត្រូវអនុវត្តចំពោះគម្រោងអត្ថប្រយោជន៍ទន្តសាស្ត្រទាំងអស់ដែលបានចេញរួច បានចូលជាធរមាន បានប្រគល់ជូន ឬបានបន្តជាថ្មីនៅថ្ងៃ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ 2024។

# 3

## សំណួរទី3៖ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# *ការពង្រីកការផ្តល់ជូនអាជ្ញាប័ណ្ណសម្រាប់ការលក់គ្រឿងស្រវឹង*

*តើអ្នកយល់ស្របនឹងច្បាប់ដែលបានសង្ខេបខាងក្រោមទេ ដែលគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយសមាជិកសភា ឬសភាតំណាងរាស្រ្តនៅថ្ងៃ មុនថ្ងៃទី3 ខែឧសភា ឆ្នាំ2022 ឡើយ?*

**សង្ខេប▶**

តាមតម្រូវការផ្លូវច្បាប់ ខ្លឹមសារសង្ខេប ត្រូវបានសរសេរ ដោយ អគ្គរដ្ឋ អាជ្ញា។

សំណើច្បាប់នេះ នឹងបង្កើនដែនកំណត់ទូទាំងរដ្ឋស្តីពីចំនួនអាជ្ញាប័ណ្ណរួមបញ្ចូលគ្នាសម្រាប់ការលក់គ្រឿងស្រវឹងសម្រាប់ការទទួលទាននៅឆ្ងាយពីអគារ (រួមបញ្ចូលទាំងអាជ្ញាប័ណ្ណសម្រាប់ "គ្រឿងស្រវឹងទាំងអស់" និងសម្រាប់ "ស្រា និងភេសជ្ជៈអប់មេ" ដែលម្ចាស់ហាងលក់រាយអាចកាន់កាប់ឬគ្រប់គ្រង៖ ចាប់ពី 9 ទៅ 12 អាជ្ញាប័ណ្ណក្នុងឆ្នាំ2023 រហូតដល់ 15 អាជ្ញាប័ណ្ណក្នុងឆ្នាំ2027 និងរហូតដល់ 18 អាជ្ញាប័ណ្ណក្នុងឆ្នាំ2031។

ចាប់ពីឆ្នាំ2023 តទៅ សំណើច្បាប់នឹងកំណត់ពីចំនួនអតិបរមានៃអាជ្ញាប័ណ្ណ "គ្រឿងស្រវឹងគ្រប់ប្រភេទ" ដែលម្ចាស់ហាងលក់រាយអាចកាន់កាប់ឬគ្រប់គ្រង ត្រឹម 7 អាជ្ញាប័ណ្ណ លើកលែងតែម្ចាស់ហាងលក់រាយមានអាជ្ញាប័ណ្ណបែបនេះច្រើនជាង 7 ក្នុងពេលបច្ចុប្បន្ននេះ។

សំណើច្បាប់នេះនឹងតម្រូវឱ្យម្ចាស់ហាងលក់រាយធ្វើការលក់គ្រឿងស្រវឹងសម្រាប់ការទទួលទាននៅឆ្ងាយពីទីតាំង តាមរយៈការទិញដូរផ្ទាល់មុខ ហើយនឹងហាមឃាត់ការលក់ដោយស្វ័យប្រវត្តិ និងការលក់គ្រឿងស្រវឹងទិញដូរដោយខ្លួនឯងពីហាងលក់រាយ។

សំណើច្បាប់នឹងកែប្រែលើការគណនាការផាកពិន័យដែលគណៈកម្មាធិការគ្រប់គ្រងគ្រឿងស្រវឹង អាចទទួលយកពាក់ព័ន្ធនឹងការដកអាជ្ញាប័ណ្ណ ដែលចេញនៅក្រោមច្បាប់ស្តីពីការគ្រប់សុរារបស់ជាតិ។ សំណើច្បាប់នេះ នឹងធ្វើការកែប្រែលើរូបមន្តសម្រាប់ការគណនាថ្លៃសេវានោះ ពីការផ្អែកលើប្រាក់ចំណេញដុលនៅលើការលក់គ្រឿងស្រវឹង ទៅជាការផ្អែកលើប្រាក់ចំណេញដុលពីការលក់រាយគ្រប់ប្រភេទវិញ។

សំណើច្បាប់នេះក៏នឹងបន្ថែមអាជ្ញាប័ណ្ណយានជំនិះនៅក្រៅរដ្ឋចូលទៅក្នុងបញ្ជីនៃទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលម្ចាស់ប័ណ្ណនេះដែលចេញក្រោមច្បាប់ស្តីពីការគ្រប់គ្រងសុរារបស់ជាតិ ឬទីភ្នាក់ងារ ឬនិយោជិត អាចជ្រើសរើសពឹងផ្អែកលើភស្តុតាងសមស្របសម្រាប់ជាសម្គាល់នៃអត្តសញ្ញាណនិងអាយុរបស់បុគ្គល។

---

**ការចូលរួមចំណែកពីការបោះឆ្នោតរបស់អ្នក▶**

តាមរយៈការតម្រូវដោយច្បាប់ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងលេខាធិការ។

*ការបោះឆ្នោតគាំទ្រ* នឹងបង្កើនចំនួនអាជ្ញាប័ណ្ណហាងលក់រាយមួយអាចមានសម្រាប់ការលក់គ្រឿងស្រវឹងដើម្បីទទួលទាននៅឆ្ងាយពីទីតាំងលក់ កំណត់ចំនួនអាជ្ញាប័ណ្ណ "គ្រឿងស្រវឹងគ្រប់ប្រភេទ" ដែលហាងលក់រាយអាចទទួលបាន កំណត់ការប្រើប្រាស់ការទិញដោយខ្លួនឯង និងតម្រូវឱ្យហាងលក់រាយទទួលយកឯកសារសម្គាល់អត្តសញ្ញាណនៅក្រៅរដ្ឋរបស់អតិថិជន។

*ការបោះឆ្នោតជំទាស់* នឹងពុំមានការផ្លាស់ប្តូរលើច្បាប់ដែលគ្រប់គ្រងលើការលក់រាយនៃគ្រឿងស្រវឹងឡើយ។

---

**របាយការណ៍ផលប៉ះពាល់សារពើពន្ធ▶**

តាមការតម្រូវពីច្បាប់ របាយការណ៍ផលប៉ះពាល់សារពើពន្ធ ត្រូវសរសេរដោយការិយាល័យប្រតិបត្តិរដ្ឋបាល និងហិរញ្ញវត្ថុ។

វិធានការណ៍ដែលបានស្នើឡើង ពុំអាចដឹងពីផលប៉ះពាល់សារពើពន្ធជាសារវន្តចំពោះហិរញ្ញវត្ថុរដ្ឋ និងហិរញ្ញវត្ថុរដ្ឋាភិបាលក្រុងឡើយ។

# សំណួរទី3៖ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

**ទឡ្ហីករណ៍▶**

ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវសរសេរដោយ ដោយអ្នកគាំទ្រ និង អ្នកបដិសេធលើ សំណួរនីមួយៗ និងឆ្លុះបញ្ចាំងពី ទស្សនៈរបស់ពួកគេ។ ខំមិនវែលនៃ រដ្ឋម៉ាសាជូសេត ពុំបានគាំទ្រចំពោះ ទឡ្ហីករណ៍ទាំងនេះទេ ហើយក៏ មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃ សេចក្តីថ្លែងការដែលបានធ្វើឡើង នៅក្នុង ទឡ្ហីករណ៍ទាំងនេះដែរ។ ឈ្មោះរបស់ បុគ្គល និង ស្ថាប័ន ដែល បានសរសេរសេចក្តីថ្លែងការនីមួយៗ និងមតិយោបល់ ជាលាយលក្ខណ៍អក្សរណាមួយពី អ្នកដទៃផ្សេងទៀត អំពីសេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យ លេខាធិការ ខំមិនវែល។

*បោះឆ្នោតគាំទ្រ៖* ការបោះឆ្នោតគាំទ្រ នឹងបំពេញសេចក្តីត្រូវការសម្រាប់ការពង្រីកបន្ថែមនូវភាពងាយស្រួលក្នុងលក្ខណៈសមស្របនិងមានតុល្យភាព ដែលក៏អាចការពារប្រឆាំងនឹងការលក់ខុសច្បាប់ផងដែរ។

ការបោះឆ្នោតគាំទ្រ ពង្រីកបន្ថែមនូវភាពងាយស្រួលតាមរយៈការបង្កើនបន្តិចម្តងៗនូវចំនួនសរុបនៃអាជ្ញាប័ណ្ណគ្រឿងស្រវឹង ដែលបុគ្គលម្នាក់ ឬក្រុមហ៊ុនណាមួយអាចកាន់កាប់បាន។ ស្តង់វេចខ្ចប់ ហាងលក់ទំនិញ ផ្សារទំនើប ហាងលក់រាយធំៗ និងកន្លែងផ្សេងទៀត នឹងអាចដាក់ពាក្យសុំអាជ្ញាប័ណ្ណបន្ថែមសម្រាប់ទីតាំងរបស់ពួកគេដែលមានស្រាប់ ដែលបច្ចុប្បន្នពុំបានលក់គ្រឿងស្រវឹង ហើយបន្ថែមទីតាំងថ្មីដែលពួកគេបើក។

ការបោះឆ្នោតគាំទ្រពង្រីកជាបណ្តើរៗនូវសុវត្ថិភាពសាធារណៈ និងលើកទឹកចិត្តឱ្យហាងលក់រាយមានការប្រុងប្រយ័ត្នតាមរយៈការហាមឃាត់ការទិញគ្រឿងស្រវឹងគិតលុយដោយខ្លួនឯង និងដោយយកការផាកពិន័យសម្រាប់ការលក់គ្រឿងស្រវឹងឱ្យអនីតិជនធ្វើជាមូលដ្ឋានលើការលក់សរុបរបស់ហាង និងមែនគ្រាន់តែលើការលក់គ្រឿងស្រវឹងនោះទេ។

ការបោះឆ្នោតគាំទ្រ ក៏នឹងគាំទ្រដល់ទេសចរណ៍ក្នុងរដ្ឋ និងនាំឱ្យរដ្ឋម៉ាសាជូសេតមានភាពស្របគ្នានឹងរដ្ឋដទៃនៅក្នុងប្រទេស ដោយអនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណប័ណ្ណនៅក្រៅរដ្ឋនៅតាមហាងលក់រាយគ្រឿងស្រវឹង។

**Robert Mellion**
**21st Century Alcohol Retail Reform Committee**
**30 Lyman Street, Suite 2**
**Westborough, MA 01581**
**(508) 366-1100**
**www.Masspack.org**

*បោះឆ្នោតជំទាស់៖* ច្បាប់ស្តីពីអាជ្ញាប័ណ្ណគ្រឿងស្រវឹងរបស់យើង ពុំចាំបាច់ធ្វើកំណែទម្រង់អ្វីច្រើននោះទេ ប៉ុន្តែវិធានការសន្លឹកឆ្នោត ពុំមែនជាដំណោះស្រាយនោះទេ។ វិធានការនេះពុំបានផ្តល់ដំណោះស្រាយពេញលេញចំពោះបញ្ហាស្មុគស្មាញនោះទេ ដោយមានការខិតខំតិចតួចដើម្បីជំរុញឱ្យមានការប្រកួតប្រជែង ឬពង្រីកជម្រើសរបស់អតិថិជន។

ទោះបីជាមានលក្ខខណ្ឌពេញនិយមតែសម្បកក្រៅខ្លះដែលបានបង្កើតឡើងដើម្បីល្បួងអ្នកបោះឆ្នោតក៏ពិតមែន ប៉ុន្តែវិធានការនេះពុំបានដកចេញនូវការដាក់កំហិតដែលហួសសម័យនៅលើការធ្វើសេចក្តីសម្រេចចិត្តក្នុងមូលដ្ឋាននោះទេ តែតាមការពិត បានធ្វើឱ្យរដ្ឋម៉ាសាជូសេតដើរថយក្រោយនៅក្នុងទិដ្ឋភាពជាច្រើន៖

- ផាកពិន័យមិនត្រឹមត្រូវលើហាងលក់រាយ ដែលលក់ទំនិញផ្សេងៗទៀតក្រៅពីគ្រឿងស្រវឹង ដូចជាហាងលក់គ្រឿងទេស និងស្តង់ចំណីអាហារជាដើម។
- ធ្វើឱ្យបច្ចេកវិទ្យានៃម៉ាស៊ីនលក់ទំនិញដែលងាយស្រួលនិងអាចជឿទុកចិត្តបានដែលមានការពេញនិយមប្រើប្រាស់ទូលំទូលាយតាមហាងលក់រាយ ប្រែជាខុសច្បាប់ទៅវិញ។
- កាត់បន្ថយចំនួនអាជ្ញាប័ណ្ណសុរាពេញលេញដែលហាងលក់រាយអាចកាន់កាប់បាន។

វិធីសាស្ត្រខុសឆ្គងនេះ ផ្តល់ប្រយោជន៍ពិសេសដល់ឧស្សាហកម្មគ្រឿងស្រវឹង ដោយឱ្យអតិថិជនដែលខ្សត់ខ្សោយថវិកាជាអ្នកចេញថ្លៃចំណាយ ហើយអនុគ្រោះដល់ហាងលក់រាយក្នុងមូលដ្ឋាន។

យើងស័ក្តិសមនឹងទទួលបានអ្វីច្រើនជាងនេះ។ សូមបោះឆ្នោតជំទាស់ទៅនឹងសំណួរនេះ ជាជាងសុំឱ្យសមាជិកសភារបស់រដ្ឋអ្នកគាំទ្រាំច្បាប់ល្អិតល្អន់ដែលតាមពិតគ្មានបានកែប្រែអ្វីសោះនោះទេ។

**Food Stores for Consumer Choice**
**P.O. Box 130211**
**Boston, MA 02113**
**(617) 798-0465**
**www.FoodStoresMA.org**

### អត្ថបទទាំងស្រុងនៃសំណើច្បាប់នេះ

ផ្នែកទី1. ល្បះទីពីរនៃផ្នែក 15 នៃជំពូក 138 នៃច្បាប់ទូទៅនេះ ត្រូវធ្វើការកែប្រែដោយត្រូវលុបចោល (ក្នុងឧទាហរណ៍នីមួយៗ) នូវឃ្លាថា "ច្រើនជាង 9" ហើយត្រូវជំនួសកន្លែងនោះវិញដោយឃ្លាខាងដូចតទៅនេះ៖ - ច្រើនជាង 12។

ផ្នែកទី2. ល្បះទីពីរនៃផ្នែក15 នៃជំពូក 138 ដែលបានលើកឡើង ដូចបានកែប្រែនៅក្នុងផ្នែក 1 នៃច្បាប់នេះ ត្រូវធ្វើការកែប្រែបន្ថែមទៀតដោយលុបចោល (ក្នុងឧទាហរណ៍នីមួយៗ) នូវលេខ "12" ហើយត្រូវបញ្ចូលនៅកន្លែងនោះវិញដោយលេខដូចតទៅនេះ៖ - 15។

ផ្នែកទី3. ល្បះទីពីរនៃផ្នែក15 នៃជំពូក 138 ដែលបានលើកឡើង ដូចបានកែប្រែនៅក្នុងផ្នែក 2 នៃច្បាប់នេះ ត្រូវធ្វើការកែប្រែបន្ថែមទៀតដោយលុបចោល (ក្នុងឧទាហរណ៍នីមួយៗ) នូវលេខ "15" ហើយត្រូវបញ្ចូលនៅកន្លែងនោះវិញដោយលេខដូចតទៅនេះ៖ - 18។

ផ្នែកទី4. ផ្នែក 15 នៃជំពូក 138 នៃច្បាប់ទូទៅនេះ ត្រូវបន្តកែប្រែបន្ថែមទៀតដោយដាក់បញ្ចូល (បន្ទាប់ពីល្បះទីពីរ) នូវល្បះថ្មីៗដូចខាងក្រោមនេះ៖

គ្មានបុគ្គលណាម្នាក់ ក្រុមហ៊ុន សាជីវកម្ម សមាគម ឬក្រុមបុគ្គលផ្សេងទៀត មិនថាដោយផ្ទាល់ឬដោយប្រយោល ឬតាមរយៈទីភ្នាក់ងារ និយោជិត ម្ចាស់ភាគហ៊ុន មន្ត្រី ឬបុគ្គលដទៃ ឬក្រុមហ៊ុនបុត្តសម្ព័ន្ធណាមួយ ត្រូវផ្តល់ជូនអាជ្ញាប័ណ្ណសរុបរួមច្រើនជាង 7 អាជ្ញាប័ណ្ណសម្រាប់ការលក់គ្រឿងស្រវឹងនៅក្នុងខំមិនវែលនេះទេ ឬចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការទិញគ្រឿងស្រវឹង ឬការទិញធានារ៉ាប់រង ឬសេវាគណនេយ្យ ឬសេវាគិតបញ្ជី ឬទទួលបានភាគរយ ឬថ្លៃសេវាណាមួយពីប្រាក់ចំណូលដុលក្នុងការដោះដូរជំនួយលើការគ្រប់គ្រង ឬចូលរួមក្នុងសកម្មភាពណាមួយដែលបានកំណត់ថាមានឥទ្ធិពលលើលទ្ធផលរួមនៃការផ្តល់អាជ្ញាប័ណ្ណច្រើនជាង 7 នោះទេ។ ក៏ប៉ុន្តែ ប្រសិនបើបុគ្គល ក្រុមហ៊ុន សាជីវកម្ម សមាគម ឬក្រុមបុគ្គលផ្សេងទៀត មិនថាដោយផ្ទាល់ឬដោយប្រយោល ឬតាមរយៈទីភ្នាក់ងារ និយោជិត ម្ចាស់ភាគហ៊ុន មន្ត្រី ឬបុគ្គលដទៃ ឬក្រុមហ៊ុនបុត្តសម្ព័ន្ធណាមួយក៏ដោយ ដែលគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 មានអាជ្ញាប័ណ្ណច្រើនជាង 7 សម្រាប់ការលក់គ្រឿងស្រវឹងនៅក្នុងខំមិនវែលនេះ ឬគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 បានចូលរួមចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការទិញគ្រឿងស្រវឹង ឬការទិញធានារ៉ាប់រង ឬសេវាគណនេយ្យ ឬ

**អត្ថបទទាំងស្រុងនៃសំណើច្បាប់នេះ (ត)**

សេវាគិតបញ្ជី ឬទទួលបានភាគរយ ឬថ្លៃសេវាណាមួយពីប្រាក់ចំណូលដុលក្នុងការដោះដូរជំនួយលើការគ្រប់គ្រង ឬចូលរួមក្នុងសកម្មភាពណាមួយដែលបានកំណត់ថាមានឥទ្ធិពលលើលទ្ធផលរួមនៃការផ្តល់អាជ្ញាប័ណ្ណច្រើនជាង 7 នោះ ពួកគេអាចបន្តកាន់កាប់ចំនួនអាជ្ញាប័ណ្ណគ្រឿងស្រវឹងទាំងអស់បាន និងអាចចូលរួមក្នុងសកម្មភាពណាមួយដែលបានកំណត់ថាមានឥទ្ធិពលលើលទ្ធផលរួមនៃការផ្តល់អាជ្ញាប័ណ្ណក្នុងចំនួននោះ។ អាជ្ញាប័ណ្ណនីមួយៗសម្រាប់ការលក់គ្រឿងស្រវឹង ត្រូវរួមបញ្ចូលនូវអាជ្ញាប័ណ្ណសម្រាប់គោលបំណងនៃការកំណត់ចំនួនអាជ្ញាប័ណ្ណសរុបដែលផ្តល់ជូនក្រោមល្បះទីពីរនៃផ្នែកនេះ។

ផ្នែកទី5. ផ្នែក 1 និង 4 នៃច្បាប់នេះ ត្រូវចូលជាធរមាននៅថ្ងៃទី1 ខែមករា ឆ្នាំ2023។

ផ្នែកទី6. ផ្នែក 2 នៃច្បាប់នេះ ត្រូវចូលជាធរមាននៅថ្ងៃទី1 ខែមករា ឆ្នាំ2027។

ផ្នែកទី7. ផ្នែក 3 នៃច្បាប់នេះ ត្រូវចូលជាធរមាននៅថ្ងៃទី1 ខែមករា ឆ្នាំ2031។

ផ្នែកទី8. ផ្នែក 15 នៃជំពូក 138 នៃច្បាប់ទូទៅនេះ (ដូចមានបង្ហាញស្រាប់) ត្រូវបន្តកែប្រែបន្ថែមទៀតដោយដាក់បញ្ចូលបន្ទាប់កថាខណ្ឌចុងក្រោយ នូវកថាខណ្ឌខាងក្រោមនេះ៖

ការលក់គ្រឿងស្រវឹងនៅក្នុងហាងតាមរយៈអាជ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងការលក់គ្រឿងស្រវឹងដូចបានអនុញ្ញាតនៅក្រោមលក្ខខណ្ឌនៃផ្នែកនេះ ត្រូវធ្វើឡើងតាមរយៈការទូទាត់ប្រាក់ផ្ទាល់មុខគ្នា រវាងអតិថិជននិងម្ចាស់អាជ្ញាប័ណ្ណ ឬរវាងអតិថិជននិងនិយោជិតដែលទទួលបានការអនុញ្ញាតពីម្ចាស់អាជ្ញាប័ណ្ណ ដែលមានអាយុ 18 ឆ្នាំហើយ។ ការលក់ដោយស្វ័យប្រវត្តិក្នុងការហាង ឬការលក់ដោយគិតប្រាក់ខ្លួនឯង តាមម្ចាស់អាជ្ញាប័ណ្ណនេះ ត្រូវបានហាមឃាត់។

ផ្នែកទី9. ផ្នែក 23 នៃជំពូក 138 នៃច្បាប់ទូទៅនេះ ត្រូវធ្វើការកែប្រែដោយត្រូវលុបចោល (ក្នុងល្បះទីបីនៃកថាខណ្ឌទីម្ភៃ) នូវឃ្លាថា "ការលក់គ្រឿងស្រវឹង" ហើយត្រូវជំនួសកន្លែងនោះវិញដោយឃ្លាខាងដូចតទៅនេះ៖ - រាល់ការលក់រាយគ្រប់ប្រភេទ។

ផ្នែកទី10. ផ្នែក 34B នៃជំពូក 138 នៃច្បាប់ទូទៅនេះ ត្រូវធ្វើកែប្រែដោយដាក់បញ្ចូលនៅក្នុងល្បះទីមួយនៃកថាខណ្ឌទីពីរ បន្ទាប់ពីឃ្លា "ឬអត្តសញ្ញាណប័ណ្ណយោធាដែលចេញដោយសហរដ្ឋអាមេរិកដែលមានសុពលភាព" នូវឃ្លាដូចតទៅនេះ៖ ឬអាជ្ញាប័ណ្ណយានជំនិះដែលមានសុពលភាពដែលចេញដោយរដ្ឋផ្សេង។

ផ្នែកទី11. ផ្នែក 34B នៃជំពូក 138 ដែលបានលើកឡើង នៃច្បាប់ទូទៅនេះ ត្រូវធ្វើកែប្រែបន្ថែមដោយល្បះទីពីរនៃកថាខណ្ឌទីពីរ បន្ទាប់ពីឃ្លា "ឬអាជ្ញាប័ណ្ណយានជំនិះដែលបានចេញស្របតាមផ្នែកទីប្រាំបី" នូវឃ្លាដូចតទៅនេះ៖ ឬអាជ្ញាប័ណ្ណយានជំនិះដែលមានសុពលភាពដែលចេញដោយរដ្ឋផ្សេង។




តាមការតម្រូវដោយច្បាប់រដ្ឋ សៀវភៅនេះមានព័ត៌មានអំពីសំណួរការបោះឆ្នោតដែលបានប្រគល់ជូនទៅលេខាធិការមិនលើសពីត្រឹមថ្ងៃទី6 ខែកក្កដា ឆ្នាំ2022។

សំណួរបន្ថែមអំពីការបោះឆ្នោត ដែលបានប្រគល់ជូនបន្ទាប់កាលបរិច្ឆេទផុតកំណត់នៃការព្រីនសៀវភៅនេះ អាចមាននៅលើសន្លឹកឆ្នោតរបស់អ្នក។

ចូលទៅកាន់ **www.VoteInMA.com** សម្រាប់ព័ត៌មានបន្ថែមណាមួយដែលអាចមាននៅក្នុងការបោះឆ្នោតរបស់រដ្ឋនៅថ្ងៃទី8 ខែវិច្ឆិកា ឆ្នាំ2022។ សន្លឹកឆ្នោតគំរូ នឹងអាចរកមើលបាននៅលើអនឡាញក្នុងខែតុលា ឆ្នាំ2022។

## ការបោះឆ្នោតក្នុងឆ្នាំ2022



ឆ្នាំនេះ អ្នកបោះឆ្នោតក្នុងរដ្ឋម៉ាសាជូសេត មានជម្រើសក្នុងការបោះឆ្នោតច្រើនជាងមុន។ អ្នកអាចបោះឆ្នោតៈ

- នៅថ្ងៃបោះឆ្នោត នៅទីកន្លែងបោះឆ្នោតរបស់អ្នក ឬ
- ក្នុងអំឡុង រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬ
- តាមសំបុត្រ ពីលំនៅដ្ឋានផ្ទាល់ខ្លួនរបស់អ្នក។

អ្នកបោះឆ្នោតគ្រប់រូបមានអាចជ្រើសរើសជម្រើសណាមួយក្នុងចំណោមជម្រើសទាំង 3 ខាងលើ។ ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬការបោះឆ្នោតតាមសំបុត្រ ពុំចាំបាច់មានហេតុផលអ្វីនោះទេ។

ក៏មានការផ្លាស់ប្តូរមួយចំនួនដើម្បីឱ្យអ្នកបោះឆ្នោតមានពេលវេលានិងឱកាសច្រើនជាងមុនក្នុងការចុះឈ្មោះបោះឆ្នោតផងដែរ។ សូមអានបន្ត ដើម្បីស្វែងយល់បន្ថែមអំពីការចុះឈ្មោះ និងការបោះឆ្នោតក្នុងឆ្នាំ2022។

## ការចុះឈ្មោះបោះឆ្នោត



មិនថាអ្នកមានគម្រោងបោះឆ្នោតដោយផ្ទាល់ ឬតាមសំបុត្រទេ អ្នកនឹងត្រូវការធ្វើឱ្យប្រាកដថា អ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ។ អ្នកអាចត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោតរបស់អ្នកតាមអនឡាញ នៅ **www.VoteInMA.com**។

ចាប់ពីឆ្នាំនេះតទៅ កាលបរិច្ឆេទផុតកំណត់សម្រាប់ការចុះឈ្មោះបោះឆ្នោត គឺពេលនេះមានរយៈពេល **10** ថ្ងៃ មុនថ្ងៃបោះឆ្នោត។

ដើម្បីធ្វើការបោះឆ្នោតក្នុងការបោះឆ្នោតរបស់រដ្ឋនៅថ្ងៃទី8 ខែវិច្ឆិកា ឆ្នាំ2022 អ្នកត្រូវតែធ្វើការចុះឈ្មោះបោះឆ្នោតត្រឹមថ្ងៃទី **29** ខែតុលា **ឆ្នាំ2022**។

ថ្ងៃទី29 ខែតុលា ក៏ជាកាលបរិច្ឆេទផុតកំណត់ ដើម្បីធ្វើការផ្លាស់ប្តូរការចុះឈ្មោះបោះឆ្នោតរបស់អ្នកផងដែរ ដូចជាការផ្លាស់ប្តូរអាសយដ្ឋានជាដើម។

### របៀបធ្វើការចុះឈ្មោះបោះឆ្នោត

តាមអនឡាញ – ប្រសិនបើអ្នកមានប័ណ្ណបើកបររដ្ឋម៉ាសាជូសេត ឬអត្តសញ្ញាណប័ណ្ណរដ្ឋម៉ាសាជូសេត អ្នកអាចធ្វើការចុះឈ្មោះតាមអនឡាញបាននៅ **www.RegisterToVoteMA.com**។ អ្នកក៏អាចប្រើប្រាស់ប្រព័ន្ធចុះឈ្មោះបោះឆ្នោតតាមអនឡាញ ដើម្បីធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នក ឬផ្លាស់ប្តូរសម្ព័ន្ធគណបក្សនយោបាយរបស់អ្នកបានផងដែរ។ ការចុះឈ្មោះតាមអនឡាញត្រូវប្រគល់មិនឱ្យលើសពីម៉ោង 11:59 យប់ នៅថ្ងៃទី29 ខែតុលា ឡើយ។

តាមសំបុត្រ – ប្រសិនបើអ្នកមិនអាចចុះឈ្មោះតាមអនឡាញបាន អ្នកក៏មានជម្រើសក្នុងការចុះឈ្មោះបោះឆ្នោតតាមសំបុត្រផងដែរ។ ទម្រង់នៃការចុះឈ្មោះតាមសំបុត្រ អាចស្នើសុំបានដោយទូរស័ព្ទទៅលេខ 1-800-462-VOTE (8683)។ រាល់ការចុះឈ្មោះបោះឆ្នោតតាមសំបុត្រទាំងអស់ ត្រូវតែវាយត្រាប្រៃសណីយ៍ ឬប្រគល់ជូនទៅសាលាក្រុង ឬសាលាសង្កាត់ នៅត្រឹមថ្ងៃទី29 ខែតុលា។

ដោយផ្ទាល់ – អាចធ្វើការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាននីមួយៗ ដែលជាទូទៅមានទីតាំងនៅក្នុងសាលាក្រុង ឬសាលាសង្កាត់របស់អ្នក។ អ្នកអាចស្វែងរកការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកនៅ **www.VoteInMA.com**។ រាល់ការិយាល័យបោះឆ្នោតទាំងអស់ ត្រូវផ្តល់ការចុះឈ្មោះដោយផ្ទាល់នៅថ្ងៃទី29 ខែតុលា រហូតដល់ម៉ោង 5 យប់។

# ការបោះឆ្នោតតាមសំបុត្រ



ចាប់ពីឆ្នាំនេះទៅ រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងរដ្ឋម៉ាសាជូសេត អាចបោះឆ្នោតតាមសំបុត្របាន ដោយពុំចាំបាច់ត្រូវមានមូលហេតុនៅក្នុងការបោះឆ្នោតនោះឡើយ។ ដើម្បីធ្វើការបោះឆ្នោតតាមសំបុត្រ អ្នកនឹងត្រូវការដាក់សំណើទៅកាន់មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋាន។ ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ ត្រូវបានផ្ញើទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនៅក្នុងរដ្ឋម៉ាសាជូសេតក្នុងពេលថ្មីៗនេះ។

ប្រសិនបើអ្នកបានដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្រ សន្លឹកឆ្នោតរបស់អ្នកគួរតែត្រូវបានផ្ញើមកអ្នកក្នុងពេលឆាប់ៗនេះមិនខាន។ អ្នកអាចតាមដានសន្លឹកឆ្នោតរបស់អ្នកតាមអនឡាញ នៅ **www.VoteInMA.com**

ប្រសិនបើអ្នកចង់បោះឆ្នោតតាមសំបុត្រ និងបានដាក់ពាក្យរួចហើយ សូមអនុវត្តតាមជំហានខាងក្រោម ដើម្បីស្នើសុំសន្លឹកឆ្នោតរបស់អ្នក។

## របៀបបោះឆ្នោតតាមសំបុត្រ

**1.** ពិនិត្យមើលការចុះឈ្មោះបោះឆ្នោតរបស់អ្នកនៅ **www.VoteInMA.com.**

ប្រសិនបើអ្នកមិនបានចុះឈ្មោះបោះឆ្នោតដោយប្រើអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកទេ អ្នកត្រូវធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នក មុនពេលដាក់ពាក្យសុំការបោះឆ្នោតតាមសំបុត្រ។ កាលបរិច្ឆេទផុតកំណត់ដើម្បីធ្វើការផ្លាស់ប្តូរការចុះឈ្មោះបោះឆ្នោតរបស់អ្នក គឺនៅថ្ងៃទី**29** ខែតុលា។

**2.** ដាក់ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ។

អ្នកអាចបំពេញពាក្យស្នើសុំដោយផ្ទាល់ដៃ ឬតាមប្រព័ន្ធអេឡិចត្រូនិក។ ពាក្យស្នើសុំ អាចស្វែងរកបាននៅ **www.VoteInMA.com**។ ត្រូវប្រាកដថា អ្នកបានបញ្ចូលអាសយដ្ឋានដែលអ្នកចង់ឱ្យគេផ្ញើអាសយដ្ឋានទៅអ្នក ប្រសិនបើអាសយដ្ឋាននោះខុសពីអាសយដ្ឋានដែលអ្នកបានចុះឈ្មោះបោះឆ្នោត។

ប្រសិនបើអ្នកចង់ឱ្យគេផ្ញើសន្លឹកពាក្យសុំទៅអ្នក សូមទូរស័ព្ទទៅអង្គភាពបោះឆ្នោត តាមរយៈលេខ 1-800-462-VOTE (8683) ដើម្បីធ្វើការស្នើសុំ។ ក្នុងជម្រើសនេះ អ្នកគ្រាន់តែដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរតាមលិខិតមួយច្បាប់ ទៅកាន់មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានទៅបានហើយ។ លិខិតនោះត្រូវរួមបញ្ចូលឈ្មោះរបស់អ្នក អាសយដ្ឋានអ្នកបានចុះឈ្មោះបោះឆ្នោត អាសយដ្ឋានដែលអ្នកចង់ឱ្យគេផ្ញើសន្លឹកឆ្នោតមក និងហត្ថលេខារបស់អ្នក។

**3.** ប្រគល់ពាក្យស្នើសុំរបស់អ្នក ទៅកាន់ការិយាល័យបោះឆ្នោតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្ររបស់អ្នក ត្រូវទៅដល់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក មិនយូរជា**ងថ្ងៃទី1** ខែវិច្ឆិកា ឡើយ។ សូមណែនាំឱ្យប្រគល់ពាក្យស្នើសុំបោះឆ្នោតតាមសំបុត្រយ៉ាងតិច 2 សប្តាហ៍មុនថ្ងៃបោះឆ្នោត។

ពាក្យស្នើសុំអាចប្រគល់តាមអនឡាញ តាមសំបុត្រ តាមអ៊ីម៉ែល តាមទូរសារ ឬដោយផ្ទាល់ក៏បាន។ អ្នកអាចស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកបាន នៅ **www.VoteInMA.com**។

**4.** រង់ចាំឱ្យសន្លឹកឆ្នោតរបស់អ្នកមកដល់។

មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក នឹងចាប់ផ្តើមផ្ញើការបោះឆ្នោតនៅដើមខែតុលា ហើយនឹងបន្តផ្ញើសន្លឹកឆ្នោតនៅពេលពាក្យសុំមកដល់ រហូតដល់កាលបរិច្ឆេទផុតកំណត់នៃការស្នើសុំនៅថ្ងៃទី1 ខែវិច្ឆិកា។

**5.** ប្រគល់សន្លឹកឆ្នោតត្រឡប់ទៅវិញ។

សន្លឹកឆ្នោតត្រូវប្រគល់ត្រឡប់ទៅវិញតាមសំបុត្រ ត្រូវមានវាយត្រាប្រៃសណីយ៍ **ត្រឹមថ្ងៃទី8 ខែវិច្ឆិកា ឆ្នាំ2022 ហើយត្រូវមកដល់មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកត្រឹមថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2022 ដើម្បីធ្វើការរាប់ចំនួន។**

រាល់ការបោះឆ្នោតតាមកញ្ចប់សំបុត្រក្នុងឆ្នាំ2022 នេះ នឹងត្រូវរួមបញ្ចូលរួមបញ្ចូលស្រោមសំបុត្រមានចុះអាសយដ្ឋានជាមុន ដែលបានបង់ថ្លៃប្រៃសណីយ៍សម្រាប់ការប្រគល់ត្រឡប់មកវិញ សម្រាប់អ្នកប្រើប្រាស់ដើម្បីប្រគល់សន្លឹកឆ្នោតត្រឡប់មកកាន់ការិយាល័យបោះឆ្នោតរបស់អ្នកវិញ។ អ្នកក៏អាចប្រគល់សន្លឹកឆ្នោតរបស់អ្នកដោយផ្ទាល់ទៅកាន់ការិយាល័យបោះឆ្នោត ប្រអប់សំបុត្រក្នុងទីក្រុង ឬសង្កាត់របស់អ្នក ឬទៅកាន់ទីតាំងបោះឆ្នោតក្នុងសហគមន៍របស់អ្នក។

ប្រសិនបើអ្នកសម្រេចចិត្តមិនបោះឆ្នោតតាមសំបុត្រទេ អ្នកអាចធ្វើការបោះឆ្នោតដោយផ្ទាល់បាន ឱ្យតែសន្លឹកឆ្នោតរបស់អ្នក មិនទាន់ទទួលបាននៅឯការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។ **នៅពេលដែលទទួលសន្លឹកឆ្នោតរបស់អ្នកហើយ អ្នកមិនអាចយកសន្លឹកឆ្នោតនោះមកវិញ ឬបោះឆ្នោតសាជាថ្មីបានទេ។**



សេវាប្រៃសណីយ៍សហរដ្ឋអាមេរិក

ណែនាំឱ្យផ្ញើ សន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ

យ៉ាងហោចណាស់

**7 ថ្ងៃ មុនថ្ងៃបោះឆ្នោត។**

# ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត៖

## ថ្ងៃទី22 ខែតុលា - ថ្ងៃទី4 ខែវិច្ឆិកា



ឆ្នាំនេះ ការបោះឆ្នោតដោយផ្ទាល់មុនថ្ងៃបោះឆ្នោត ត្រូវបានបន្ថែមពេលវេលា។ ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងត្រូវធ្វើឡើងច្រើនជាង 15 ថ្ងៃ ដោយធានាថា នឹងមានម៉ោងសម្រាប់បោះឆ្នោតនៅថ្ងៃចុងសប្តាហ៍ផង។

### នរណា?

អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ដែលមិនទាន់បានបោះឆ្នោតតាមសំបុត្រ អាចធ្វើការបោះឆ្នោតមុនថ្ងៃបោះឆ្នោតដោយផ្ទាល់បាន។ ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ពុំចាំបាច់មានហេតុផលអ្វីនោះទេ។

### នៅពេលណា?

រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងចាប់ផ្តើមនៅថ្ងៃសៅរ៍ ទី22 ខែតុលា ហើយបញ្ចប់ទៅវិញនៅថ្ងៃសុក្រ ទី4 ខែវិច្ឆិកា។ ក្រុង និងសង្កាត់នីមួយៗ ត្រូវផ្តល់ជូនការបោះឆ្នោតមុនថ្ងៃបោះឆ្នោត យ៉ាងតិចមួយទីតាំងដែរ។ នៅចុងសប្តាហ៍ ថ្ងៃទី22-23 ខែតុលា និងថ្ងៃទី29-30 ខែតុលា គ្រប់សហគមន៍ទាំងអស់ត្រូវផ្តល់ការបោះឆ្នោតនៅថ្ងៃចុងសប្តាហ៍ខ្លះ។ ចំនួនម៉ោងដែលសហគមន៍នីមួយៗត្រូវបើកការិយាល័យ អាស្រ័យលើទំហំទីក្រុង ឬសង្កាត់។

សម្គាល់៖ ទីក្រុងនិងសង្កាត់ជាច្រើនមានម៉ោងធ្វើការមានកំណត់នៅថ្ងៃសុក្រ។ សូមកុំភ្លេចពិនិត្យមើលតារាងពេលវេលាសហគមន៍របស់អ្នក នៅ **www.VoteInMA.com** នៅពេលអ្នកមានគម្រោងធ្វើការបោះឆ្នោត។

### ទីណា?

អ្នកអាចធ្វើការបោះឆ្នោតមុនថ្ងៃបោះឆ្នោតនៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត ក្នុងទីក្រុង ឬសង្កាត់ ដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ គ្រប់ទីក្រុងនិងសង្កាត់ទាំងអស់ ត្រូវមានទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោតយ៉ាងតិចមួយ ប៉ុន្តែពួកគេអាចជ្រើសរើសឱ្យច្រើនជាងនេះក៏បាន។ ទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត ត្រូវបានជ្រើសរើសដោយទីក្រុង និងសង្កាត់នីមួយៗ ហើយនឹងត្រូវចុះផ្សាយនៅ **www.VoteInMA.com** យ៉ាងហោចណាស់ 1 សប្តាហ៍មុនពេលការបោះឆ្នោតមុនថ្ងៃបោះឆ្នោតចាប់ផ្តើម។

### របៀបណា?

អ្នកពុំចាំបាច់ធ្វើការណាត់ជួប ឬដាក់ពាក្យសុំធ្វើការបោះឆ្នោតដោយផ្ទាល់មុនថ្ងៃបោះឆ្នោតនោះទេ។ អ្នកគ្រាន់តែទៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោតណាមួយ នៅក្នុងទីក្រុង ឬសង្កាត់របស់អ្នក រួចបោះឆ្នោតដោយផ្ទាល់ជាការស្រេច ដូចអ្នកធ្វើនៅថ្ងៃបោះឆ្នោតដែរ។ បន្ទាប់ពីអ្នកបោះឆ្នោតរួច អ្នកនឹងត្រូវបិទស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នក ចុះហត្ថលេខាបញ្ជាក់នៅលើស្រោមសំបុត្រនោះ ហើយប្រគល់វាទៅមន្ត្រីបោះឆ្នោត។ នៅពេលដែលអ្នកប្រគល់ស្រោមសំបុត្រសន្លឹកឆ្នោតរួច ហើយស្ថានបានទទួលយក ការបោះឆ្នោតរបស់អ្នកសម្រេចរួចរាល់ ហើយអ្នកមិនអាចយកសន្លឹកឆ្នោតនោះមកវិញ ឬបោះឆ្នោតម្តងទៀតបានទេ។

### ចូរចងចាំ៖

ជាទូទៅតែងមានមនុស្សតម្រង់ជួរវែងនៅទីតាំងបោះឆ្នោតនៅថ្ងៃដំបូង និងថ្ងៃចុងក្រោយនៃរយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត។ នៅថ្ងៃចុងសប្តាហ៍ ក៏អាចមានមនុស្សតម្រង់ជួរគ្នាច្រើនដែរ។ សូមលើកទឹកចិត្តឱ្យអ្នកបោះឆ្នោតដែលអាចបោះឆ្នោតក្នុងអំឡុងពេលមនុស្សតិចបាន មកបោះឆ្នោតនៅពេលនេះ។

ករណីភាគច្រើន មានទីតាំងបោះឆ្នោតច្រើននៅទូទាំងក្រុងនិងសង្កាត់នីមួយៗនៅថ្ងៃបោះឆ្នោត ច្រើនជាងទីតាំងដែលមានអំឡុងការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ដែលមានន័យថា ក្នុងពេលនោះអាចចំណាយពេលរង់ចាំតិចជាងនៅកន្លែងបោះឆ្នោតនៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត។

រកមើលតារាងពេលពេលវេលាបោះឆ្នោតមុនថ្ងៃបោះឆ្នោតនៅ **www.VoteInMA.com**
ចាប់ផ្តើមពីថ្ងៃទី14 ខែតុលា ឆ្នាំ2022 តទៅ!

# ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត

អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចទាំងអស់ ដែលមិនបានបោះឆ្នោតតាមសំបុត្រ ឬបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងអាចធ្វើការបោះឆ្នោតដោយផ្ទាល់បាននៅថ្ងៃបោះឆ្នោត នាថ្ងៃទី8 ខែវិច្ឆិកា ឆ្នាំ2022។ ទីតាំងបោះឆ្នោតនៅទូទាំងរដ្ឋម៉ាសាជូសេត នឹងចាប់បើកពីម៉ោង **7 ព្រឹក** ដល់ម៉ោង **8** យប់។

### កន្លែងត្រូវបោះឆ្នោត

នៅថ្ងៃបោះឆ្នោត អ្នកអាចធ្វើការបោះឆ្នោតនៅកន្លែងបោះឆ្នោតដែលបានកំណត់សម្រាប់មណ្ឌលរបស់អ្នក។ មណ្ឌលត្រូវបានចាប់ឆ្នោតជាថ្មីនៅក្នុងក្រុង និងសង្កាត់ ដូច្នេះ លេខមណ្ឌលរបស់អ្នក ឬកន្លែងបោះឆ្នោតរបស់អ្នក អាចផ្លាស់ប្តូរ។

ចូលទៅកាន់ **www.VoteInMA.com** ដើម្បីធ្វើការត្រួតពិនិត្យមណ្ឌល និងកន្លែងបោះឆ្នោតរបស់អ្នកម្តងទៀត នៅមុនពេលអ្នកទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

### ការត្រៀមលក្ខណៈដើម្បីបោះឆ្នោត

នៅដើមខែតុលា អ្នកក៏នឹងអាចចូលទៅមើល **www.VoteInMA.com** ដើម្បីពិនិត្យសន្លឹកឆ្នោតគំរូ ដើម្បីឱ្យអ្នកអាចធ្វើការសម្រេចចិត្តបាន។

អ្នកមានសិទ្ធិក្នុងការយកកំណត់ចំណាំទៅតាមខ្លួន ទៅកាន់កន្លែងបោះឆ្នោត ដើម្បីជួយអ្នកក្នុងការបំពេញសន្លឹកឆ្នោត។ អ្នកមិនត្រូវភ្លេចយកកំណត់ចំណាំ ឬឯកសារណាមួយមកជាមួយអ្នកទេ នៅពេលអ្នកចាកចេញពីកន្លែងបោះឆ្នោត។

### ការត្រួតពិនិត្យមុនចូល

នៅពេលអ្នកទៅដល់កន្លែងបោះឆ្នោតរបស់អ្នក អ្នកនឹងត្រូវបុគ្គលិករៀបចំការបោះឆ្នោតត្រួតពិនិត្យមុនចូល។ ប្រសិនបើមានមនុស្សតម្រង់ជួររង់ចាំនៅតាមមណ្ឌលច្រើនជាងមួយ នៅកន្លែងបោះឆ្នោតរបស់អ្នក ត្រូវប្រាកដថាអ្នកចូលតម្រង់ជួរនៅតាមមណ្ឌលរបស់អ្នក។ អ្នកអាចសាកសួរបុគ្គលិករៀបចំការបោះឆ្នោតឱ្យជួយបាន ប្រសិនបើអ្នកមិនច្បាស់ពីមណ្ឌលរបស់អ្នក ឬអ្នកអាចចូលទៅមើលគេហទំព័រ **www.VoteInMA.com** ដើម្បីស្វែងរកមើលកន្លែងបោះឆ្នោតរបស់អ្នក ដែលក៏នឹងបង្ហាញអ្នកពីលេខបន្ទប់ ឬលេខមណ្ឌលផងដែរ។

នៅពេលអ្នកត្រួតពិនិត្យចូល អ្នកនឹងត្រូវប្រាប់បុគ្គលិករៀបចំការបោះឆ្នោតពីអាសយដ្ឋាននិងឈ្មោះរបស់អ្នក ដើម្បីឱ្យគេអាចរកឈ្មោះអ្នកឃើញនៅលើបញ្ជី។ បុគ្គលិករៀបចំការបោះឆ្នោត ត្រូវបានតម្រូវឱ្យបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកម្តងទៀត មុនពេលគូសឈ្មោះអ្នកនៅលើបញ្ជី និងប្រគល់សន្លឹកឆ្នោតជូនអ្នក។

ប្រសិនបើរកមិនឃើញឈ្មោះរបស់អ្នកនៅលើបញ្ជីទេ អ្នកអាចសុំបុគ្គលិករៀបចំការបោះឆ្នោតឱ្យទាក់ទងទៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន ដើម្បីបញ្ជាក់ពីការចុះឈ្មោះរបស់អ្នក។ ប្រសិនបើការចុះឈ្មោះរបស់អ្នកមិនអាចរកឃើញទេ អ្នកមានសិទ្ធិគូសសន្លឹកឆ្នោតបណ្តោះអាសន្នបាន ដែលនឹងត្រូវរាប់ថាបានការ ប្រសិនបើសិទ្ធិរបស់អ្នកអាចធ្វើការបញ្ជាក់បាន។

ប្រសិនបើអ្នកត្រូវបានតម្រូវឱ្យបង្ហាញឯកសារអត្តសញ្ញាណ គេនឹងសាកសួរអ្នកនៅតុត្រួតពិនិត្យចូល។

### ឯកសារអត្តសញ្ញាណ

គេអាចសុំឱ្យអ្នកបង្ហាញឯកសារអត្តសញ្ញាណ ប្រសិនបើអ្នកជាអ្នកបោះឆ្នោតលើកដំបូងក្នុងរដ្ឋម៉ាសាជូសេត អ្នកជាអ្នកបោះឆ្នោតអសកម្ម ឬមន្ត្រីបោះឆ្នោតមានហេតុផលដទៃទៀតដើម្បីស្នើសុំឯកសារអត្តសញ្ញាណពីអ្នក។

គេពុំបានតម្រូវឱ្យអ្នកបង្ហាញរូបថតឯកសារអត្តសញ្ញាណដើម្បីធ្វើការបោះឆ្នោតឡើយ។ ឯកសារអត្តសញ្ញាណដែលអាចទទួលយកបាន រួមមាន៖

- ប័ណ្ណបើកបរ
- អត្តសញ្ញាណប័ណ្ណរដ្ឋ
- វិក្កយបត្រទឹកភ្លើង
- របាយការណ៍ធនាគារ
- ប័ណ្ណបើកប្រាក់ខែ
- មូលប្បទានបត្ររដ្ឋាភិបាល
- បង្កាន់ដៃជួលនៅលើក្បាលលិខិតរបស់ម្ចាស់ផ្ទះ
- លិខិតពីអន្តេវាសិកដ្ឋាន ឬការិយាល័យលំនៅដ្ឋាននៅលើក្បាលលិខិតរបស់សាលារៀន
- ឯកសារផ្លូវការដទៃផ្សេងទៀត ដែលបង្ហាញពីឈ្មោះ និងអាសយដ្ឋានរបស់អ្នក។

ទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ត្រូវបង្ហាញពីឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។

ប្រសិនបើអ្នកជាអ្នកបោះឆ្នោតអសកម្មដោយសារអ្នកខកខានមិនបានប្រគល់បញ្ជីឈ្មោះផ្លូវការប្រចាំឆ្នាំ ហើយអ្នកមិនអាចបង្ហាញឯកសារអត្តសញ្ញាណបាន នោះអ្នកនៅតែត្រូវបានគេអនុញ្ញាតឱ្យធ្វើការបោះឆ្នោត ដោយគូសលើសន្លឹកឆ្នោតដែលបានតវ៉ា។ សន្លឹកឆ្នោតទាំងនេះត្រូវរាប់ថាបានការនៅថ្ងៃបោះឆ្នោត ហើយត្រូវធ្វើការត្រួតពិនិត្យឡើងវិញ តែក្នុងករណីរាប់សន្លឹកឆ្នោតជាថ្មីប៉ុណ្ណោះ។

ប្រសិនបើអ្នកជាអ្នកបោះឆ្នោតលើកដំបូងក្នុងរដ្ឋម៉ាសាជូសេត ដែលតម្រូវឱ្យបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណតាមច្បាប់ នោះអ្នកនឹងត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតលើសន្លឹកឆ្នោតបណ្តោះអាសន្ន។ អ្នកនឹងត្រូវត្រឡប់មកវិញនៅពេលក្រោយដោយមានយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណរបស់អ្នក ដើម្បីឱ្យសន្លឹកឆ្នោតរបស់អ្នករាប់ថាបានការ។

### ការបោះឆ្នោត

នៅពេលអ្នកមានសន្លឹកឆ្នោតរបស់អ្នក អ្នកអាចទៅកាន់បន្ទប់សម្ងាត់ដើម្បីគូសសន្លឹកឆ្នោតតែម្នាក់ឯង។ ប្រសិនបើអ្នកយកកូនមកជាមួយ គេអនុញ្ញាតឱ្យអ្នកយកកូនៗរបស់អ្នកចូលក្នុងបន្ទប់សម្ងាត់ជាមួយអ្នកបាន។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការគូសសន្លឹកឆ្នោត ដោយសារបញ្ហាពិការភាព ឬដោយសារអសមត្ថភាពក្នុងការអានសន្លឹកឆ្នោតរបស់អ្នក អ្នកអាចជ្រើសរើសមនុស្សណាម្នាក់ឱ្យអមដំណើរអ្នកចូលក្នុងបន្ទប់សម្ងាត់ដើម្បីជួយអ្នកបាន។

ប្រសិនបើចង់គូសសន្លឹកឆ្នោតដោយខ្លួនឯង អ្នកអាចប្រើម៉ាស៊ីនជំនួយអ្នកបោះឆ្នោតដែលគូសសន្លឹកឆ្នោតដោយស្វ័យប្រវត្តិ ដែលមានផ្តល់ជូននៅគ្រប់កន្លែងបោះឆ្នោតទាំងអស់។ ម៉ាស៊ីននេះនឹងអានសន្លឹកឆ្នោតឱ្យអ្នកស្តាប់ ពង្រីកសន្លឹកឆ្នោត និងជួយអ្នកក្នុងការគូសសន្លឹកឆ្នោត។

ប្រសិនបើអ្នកពុំចង់ប្រើការគូសសន្លឹកឆ្នោតដោយស្វ័យប្រវត្តិ ហើយអ្នកពុំបាននាំនរណាម្នាក់ទៅជាមួយដើម្បីជួយអ្នក អ្នកក៏អាចស្នើសុំជំនួយពីបុគ្គលិករៀបចំការបោះឆ្នោតពីរនាក់ក្នុងការគូសសន្លឹកឆ្នោតរបស់អ្នកបានផងដែរ។

### ការគូសសន្លឹកឆ្នោតរបស់អ្នក

បន្ទាប់ពីអ្នកបានជ្រើសរើសរួច អ្នកអាចត្រូវការបន្តដំណើរទៅកាន់តុត្រួតពិនិត្យចេញ។ ប្រសិនបើកន្លែងបោះឆ្នោតរបស់អ្នកពុំមានតុត្រួតពិនិត្យចេញទេ អ្នកនឹងត្រូវបន្តដំណើរដោយផ្ទាល់ទៅកាន់ហិបឆ្នោតតែម្តង។

កន្លែងបោះឆ្នោតរបស់អ្នកអាចប្រើម៉ាស៊ីនតម្រៀបសន្លឹកឆ្នោតអេឡិចត្រូនិកដើម្បីរាប់សន្លឹកឆ្នោត ឬប្រើហិបឆ្នោតស៊កសន្លឹកឆ្នោតដោយផ្ទាល់ដៃ។

# *សំណួរដែលបានសាកសួរជាញឹកញាប់*

## ការបោះឆ្នោតតាមសំបុត្រ

### តើខ្ញុំត្រូវបោះឆ្នោតតាមសំបុត្រមែនទេ?

អត់ទេ។ ការបោះឆ្នោតដោយផ្ទាល់ គឺនៅតែមានសម្រាប់អ្នកដែលពុំចង់បោះឆ្នោតតាមសំបុត្រដដែល។

### តើខ្ញុំត្រូវដាក់ពាក្យស្នើសុំឆាប់ប៉ុណ្ណា?

បានឆាប់តាមដែលអាចធ្វើទៅបាន! ពាក្យស្នើសុំរបស់អ្នកត្រូវទៅដល់ការិយាល័យបោះឆ្នោតត្រឹមថ្ងៃទី1 ខែវិច្ឆិកា ប៉ុន្តែសំបុត្រអាចចំណាយពេលរហូតដល់ 1 សប្តាហ៍ដើម្បីប្រគល់ជូន ដូច្នេះ កាលណាអ្នកដាក់ពាក្យកាន់តែឆាប់ អ្នកកាន់តែមានពេលវេលាច្រើនក្នុងការប្រគល់សន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ និងប្រាកដថាសន្លឹកឆ្នោតនោះត្រូវបានរាប់។

### ប្រសិនបើខ្ញុំបានស្នើសុំការបោះឆ្នោតតាមសំបុត្រ តើខ្ញុំអាចផ្លាស់ប្តូរទៅបោះឆ្នោតដោយផ្ទាល់វិញបានដែរឬទេ?

នៅពេលដែលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកបានទទួលសន្លឹកឆ្នោតរបស់អ្នករួចហើយ អ្នកមិនអាចដកយកសន្លឹកឆ្នោតនោះមកវិញ ឬបោះឆ្នោតសាជាថ្មីបានទេ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបោះឆ្នោតតាមសំបុត្រ ប៉ុន្តែពុំបានប្រគល់សន្លឹកឆ្នោតនោះត្រឡប់ទៅឱ្យមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកវិញទេ អ្នកអាចបោះឆ្នោតដោយផ្ទាល់បានក្នុងអំឡុង រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោតបាន។

### តើការបោះឆ្នោតតាមសំបុត្រមានសុវត្ថិភាពដែរឬទេ?

មាន។ មុនពេលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកអាចផ្ញើសន្លឹកឆ្នោតទៅអ្នកបាន ពួកគេត្រូវតែធ្វើការបញ្ជាក់ថា អ្នកជាអ្នកបោះឆ្នោត ហើយបានកត់ត្រាពាក្យស្នើសុំរបស់អ្នកទុក។ នៅពេលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកទទួលបានសន្លឹកឆ្នោត ពួកគេនឹងគូសធីក ដើម្បីប្រាកដថា អ្នកបានចុះហត្ថលេខាលើស្រោមសំបុត្រ និងបានប្រៀបធៀបហត្ថលេខានោះជាមួយនឹងហត្ថលេខាដែលអ្នកមាននៅលើឯកសារ។ ចំណុចនេះសំខាន់ណាស់ ដោយសារសន្លឹកឆ្នោតត្រូវតែធ្វើការបដិសេធ ប្រសិនបើពុំបានចុះហត្ថលេខាលើសន្លឹកឆ្នោតទេ។ ប្រសិនបើគេបានទទួលយកសន្លឹកឆ្នោតរបស់អ្នករួចហើយ អ្នកនឹងត្រូវគូសចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ហើយសន្លឹកឆ្នោតរបស់អ្នកនឹងត្រូវមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នករក្សាទុកយ៉ាងមានសុវត្ថិភាព រហូតដល់អាចរាប់សន្លឹកឆ្នោតនោះបាន។

### តើកាលបរិច្ឆេទផុតកំណត់នៃការប្រគល់សន្លឹកឆ្នោតរបស់ខ្ញុំត្រឡប់ទៅវិញចំថ្ងៃណា?

ដើម្បីអាចរាប់សន្លឹកឆ្នោតរបស់អ្នកបាន សន្លឹកឆ្នោតនោះត្រូវមានវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី**8** ខែវិច្ឆិកា ឆ្នាំ**2022** ហើយទទួលបានមិនលើសពីថ្ងៃទី**12** ខែវិច្ឆិកា ឆ្នាំ**2022** ឡើយ។ សេវាប្រៃសណីយ៍ សូមណែនាំឱ្យផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញយ៉ាងហោចណាស់មួយសប្តាហ៍ មុនថ្ងៃបោះឆ្នោត។

### តើខ្ញុំអាចឆែកមើលថាតើគេបានទទួលសន្លឹកឆ្នោតរបស់ខ្ញុំដោយវិធីណា?

អ្នកអាចឆែកមើលស្ថានភាពសន្លឹកឆ្នោតរបស់អ្នកតាមអនឡាញ នៅ **www.VoteInMA.com**។ វានឹងបង្ហាញថាតើពាក្យស្នើសុំរបស់អ្នកបានទទួលហើយឬនៅ បង្ហាញពីកាលបរិច្ឆេទដែលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានបានផ្ញើសន្លឹកឆ្នោតទៅអ្នក និងកាលបរិច្ឆេទដែលសន្លឹកឆ្នោតរបស់អ្នកបានមកដល់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន។

### តើការបោះឆ្នោតតាមសំបុត្រទាំងអស់ សុទ្ធតែត្រូវរាប់ចំនួនមែនទេ?

រាល់សន្លឹកឆ្នោតដែលបានទទួលទាន់ពេលវេលា នឹងត្រូវរាប់ចំនួន ប្រសិនបើសន្លឹកឆ្នោតនោះបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ។ សូមកុំភ្លេចចុះហត្ថលេខាលើស្រោមសន្លឹកឆ្នោតរបស់អ្នក ដើម្បីឱ្យសន្លឹកឆ្នោតរបស់អ្នកអាចរាប់ជាបានការ! ការរាប់សន្លឹកឆ្នោត គឺមានតម្លាភាព និងបើកទូលាយសម្រាប់ការអង្កេតពីសាធារណជន។

## ការបោះឆ្នោតដោយផ្ទាល់

### តើពេលណាទើបខ្ញុំអាចបោះឆ្នោតដោយផ្ទាល់បាន?

អ្នកអាចធ្វើការបោះឆ្នោតដោយផ្ទាល់បានក្នុងអំឡុង រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត។ រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងចាប់ផ្តើមនៅ
ថ្ងៃទី**22** ខែតុលា ហើយបញ្ចប់ទៅវិញនៅថ្ងៃទី**4** ខែវិច្ឆិកា។ អ្នកអាចពិនិត្យមើលកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង នៅ **www.VoteInMA.com**។

នៅថ្ងៃបោះឆ្នោតនាថ្ងៃទី**8** ខែវិច្ឆិកា កន្លែងបោះឆ្នោតនឹងត្រូវបើកចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់។ សូមចូលទៅកាន់ **www.VoteInMA.com** ដើម្បីរកមើលកន្លែងបោះឆ្នោតរបស់អ្នក។ អ្នកក៏អាចទូរស័ព្ទទៅកាន់អង្គភាពបោះឆ្នោតតាមរយៈលេខ 1-800-462- VOTE (8683) ដើម្បីរកជំនួយក្នុងការស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក។

### តើខ្ញុំអាចស្វែងយល់ពីមុខតំណែង និងបេក្ខជនណាខ្លះដែលមាននៅលើសន្លឹកឆ្នោតបានដោយរបៀបណា?

សន្លឹកឆ្នោតគំរូ ក៏ដូចជាប័ណ្ណណែនាំ ត្រូវបានបិទផ្សាយនៅតាមកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ អ្នកក៏នឹងអាចពិនិត្យមើលសន្លឹកឆ្នោតគំរូបានផងដែរនៅ **www.VoteInMA.com** ក្នុងខែតុលា។

### ខ្ញុំបានចុះឈ្មោះបោះឆ្នោតហើយ ប៉ុន្តែខ្ញុំគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

ប្រសិនបើអ្នកចុះឈ្មោះបោះឆ្នោត ប៉ុន្តែឈ្មោះរបស់អ្នកមិនមាននៅលើបញ្ជីបោះឆ្នោត សូមសុំមន្ត្រីបោះឆ្នោតដែលទទួលខុសត្រូវនៅកន្លែងបោះឆ្នោត ឱ្យឆែកមើលការបោះឆ្នោតរបស់អ្នកជាមួយស្មៀនក្រុង ឬសង្កាត់ ដើម្បីចង់ដឹងថាតើអ្នកបានចុះឈ្មោះក្នុងមណ្ឌលផ្សេងនៅក្នុងក្រុងនោះឬអត់។ ប្រសិនបើពួកគេនៅតែពុំអាចរកឈ្មោះអ្នកឃើញទៀត អ្នកអាចបោះឆ្នោតលើសន្លឹកឆ្នោតបណ្តោះអាសន្នបាននៅកន្លែងបោះឆ្នោត។ បន្ទាប់ពីការបោះឆ្នោត មន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន នឹងស្វែងរកកំណត់ត្រាដើម្បីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតរបស់អ្នក។ ប្រសិនបើបញ្ជាក់ពីការចុះឈ្មោះរបស់អ្នករួចហើយ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវរាប់ថាបានការ។ ប្រសិនបើសិទ្ធិរបស់អ្នកមិនអាចបញ្ជាក់បានទេ សន្លឹកឆ្នោតរបស់អ្នកនឹងនៅបន្តបិទនៅក្នុងស្រោមសំបុត្រដដែល។

### ចុះបើខ្ញុំធ្វើខុសនៅលើសន្លឹកឆ្នោតវិញ តើខ្ញុំត្រូវធ្វើដូចម្តេច?

ប្រសិនបើអ្នកធ្វើខុសនៅលើសន្លឹកឆ្នោត អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីបាន។ អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីបានរហូតដល់ទៅពីរ។

### តើខ្ញុំអាចយកឯកសារទៅកន្លែងបោះឆ្នោតបានដែរឬទេ?

បាន អ្នកអាចយកឯកសារចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតបាន។ អ្នកអាចយកខិត្តប័ណ្ណព្រីនស្រេច ឬខិត្តប័ណ្ណ ឬកំណត់ត្រាផ្ទាល់ខ្លួនរបស់អ្នកមកជាមួយបាន ប៉ុន្តែអ្នកមិនអាចបង្ហាញឯកសារទាំងនោះ នៅពេលស្ថិតក្នុងកន្លែងបោះឆ្នោតបានឡើយ។ អ្នកត្រូវយកកំណត់ចំណាំ ឬឯកសារណាមួយមកជាមួយអ្នកវិញ នៅពេលអ្នកចាកចេញពីបន្ទប់គូសសន្លឹកបោះឆ្នោត។

# សុវត្ថិភាពនៃការបោះឆ្នោត

ការបោះឆ្នោតក្នុងរដ្ឋម៉ាសាជូសេត មានសុវត្ថិភាព អាចផ្ទៀងផ្ទាត់បាន និងមានតម្លាភាព ។ ដោយមានការផ្លាស់ប្ដូរក្នុងពេលថ្មីៗនេះទៅលើច្បាប់បោះឆ្នោតរបស់យើង អ្នកអាចមានសំណួរខ្លះអំពីការរក្សាសុវត្ថិភាពនៅនឹងកន្លែង ដើម្បីធានាថា ការបោះឆ្នោតទាំងអស់ត្រូវបានរាប់ចំនួនស្របតាមច្បាប់និងត្រឹមត្រូវ។

### ដានក្រដាសដែលអាចផ្ទៀងផ្ទាត់បាន

ក្នុងរដ្ឋម៉ាសាជូសេត អ្នកបោះឆ្នោតទាំងអស់ បោះឆ្នោតលើសន្លឹកឆ្នោត។ សន្លឹកឆ្នោតអាចរាប់តាមម៉ាស៊ីនរាប់សន្លឹកឆ្នោតអេឡិចត្រូនិក ឬតាមរយៈបុគ្គលិករៀបចំការបោះឆ្នោត ដែលបូកសរុបលទ្ធផលបោះឆ្នោតដោយដៃ។

មិនថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានគេរាប់ដោយវិធីណានោះទេ បុគ្គលិករៀបចំការបោះឆ្នោត កត់ត្រាសំឡេងឆ្នោតនៅលើសន្លឹករាប់សន្លឹកឆ្នោត នៅកន្លែងបោះឆ្នោតនីមួយៗ ក្រោយពេលបិទបញ្ចប់ការបោះឆ្នោត។ ការរាប់សន្លឹកឆ្នោតទាំងអស់ និងការបូកសរុបលទ្ធផល ធ្វើឡើងនៅកន្លែងសាធារណៈ ដែលមានការស្វាគមន៍ឱ្យមនុស្សគ្រប់គ្នាចូលរួមអង្កេតក្នុងដំណើរការនេះ។

ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាននីមួយៗ ប្រើប្រាស់សន្លឹកបូកសរុបលទ្ធផល ដើម្បីប្រមូលផ្ដុំជាលទ្ធផលមិនផ្លូវការ។ លទ្ធផលបោះឆ្នោតអាចរាប់ជាផ្លូវការបាន ក្រោយពីបានត្រួតពិនិត្យល្អិតល្អន់ ដោយបានបញ្ជាក់ពីមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន ដោយបានរាយការណ៍ទៅកាន់ការិយាល័យលេខាធិការខំមិនវែល និងបានបញ្ជាក់ជាថ្មីដោយអភិបាល និងគណៈអភិបាល។

បេក្ខជនតែងមានសិទ្ធិក្នុងការដាក់ញត្តិឱ្យមានការរាប់សន្លឹកឆ្នោតដោយដៃសាជាថ្មី ដើម្បីផ្ទៀងផ្ទាត់ថា ការរាប់សន្លឹកឆ្នោតជាផ្លូវការ ពិតជាត្រឹមត្រូវប្រាកដមែន។

### ម៉ាស៊ីនរាប់សន្លឹកឆ្នោត

រាល់ ម៉ាស៊ីនរាប់សន្លឹកឆ្នោតទាំងអស់ក្នុងរដ្ឋម៉ាសាជូសេត ត្រូវបានបញ្ជាក់សម្រាប់ប្រើប្រាស់ដោយគណៈកម្មាធិការជំនួយការបោះឆ្នោតរបស់សហព័ន្ធ និងលេខាធិការខំមិនវែល។

នៅមុនពេលការបោះឆ្នោតម្ដងៗ មន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន ត្រូវរៀបចំការធ្វើតេស្តភស្តុភារកម្ម និងភាពត្រឹមត្រូវនៃម៉ាស៊ីនរាប់សន្លឹកឆ្នោត ដែលនឹងត្រូវប្រើប្រាស់នៅក្នុងការបោះឆ្នោត។ ម៉ាស៊ីននីមួយៗត្រូវបានធ្វើតេស្តរួច ដើម្បីប្រាកដថា ម៉ាស៊ីននោះរាប់សន្លឹកឆ្នោតបានត្រឹមត្រូវ។ កាលបរិច្ឆេទ ពេលវេលា និងទីតាំងធ្វើតេស្ត ត្រូវបានបិទផ្សាយជាសាធារណៈ ហើយសាធារណជន ត្រូវបានស្វាគមន៍ឱ្យធ្វើអង្កេត។ គណៈកម្មការគណបក្សក្នុងមូលដ្ឋាន ក៏ត្រូវបានអញ្ជើញឱ្យចូលរួមអង្កេតការធ្វើតេស្តឧបករណ៍បោះឆ្នោតផងដែរ។

មានតែម៉ាស៊ីនរាប់សន្លឹកឆ្នោតប៉ុណ្ណោះដែលត្រូវបញ្ជាក់សម្រាប់ការប្រើប្រាស់នៅក្នុងរដ្ឋម៉ាសាជូសេត។ គ្មានម៉ាស៊ីនរាប់សន្លឹកឆ្នោតណាក្នុងរដ្ឋម៉ាសាជូសេត ត្រូវភ្ជាប់ទៅនឹងអ៊ីនធឺណិតឡើយ។

### ការបោះឆ្នោតតាមសំបុត្រ

ការបោះឆ្នោតតាមសំបុត្ររបស់អ្នក នឹងត្រូវត្រួតពិនិត្យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពីសន្លឹកឆ្នោតនោះបានមកដល់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន។ មន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក នឹងបើកស្រោមសំបុត្រប្រៃសណីយ៍ពីខាងក្រៅ និងពិនិត្យមើលសន្លឹកឆ្នោតនៅខាងក្នុងស្រោមសំបុត្រ រកមើលហត្ថលេខារបស់អ្នក។ ហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោត នឹងត្រូវយកមកផ្ទៀងផ្ទាត់ជាមួយហត្ថលេខានៅលើឯកសារនៅការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។

ប្រសិនបើស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នក មានចុះហត្ថលេខា ហើយត្រូវបានទទួលយក នោះមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន នឹងឆូតឈ្មោះរបស់អ្នកនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីកុំឱ្យអ្នកអាចបោះឆ្នោតបានម្ដងទៀត។ បញ្ជីឈ្មោះអ្នកបោះឆ្នោតដែល



ប្រើនៅកន្លែងបោះឆ្នោតរបស់អ្នក នឹងបង្ហាញថា អ្នកបានបោះឆ្នោតរួចហើយ។

ប្រសិនបើសន្លឹកឆ្នោតរបស់អ្នក មិនត្រូវបានទទួលយកទេ គេនឹងជូនដំណឹងទៅអ្នកថា សន្លឹកឆ្នោតរបស់អ្នកត្រូវបានបដិសេធ ហើយអ្នកនឹងនៅតែអាចបោះឆ្នោតដោយផ្ទាល់បានដដែល។ ប្រសិនបើនៅមានពេល គេនឹងផ្ញើសន្លឹកឆ្នោតជំនួសថ្មីមួយសន្លឹកទៅអ្នក ដើម្បីប្រើក្នុងការបោះឆ្នោតតាមសំបុត្រ។

សន្លឹកឆ្នោតដែលបានផ្ញើចូល ត្រូវបានពិនិត្យផ្ទៀងផ្ទាត់នឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅមុនពេលរាប់សន្លឹកឆ្នោតនោះ។ ការធ្វើបែបនេះ គឺដើម្បីបង្ការកុំឱ្យអ្នកបោះឆ្នោតណាមួយធ្វើការបោះឆ្នោតច្រើនជាងមួយលើក។ សន្លឹកឆ្នោតដែលបានផ្ញើចូល ដែលមកដល់បន្ទាប់ពីនរណាម្នាក់បានបោះឆ្នោតដោយផ្ទាល់រួច នឹងត្រូវបដិសេធចោល នៅពេលត្រួតពិនិត្យសន្លឹកឆ្នោតនោះ។

### ការរាប់សន្លឹកឆ្នោត

នៅពេលអ្នកបោះឆ្នោតដោយផ្ទាល់នៅកន្លែងបោះឆ្នោត អ្នកត្រូវដាក់សន្លឹកឆ្នោតនោះដោយផ្ទាល់ចូលទៅក្នុងហិបឆ្នោតដែលចាក់សោ នៅទីនោះ សន្លឹកឆ្នោតត្រូវរក្សាទុករហូតដល់បិទបញ្ចប់ការបោះឆ្នោត។ សន្លឹកឆ្នោតដែលស៊កចូលទៅក្នុងម៉ាស៊ីនរាប់សន្លឹកឆ្នោត ត្រូវបានរាប់ចំនួននៅពេលដែលអ្នកស៊កសន្លឹកឆ្នោតចូល ចំណែកសន្លឹកឆ្នោតដែលបានស៊កចូលទៅក្នុងហិបឆ្នោតដទៃ នឹងត្រូវរាប់នៅក្នុងកន្លែងបោះឆ្នោត បន្ទាប់ពីបិទបញ្ចប់ការបោះឆ្នោត។

នៅពេលដែលអ្នកបោះឆ្នោតមុនថ្ងៃបោះឆ្នោតដោយផ្ទាល់ ឬបោះឆ្នោតតាមសំបុត្រ អ្នកដាក់សន្លឹកឆ្នោតចូលទៅក្នុងស្រោមសំបុត្រសន្លឹកឆ្នោត ដែលត្រូវរក្សាទុកក្នុងស្រោមសំបុត្របិទជិតនិងមានសុវត្ថិភាពរហូតដល់ពេលដែលអាចរាប់ចំនួនបាន។ សន្លឹកឆ្នោតមិនអាចគ្មានបិទស្រោមសំបុត្រជិតនោះទេ រហូតដល់ម៉ោងត្រូវរាប់សន្លឹកឆ្នោតបានចាប់ផ្ដើម។

រាល់សន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់ចំនួនជាសាធារណៈ មិនថានៅកន្លែងរាប់សន្លឹកឆ្នោតកណ្ដាល ឬនៅកន្លែងបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោតនោះទេ។ នៅមុនពេលរាប់សន្លឹកឆ្នោតបោះមុនថ្ងៃបោះឆ្នោត ឬសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោត ឈ្មោះនិងអាសយដ្ឋាននៅលើស្រោមសំបុត្រ ត្រូវអានឮៗ ហើយឈ្មោះអ្នកបោះឆ្នោត ត្រូវឆូតចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត។

អ្នកសង្កេតការត្រូវបានស្វាគមន៍ឱ្យចូលរួមក្នុងម៉ោងរាប់សន្លឹកឆ្នោត ដែលត្រូវបិទផ្សាយជាសាធារណៈដោយមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។ សន្លឹកឆ្នោតណាមួយដែលមិនត្រូវបានរាប់ចំនួននៅកន្លែងរាប់សន្លឹកឆ្នោតកណ្ដាល ត្រូវផ្ញើទៅកាន់កន្លែងបោះឆ្នោតដែលសមស្រប ដើម្បីបញ្ចូលទៅក្នុងហិបឆ្នោតនៅថ្ងៃបោះឆ្នោត។

អ្នកសង្កេតការក៏ស្វាគមន៍ឱ្យចូលរួមនៅកន្លែងបោះឆ្នោតដើម្បីមើលដំណើរការនៃការបោះឆ្នោត និងដំណើរការនៃការរាប់សន្លឹកឆ្នោត រហូតដល់ជិតពាក់កណ្ដាលអាធ្រាត្រ

។ អ្នកសង្កេតការមិនត្រូវរំខានដល់ដំណើរការនៃការបោះឆ្នោតឡើយ ហើយត្រូវអង្កេតពីកន្លែងទីតាំងដែលបានកំណត់នៅខាងក្រៅនៃតំបន់បោះឆ្នោត។

**លទ្ធផលបោះឆ្នោត**

សម្រាប់ការបោះឆ្នោតរបស់រដ្ឋនាថ្ងៃទី8 ខែវិច្ឆិកា ឆ្នាំ2022 លទ្ធផលបោះឆ្នោតមិនផ្លូវការដែលបានរាយការណ៍នៅយប់ថ្ងៃបោះឆ្នោត នឹងត្រូវរួមបញ្ចូលនូវចំនួនសន្លឹកឆ្នោតដែលបានរាប់ចំនួនទាំងអស់មកដល់ថ្ងៃទី8 នេះដែរ។ លទ្ធផលទាំងនោះ នឹងរួមបញ្ចូលនូវ៖

- រាល់សន្លឹកឆ្នោតទាំងអស់ដែលបានបោះឆ្នោតក្នុងអំឡុងរយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត
- រាល់សន្លឹកឆ្នោតផ្ញើចូលទាំងអស់ដែលបានប្រគល់ត្រឡប់មកវិញត្រឹមថ្ងៃទី7 ខែវិច្ឆិកា
- រាល់សន្លឹកឆ្នោតទាំងអស់ដែលបានបោះដោយផ្ទាល់នៅថ្ងៃបោះឆ្នោត។

សន្លឹកឆ្នោតដែលបានប្រគល់ត្រឡប់មកវិញតាមប្រៃសណីយ៍ ឬប្រអប់ទម្លាក់សន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោត នឹងត្រូវផ្ញើទៅកាន់ការិយាល័យរៀបចំការបោះឆ្នោតដើម្បីត្រួតពិនិត្យដើម្បីឱ្យគេអាចពិនិត្យមើលហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោត ហើយអាចផ្ទៀងផ្ទាត់ជាមួយបញ្ជីឈ្មោះអ្នកបោះឆ្នោតបាន។

សន្លឹកឆ្នោតផ្ញើចូលដែលមកដល់នៅថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2022 នឹងត្រូវរាប់បាន លុះត្រាតែសន្លឹកឆ្នោតនោះត្រូវបានវាយត្រាប្រៃសណីយ៍នៅត្រឹមថ្ងៃបោះឆ្នោត។

បន្ទាប់ពីបានប្រគល់បញ្ជីឈ្មោះអ្នកបោះឆ្នោតពីកន្លែងបោះឆ្នោតទៅកាន់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានហើយ មន្ត្រីរៀបចំការបោះឆ្នោតនឹងពិនិត្យមើលសន្លឹកឆ្នោតដែលបានមកដល់នៅថ្ងៃ ឬក្រោយថ្ងៃបោះឆ្នោត ដោយផ្ទៀងផ្ទាត់ជាមួយបញ្ជីឈ្មោះនោះ ដើម្បីកំណត់ថាតើអ្នកដែលបានប្រគល់សន្លឹកឆ្នោតត្រឡប់មកវិញនោះ បានបោះឆ្នោតដោយផ្ទាល់ហើយឬនៅ។ សន្លឹកឆ្នោតពីបុគ្គលដែលបានបោះឆ្នោតរួចហើយ នឹងត្រូវបដិសេធចោល។

សន្លឹកឆ្នោតដែលបានទទួលនៅថ្ងៃ ឬក្រោយថ្ងៃបោះឆ្នោត នឹងត្រូវរាប់ចំនួនក្នុងអំឡុងម៉ោងរាប់សន្លឹកឆ្នោតជាសាធារណៈ ដែលត្រូវធ្វើឡើងក្រោយម៉ោង 5 ល្ងាច នៅថ្ងៃទី12 ខែវិច្ឆិកា។ តារាងលទ្ធផលបោះឆ្នោត នឹងត្រូវធ្វើការកែប្រែដើម្បីឆ្លុះបញ្ចាំងពីសន្លឹកឆ្នោតបន្ថែមទាំងនោះ នៅមុនពេលលទ្ធផលបោះឆ្នោតអាចក្លាយជាលទ្ធផលផ្លូវការបាន។

## *ធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត!*

វិធីដ៏ល្អមួយដែលអ្នកអាចជួយធានាថា រដ្ឋម៉ាសាជូសេតរៀបចំការបោះឆ្នោតប្រកបដោយជោគជ័យបាននៅក្នុងឆ្នាំនេះ គឺតាមរយៈការលះបង់ពេលវេលារបស់អ្នកធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត។

បុគ្គលិករៀបចំការបោះឆ្នោត ត្រូវការជាចាំបាច់នៅទូទាំងខំមិនវែលនៅថ្ងៃទី8 ខែវិច្ឆិកា ហើយសហគមន៍ភាគច្រើន ក៏នឹងត្រូវការបុគ្គលិកដើម្បីជួយដល់ការបោះឆ្នោតមុនថ្ងៃបោះឆ្នោតផងដែរ។

បុគ្គលិករៀបចំការបោះឆ្នោត ត្រូវបានមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានជួលឱ្យជួយត្រួតពិនិត្យចូលសម្រាប់អ្នកបោះឆ្នោត បូកសរុបសំឡេងឆ្នោត និងជួយអ្នកបោះឆ្នោតនៅកន្លែងបោះឆ្នោត។

ជាទូទៅ បុគ្គលិករៀបចំការបោះឆ្នោតត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនៅខំមិនវែល ក៏ប៉ុន្តែ មានបុគ្គលិករៀបចំការបោះឆ្នោតរហូតដល់ 2 ក្នុងមួយមណ្ឌល ដែលអាចមានអាយុពី 16 ឬ 17 ឆ្នាំ។

ប្រសិនបើអ្នកអាចលះបង់ពេលវេលាធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត សូមចូលទៅកាន់គេហទំព័រអង្គភាពរៀបចំការបោះឆ្នោត **www.VoteInMA.com** ដើម្បីស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកដែលអ្នកចង់ធ្វើការជាមួយ។ អ្នកពុំចាំបាច់ត្រូវតែជាពលរដ្ឋក្នុងទីក្រុង ឬសង្កាត់ ដើម្បីអាចក្លាយជាបុគ្គលិករៀបចំការបោះឆ្នោតនៅក្នុងក្រុងឬសង្កាត់នោះទេ។



## *អ្នកបោះឆ្នោតជាមន្ត្រីយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស*

ក្នុងរដ្ឋម៉ាសាជូសេត សមាជិកផ្តល់សេវាកម្មមានឯកសណ្ឋានដែលកំពុងកាន់ភារកិច្ច ក្រុមគ្រួសាររបស់ពួកគេ ពលរដ្ឋអាមេរិកដែលរស់នៅក្រៅប្រទេស សុទ្ធតែមានសិទ្ធិក្នុងការបោះឆ្នោតទាំងអស់។ អ្នកបោះឆ្នោតទាំងនេះ ពុំបានចាំបាច់ត្រូវចុះឈ្មោះបោះឆ្នោតដើម្បីស្នើសុំសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតនោះទេ។ សន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោត អាចស្នើសុំបានដោយប្រើពាក្យស្នើសុំប័ណ្ណប្រៃសណីយ៍របស់សហព័ន្ធ ឬទម្រង់នៃការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរណាមួយ។ សមាជិកគ្រួសារក៏អាចស្នើសុំឱ្យផ្ញើសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតទៅកាន់អ្នកបោះឆ្នោតបានផងដែរ។

អ្នកបោះឆ្នោតទាំងនេះ អាចស្នើសុំឱ្យផ្ញើសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតទៅកាន់ពួកគេតាមប្រៃសណីយ៍ ទូរសារ ឬអ៊ីម៉ែលបាន។ សន្លឹកឆ្នោតក៏អាចប្រគល់ត្រឡប់មកកាន់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានតាមវិធីណាមួយដែលបានរៀបរាប់នេះផងដែរ។

រដ្ឋម៉ាសាជូសេត ក៏អនុញ្ញាតឱ្យមន្ត្រីយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស ធ្វើការបោះឆ្នោតដោយអវត្តមានអ្នកបោះឆ្នោតនៅគ្រប់ការបោះឆ្នោតបានផងដែរ ដោយប្រើសន្លឹកឆ្នោតបំពេញចូលដែលបោះដោយអវត្តមានអ្នកបោះឆ្នោតរបស់សហព័ន្ធ (FWAB)។ សន្លឹកឆ្នោត FWAB អាចប្រើដើម្បីបោះឆ្នោតបានគ្រប់ពេលនៅពេលការបោះឆ្នោត ទោះបីជាអ្នកបោះឆ្នោតមិនបានដាក់ពាក្យស្នើសុំសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតក៏ដោយ។ បន្ទាប់ពីបោះឆ្នោតលើសន្លឹកឆ្នោត FWAB រួច អ្នកបោះឆ្នោតអាចប្រគល់សន្លឹកឆ្នោតនោះតាមប្រៃសណីយ៍ ឬតាមអេឡិចត្រូនិក។ ទាំងពាក្យស្នើសុំប័ណ្ណប្រៃសណីយ៍របស់សហព័ន្ធ ទាំងសន្លឹកឆ្នោតបំពេញចូលដែលបោះដោយអវត្តមានអ្នកបោះឆ្នោតរបស់សហព័ន្ធ សុទ្ធតែអាចស្វែងរកបាននៅលើគេហទំព័រនៃកម្មវិធីជំនួយការបោះឆ្នោតរបស់សហព័ន្ធ **www.FVAP.gov**។

# កម្រងសិទ្ធិអ្នកបោះឆ្នោតនៃរដ្ឋម៉ាសាជូសេត

សិទ្ធិក្នុងការបោះឆ្នោតរបស់អ្នក ត្រូវបានការពារ។ សិទ្ធិទាំងអស់នេះត្រូវបានធានាចំពោះអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

1. អ្នកមានសិទ្ធិក្នុងការបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

2. អ្នកមានសិទ្ធិគូសសន្លឹកឆ្នោតរបស់អ្នកក្នុងលក្ខណៈដែលធានានូវការសម្ងាត់ផ្ទាល់ខ្លួន។ អ្នកមានសិទ្ធិក្នុងការបោះឆ្នោត ដោយពុំមានបុគ្គលណាម្នាក់ព្យាយាមជះឥទ្ធិពលលើការបោះឆ្នោតរបស់អ្នក ហើយមានសិទ្ធិក្នុងការបោះឆ្នោតក្នុងប្រអប់គូសសន្លឹកឆ្នោតដែលបង្ការមិនឱ្យអ្នកដទៃណាម្នាក់មើលអ្នកគូសសន្លឹកឆ្នោតឡើយ។

3. អ្នកមានសិទ្ធិក្នុងការស្ថិតនៅក្នុងបន្ទប់គូសសន្លឹកឆ្នោតចំនួនប្រាំ (5) នាទី ប្រសិនបើមានអ្នកដទៃរង់ចាំ និងអាចស្ថិតនៅទីនោះបានដប់ (10) នាទី ប្រសិនបើគ្មានអ្នករង់ចាំទេ។

4. អ្នកមានសិទ្ធិទទួលបានសន្លឹកឆ្នោតប្តូរថ្មីរហូតដល់ពីរ (2) សន្លឹក ប្រសិនបើអ្នកធ្វើខុស ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

5. អ្នកមានសិទ្ធិស្នើសុំជំនួយនៅពេលបោះឆ្នោត ពីបុគ្គលណាម្នាក់តាមជម្រើសរបស់អ្នក។ ប្រសិនបើអ្នកមិនបាននាំអ្នកណាមកជាមួយទេ អ្នកមានសិទ្ធិស្នើសុំបុគ្គលិករៀបចំការបោះឆ្នោតចំនួនពីរ (2) នាក់ ដើម្បីជួយអ្នក។

6. អ្នកមានសិទ្ធិក្នុងការបោះឆ្នោត ប្រសិនបើអ្នកជាជនពិការ។ កន្លែងបោះឆ្នោតត្រូវតែអាចចេញចូលបាន ហើយត្រូវតែមានបន្ទប់គូសសន្លឹកឆ្នោតដែលអាចចេញចូលបាន។

7. អ្នកមានសិទ្ធិក្នុងការបោះឆ្នោត ប្រសិនបើអ្នកមិនអាចអាន ឬសរសេរ ឬមិនអាចអានឬសរសេរភាសាអង់គ្លេសបាន។

8. អ្នកមានសិទ្ធិក្នុងការបោះឆ្នោត ប៉ុន្តែត្រូវបង្ហាញឯកសារអត្តសញ្ញាណ ប្រសិនបើ៖ អ្នកជាអ្នកបោះឆ្នោតលើកដំបូងដែលបានចុះឈ្មោះបោះឆ្នោតតាមសំបុត្រ និងពុំបានប្រគល់ឯកសារអត្តសញ្ញាណអមជាមួយទម្រង់បែបបទចុះឈ្មោះបោះឆ្នោត។ ឬឈ្មោះរបស់អ្នកមាននៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតអកម្ម។ ឬការបោះឆ្នោតរបស់អ្នកត្រូវបានតវ៉ា ឬប្រសិនបើបានស្នើសុំពីបុគ្គលិករៀបចំការបោះឆ្នោត។ ទម្រង់នៃឯកសារអត្តសញ្ញាណដែលអាចទទួលយកបាន មានដូចជា៖ ប័ណ្ណបើកបររដ្ឋម៉ាសាជូសេត ឯកសារបោះពុម្ពដទៃទៀត ដែលមានឈ្មោះនិងអាសយដ្ឋានរបស់អ្នក ដូចជា បង្កាន់ដៃទឹកភ្លើង បង្កាន់ដៃជួលនៅលើក្បាលលិខិតរបស់ម្ចាស់ផ្ទះ កិច្ចសន្យាជួល ឬសំណៅថតចម្លងនៃការទទួលស្គាល់ការចុះឈ្មោះបោះឆ្នោត ឬបង្កាន់ដៃ។

9. អ្នកមានសិទ្ធិក្នុងការបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោត ប្រសិនបើ៖ អ្នកនឹងត្រូវអវត្តមានពីទីក្រុង ឬសង្កាត់របស់អ្នកនៅថ្ងៃបោះឆ្នោត ឬប្រសិនបើអ្នកមានពិការភាពរាងកាយដែលរារាំងមិនឱ្យអ្នកទៅបោះឆ្នោតនៅកន្លែងបោះឆ្នោតបាន ឬប្រសិនបើអ្នកមិនអាចបោះឆ្នោតបានដោយសារជំនឿសាសនា។

10. អ្នកមានសិទ្ធិក្នុងការបោះឆ្នោតលើសន្លឹកឆ្នោតបណ្តោះអាសន្ន ប្រសិនបើអ្នកជឿថា អ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែបុគ្គលិករៀបចំការបោះឆ្នោតប្រាប់អ្នកអាច អ្នកពុំមានសិទ្ធិក្នុងការបោះឆ្នោត។

11. អ្នកមានសិទ្ធិក្នុងការតាមដានការតវ៉ាណាមួយចំពោះសិទ្ធិរបស់អ្នកក្នុងការបោះឆ្នោត តាមរយៈដំណើរការបណ្តឹង។

12. អ្នកមានសិទ្ធិក្នុងការបោះឆ្នោត ប្រសិនបើបច្ចុប្បន្ននេះ អ្នកមិនត្រូវបានឃុំខ្លួនពីបទព្រហ្មទណ្ឌ និងបានចុះឈ្មោះបោះឆ្នោត ក្រោយពីគេដោះលែងអ្នកវិញ។

13. អ្នកមានសិទ្ធិក្នុងការយកកម្រងសិទ្ធិអ្នកបោះឆ្នោត ឬអត្ថបទណាមួយផ្សេងទៀតទៅជាមួយបាន រួមទាំងសន្លឹកឆ្នោតគំរូ សៀវភៅណែនាំសម្រាប់អ្នកបោះឆ្នោត ឬសម្ភារៈឃោសនាដទៃទៀត ចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតជាមួយអ្នកបាន។ សូមកុំភ្លេចយកក្រដាសទាំងអស់នោះមកវិញ នៅពេលអ្នកចាកចេញពីបន្ទប់គូសសន្លឹកឆ្នោត។

14. អ្នកមានសិទ្ធិក្នុងការបោះឆ្នោតនៅកន្លែងបោះឆ្នោតរបស់អ្នកគ្រប់ពេលវេលាចន្លោះពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់ សម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋនិងថ្នាក់សហព័ន្ធ។ ម៉ោងអាចខុសគ្នាទៅតាមការបោះឆ្នោតក្នុងមូលដ្ឋាន។ ប្រសិនបើអ្នកឈរតម្រង់ជួរនៅកន្លែងបោះឆ្នោតរបស់អ្នកនៅពេលដែលការបោះឆ្នោតត្រូវបានបិទនៅម៉ោង 8 យប់ អ្នកមានសិទ្ធិក្នុងការបោះឆ្នោត។

15. អ្នកមានសិទ្ធិក្នុងការនាំកូនចៅរបស់អ្នកចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតជាមួយអ្នក។

ប្រសិនបើអ្នកមានអារម្មណ៍ថា សិទ្ធិក្នុងការបោះឆ្នោតរបស់អ្នកត្រូវបានបំពានដោយវិធីណាមួយ សូមទូរស័ព្ទទៅលេខាធិការអង្គភាពបោះឆ្នោតរបស់ខំមិនវែលតាមរយៈលេខ 1-800-462-VOTE (8683)។ ការហៅទូរស័ព្ទនេះ គឺពុំគិតថ្លៃនោះទេ នៅក្នុងរដ្ឋម៉ាសាជូសេត។

# តើអ្នកធ្លាប់ជាជនរងគ្រោះនៃការឆបោកក្នុងការវិនិយោគដែរឬទេ?

ការិយាល័យលេខាធិការខំមិនវែល គ្រប់គ្រងនិងអនុវត្តច្បាប់នានាដែលពាក់ព័ន្ធនឹងការវិនិយោគគ្រប់ប្រភេទ ដែលផ្តល់ជូន ឬលក់នៅក្នុងរដ្ឋម៉ាសាជូសេត។

ការិយាល័យលេខាធិកា បានទទួលជោគជ័យក្នុងការប្រគល់ប្រាក់រាប់លានដុល្លារដោយផ្ទាល់ត្រឡប់ទៅឱ្យវិនិយោគិនដែលរងការបោកប្រាស និងបានការពារផ្សារមូលបត្រ។

សូមពិនិត្យមើលថាតើស្ថានភាពទាំងនេះ ស្រដៀងគ្នានឹងស្ថានភាពរបស់អ្នកដែរឬទេ៖

- ពលរដ្ឋម៉ាសាជូសេតវ័យចំណាស់ដែលត្រូវមេធាវីក្នុងស្រុកជួលឱ្យជួយផ្តល់សេវាផ្លូវច្បាប់សម្រាប់ប្តី/ប្រពន្ធពលរដ្ឋដែលមានជំងឺ។ មេធាវីបានបញ្ឆោះបញ្ចូលឱ្យពលរដ្ឋផ្ទេរប្រាក់រាប់សែនដុល្លារក្នុងគោលបំណងដើម្បីទិញធនលាភ។ ពលរដ្ឋបានទាក់ទងការិយាល័យលេខាធិការ នៅពេលដែលគាត់ដឹងថា តាមពិតមេធាវីមិនដែលបានទិញធនលាភនោះសោះ។ អង្គភាពមូលបត្រ បានតាមរកមេធាវីដែលបង្កើតការនិយាយដែលនាំឱ្យការយល់ខុសនោះដោយជោគជ័យ ដោយបានទារប្រាក់ទាំងអស់សម្រាប់ជនរងគ្រោះវិញ ហើយបានហាមឃាត់មេធាវីនោះមិនឱ្យពាក់ព័ន្ធនឹងឧស្សាហកម្មមូលបត្រជាអចិន្ត្រៃយ៍។

- ការិយាល័យលេខាធិការ មានភាពជោគជ័យក្នុងការទារប្រាក់រាប់ពាន់ដុល្លារសម្រាប់ពលរដ្ឋ នៅពេលស្ថានភាពហិរញ្ញវត្ថុធំមួយបាត់បង់កំណត់ត្រា ឬបានអះអាងថាបុគ្គលនោះស្លាប់ (នៅពេលដែលការពិតមនុស្សនោះនៅរស់សោះ) ពាក់ព័ន្ធនឹងការខកខានមិនទទួលបានអត្ថប្រយោជន៍ធនលាភ។

- ឈ្មួញកណ្តាលខិលខូចពីរនាក់ពីខាងឈ្មួញកណ្តាល-អ្នកជំនួញបានពាក់ព័ន្ធនឹងការជួញដូរយ៉ាងច្រើននៅក្នុងគណនីរបស់មនុស្សចាស់ ដើម្បីបង្កើតប្រាក់កម្រៃជើងសារយ៉ាងច្រើនសម្រាប់ខ្លួនគេ។ ទីភ្នាក់ងារលាក់បាំងចំនួនទឹកប្រាក់ដែលគិតទៅលើអតិថិជនដើម្បីឱ្យអតិថិជនពុំដឹងខ្លួនពីការបូមយកប្រាក់កម្រៃជើងសារ។ អតិថិជនទាក់ទងការិយាល័យលេខាធិការ ហើយអាចទាមទារថ្លៃសេវាច្រើនលើសលប់ដែលបានគិតយកពីគណនីរបស់ខ្លួន ហើយក្រុមហ៊ុនឈ្មួញកណ្តាល ត្រូវបានហាមឃាត់មិនឱ្យធ្វើអាជីវកម្មក្នុងរដ្ឋម៉ាសាជូសេតជាអចិន្ត្រៃយ៍។

- ឈ្មួញកណ្តាល-អ្នកជំនួញ មិនបានធានាពីនិរន្តរភាព និងការព្យួរអាជីពការងារហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសកម្មរបស់និវត្តជន រួមបញ្ចូលទាំង REIT ដែលមិនអាចជួញដូរបានផងដែរ។ អង្គភាពមូលបត្រអាចធានានូវសំណងដល់ពលរដ្ឋម៉ាសាជូសេតដែលបានរងផលប៉ះពាល់។

- ក្រុមហ៊ុនអចលនទ្រព្យនោះត្រូវបានរារាំងមិនឱ្យផ្តល់ការវិនិយោគអចលនទ្រព្យក្លែងក្លាយជូនដល់ពលរដ្ឋម៉ាសាជូសេតឡើយ។ ការិយាល័យលេខាធិការ អាចធ្វើការបញ្ជាឱ្យក្រុមហ៊ុនផ្តល់សំណងទៅកាន់វិនិយោគិនទាំងអស់របស់រដ្ឋម៉ាសាជូសេតវិញ បង់ប្រាក់ពិន័យរដ្ឋបាល ហើយបញ្ឈប់ការលក់ទាំងអស់នៅក្នុងរដ្ឋម៉ាសាជូសេត។

- ឈ្មួញកណ្តាលប្រើយុទ្ធនាការឃោសនាបំភាន់តាមវិទ្យុដើម្បីល្បួងរកអ្នកវិនិយោគ។ អង្គភាពមូលបត្រអាចចាត់វិធានការដើម្បីបិទការឃោសនានោះ និងបានហាមឃាត់អ្នកជំនាញហិរញ្ញវត្ថុមិនឱ្យប្រើប្រាស់វាទៀត។

- បុគ្គលម្នាក់បានតាមប្រម៉ាញ់សាច់ញាតិចាស់ៗដើម្បីទទួលបានការគ្រប់គ្រងទាំងស្រុងលើគណនីឈ្មួញកណ្តាលរបស់ពួកគាត់ និងលួចប្រាក់របស់ពួកគាត់ដើម្បីប្រើប្រាស់សម្រាប់ការចាយវាយផ្ទាល់ខ្លួន។ ពួកគាត់បានជូនដំណឹងដល់ការិយាល័យលេខាធិការ នៅពេលដែលគាត់បានសារភាពទង្វើរបស់គាត់ ហើយការិយាល័យក៏អាចឱ្យក្រុមហ៊ុនឈ្មួញកណ្តាលសងសំណងប្រាក់ដែលបានលួចនោះវិញដែរ។

- ប្តីប្រពន្ធចូលនិវត្តន៍បានជួលអ្នកប្រឹក្សាយោបល់ខាងវិនិយោគដើម្បីជួយពួកគាត់ក្នុងរឿងហិរញ្ញវត្ថុ។ បុគ្គលនោះបានដាក់គាត់ចូលក្នុងផលិតផលមួយដែលគាត់ទទួលបានប្រាក់កម្រៃជើងសារយ៉ាងច្រើន ប៉ុន្តែផលិតផលនោះមិនបំពេញតាមតម្រូវការពួកគាត់ទេ ហើយប្តីប្រពន្ធនោះ ជាប់ថ្លៃសេវាយ៉ាងច្រើន។ ការិយាល័យអាចជួយពួកគាត់ឱ្យចាកចេញពីផលិតផលនោះ និងទទួលបានសំណងថ្លៃសេវាត្រឡប់មកវិញ។

ប្រសិនបើអ្នកត្រូវការជំនួយ អ្នកអាចទាក់ទងការិយាល័យលេខាធិការបានខ្សែទូរសព្ទឥតគិតថ្លៃ **1-800-269-5428**។

## សេវាកម្មនានារបស់លេខាធិការខំមិនវែល

សេវាព័ត៌មានពលរដ្ឋ ដើរតួជាព័ត៌មានសំខាន់និងជាទីភ្នាក់ងារបញ្ជូនបន្តសម្រាប់រដ្ឋ ដោយផ្តល់ព័ត៌មានស្តីពីកម្មវិធីរបស់រដ្ឋ និងទីភ្នាក់ងាររបស់រដ្ឋ។ CIS ប៉ុនប៉ងក្នុងការឆ្លើយតបនឹងសំណើនានាដោយផ្តល់នូវជំនួយដោយផ្ទាល់ ឬការបញ្ជូនបន្តភ្លាមៗទៅកាន់ទីភ្នាក់ដែលសមស្រប។ ក្នុងនាមជាផ្នែកមួយនៃគោលដៅរបស់ខ្លួនក្នុងការធ្វើឱ្យរដ្ឋាភិបាលកាន់ដែលងាយទាក់ទងបានពីខាងសាធារណជន CIS បានបង្កើតស៊េរីឯកសារបោះពុម្ពផ្សាយនៅលើប្រធានបទជាក់លាក់ដែលមានការចាប់អារម្មណ៍ រួមមាន៖

- សៀវភៅណែនាំអំពីសេវាកម្មរបស់រដ្ឋសម្រាប់ពលរដ្ឋ៖ បញ្ជីសម្រិតសម្រាំងនៃទីភ្នាក់ងារ និងកម្មវិធីរបស់រដ្ឋាភិបាល ដែលមានអាសយដ្ឋាន លេខទូរស័ព្ទ និងខ្លឹមសាររបស់ទីភ្នាក់ងារ។ តម្លៃ៖ $26 ($19 បូកថ្លៃដឹកជញ្ជូន $7)។ ឥតគិតថ្លៃតាមអនឡាញ នៅ **www.sec.state.ma.us/cis** អាចស្វែងរកបានតាមហាងលក់សៀវភៅរបស់រដ្ឋ។
- ស្វាគមន៍មកកាន់រដ្ឋម៉ាសាជូសេត៖ សៀវភៅណែនាំជាក់ស្តែងអំពីការរស់នៅក្នុងរដ្ឋ - ឥតគិតថ្លៃ
- ពន្ធអាករលើយានយន្ត - ឥតគិតថ្លៃ
- លំនៅដ្ឋានស្អាតនិងមានសុវត្ថិភាពសម្រាប់ពលរដ្ឋម៉ាសាជូសេត - ឥតគិតថ្លៃ។
- សៀវភៅណែនាំអំពីច្បាប់អតីតយុទ្ធជន និងអត្ថប្រយោជន៍ - ឥតគិតថ្លៃ។
- ខិត្តប័ណ្ណព័ត៌មានរដ្ឋម៉ាសាជូសេត៖ ទិដ្ឋភាពទូទៅខាងប្រវត្តិសាស្ត្ររដ្ឋាភិបាល និងនិមិត្តរូបរបស់រដ្ឋ សម្រាប់សិស្សនៅអាយុរៀនអនុវិទ្យាល័យ និងវិទ្យាល័យ - ឥតគិតថ្លៃ។

លេខទូរស័ព្ទ៖ 617-727-7030 ឬ 1-800-392-6090 (ខ្សែទូរសព្ទឥតគិតថ្លៃក្នុង រដ្ឋម៉ាសាជូសេតតែប៉ុណ្ណោះ)
គេហទំព័រ៖ **www.sec.state.ma.us/cis**
អ៊ីម៉ែល៖ cis@sec.state.ma.us

អង្គភាពបោះឆ្នោត គ្រប់គ្រងរាល់ការបោះឆ្នោតរបស់រដ្ឋទាំងអស់ ផ្តល់ព័ត៌មានអំពីការបោះឆ្នោត និងផ្គត់ផ្គង់ឯកសារបោះឆ្នោតជូនដល់សាធារណជន បេក្ខជន និងមន្ត្រីរដ្ឋាភិបាល។

លេខទូរស័ព្ទ៖ 617-727-2828 ឬ 1-800-462-VOTE (8683)
គេហទំព័រ៖ **www.sec.state.ma.us/ele**
អ៊ីម៉ែល៖ elections@sec.state.ma.us

អង្គភាពមូលបត្រ បំពេញកិច្ចការដើម្បីការពារវិនិយោគិនក្នុងរដ្ឋម៉ាសាជូសេត តាមរយៈការចុះឈ្មោះឈ្មួញកណ្តាល-អ្នកជំនួញ និងអ្នកប្រឹក្សាយោបល់ការវិនិយោគ ដោយតម្រូវឱ្យមានការរាយការណ៍ពីបញ្ហាសន្តិសុខដែលមានហានិភ័យខ្ពស់ បណ្តឹងស៊ើបអង្កេត និងការអនុវត្តច្បាប់ដែលសមស្រប និងវិធានការវិន័យ។

លេខទូរស័ព្ទ៖ 617-727-3548 or 1-800-269-5428
គេហទំព័រ៖ **www.sec.state.ma.us/sct**
អ៊ីម៉ែល៖ securities@sec.state.ma.us

អង្គភាពកំណត់ត្រាសាធារណ: គ្រប់គ្រងច្បាប់កំណត់ត្រាសាធារណៈ ជួយដល់ទីភ្នាក់ងារ និងទីក្រុងក្នុងការគ្រប់គ្រងកំណត់ត្រា បញ្ជាក់ឯកសារសម្រាប់ប្រើប្រាស់នៅបរទេស ធ្វើការស្បថចូលកាន់តំណែង និងរក្សាកំណត់ត្រានៃការតែងតាំងតំណែងអភិបាល និងបេសកកម្ម។

លេខទូរស័ព្ទ៖ 617-727-2832
គេហទំព័រ៖ **www.sec.state.ma.us/pre**
អ៊ីម៉ែល៖ pre@sec.state.ma.us

កំណត់ត្រាអចលនទ្រព្យ។ ព័ត៌មានអំពីបណ្តឹងសុំផ្តាច់ទ្រព្យបញ្ចាំ និងផ្ទះកំណើត - រដ្ឋម៉ាសាជូសេតត្រូវបានបែងចែកជាមណ្ឌលចុះបញ្ជីចំនួន 21 ដែលមានអ្នកចុះបញ្ជីប័ណ្ណកម្មសិទ្ធិត្រូវបានបោះឆ្នោតជ្រើសតាំងឱ្យទទួលខុសត្រូវលើការិយាល័យនីមួយៗ។ ឯកសារពាក់ព័ន្ធនឹងម្ចាស់កម្មសិទ្ធិអចលនទ្រព្យនៅក្នុងសង្កាត់ ត្រូវបានកត់ត្រាទុកនៅក្នុងបញ្ជីប័ណ្ណកម្មសិទ្ធិ។

គេហទំព័រ៖ **www.masslandrecords.com**

បណ្ណាសាររដ្ឋម៉ាសាជូសេត ប្រមូលផ្តុំ ធ្វើកាតាឡុក និងរក្សាទុកកំណត់ត្រាដែលមានតម្លៃជិត 400 ឆ្នាំនៃរដ្ឋាភិបាលរដ្ឋ។ បណ្ណាសារនេះបានដើរតួជាធនធានសម្រាប់អ្នកសិក្សា ពង្សាវលីវិទូ និងសិស្សានុសិស្ស និងជាការប្រឹក្សាមួយសម្រាប់កំណត់ត្រាប្រវត្តិសាស្ត្រសហគមន៍ក្នុងរដ្ឋម៉ាសាជូសេត។

លេខទូរស័ព្ទ៖ 617-727-2816
គេហទំព័រ៖ **www.sec.state.ma.us/arc**
អ៊ីម៉ែល៖ archives@sec.state.ma.us

សារមន្ទីរខំមិនវែល បានធ្វើឱ្យប្រវត្តិសាស្ត្ររដ្ឋម៉ាសាជូសេតរស់ឡើងវិញ តាមរយៈការតាំងពិពរណ៌ ការផ្សព្វផ្សាយ និងកម្មវិធីសិស្ស និងឯកសារបោះពុម្ពផ្សាយ។

លេខទូរស័ព្ទ៖ 617-727-9268
គេហទំព័រ៖ **www.commonwealthmuseum.org**

គណៈកម្មាធិការប្រវត្តិសាស្ត្ររដ្ឋម៉ាសាជូសេត គឺជាទីភ្នាក់ងាររដ្ឋដែលទទួលខុសត្រូវសម្រាប់ការអភិរក្សប្រវត្តិសាស្ត្រក្នុងខំមិនវែលនេះ។ ទីភ្នាក់ងារបានផ្តល់ជំនួយដល់សហគមន៍ក្នុងការចុះបញ្ជីទ្រព្យសម្បត្តិជាមួយមន្ទីរចុះបញ្ជីទីតាំងប្រវត្តិសាស្ត្រជាតិ និងបង្កើតជាសង្កាត់ប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន។

លេខទូរស័ព្ទ៖ 617-727-8470
គេហទំព័រ៖ **www.sec.state.ma.us/mhc**
អ៊ីម៉ែល៖ mhc@sec.state.ma.us

ហាងសៀវភៅរបស់រដ្ឋ ផ្តល់ជូននូវសៀវភៅ និងខិត្តប័ណ្ណជាច្រើនប្រភេទដែលបានបោះពុម្ពផ្សាយដោយលេខាធិការខំមិនវែល និងទីភ្នាក់ងាររដ្ឋដទៃផ្សេងទៀត រួមមានក្រមបទបញ្ញត្តិរដ្ឋម៉ាសាជូសេតជាដើម។ កាតាឡុកហាងសៀវភៅឥតគិតថ្លៃ អាចស្វែងរកបាន។

លេខទូរស័ព្ទ៖ 617-727-2834
គេហទំព័រ៖ **www.sec.state.ma.us/spr**
អ៊ីម៉ែល៖ bookstore@sec.state.ma.us

ការិយាល័យក្នុងតំបន់ ក្នុង Springfield និង Fall River ផ្តល់ជូននូវសេវាកម្មជាច្រើនដែលផ្តល់ជូនដោយការិយាល័យ Boston និងធ្វើឱ្យរដ្ឋាភិបាលរដ្ឋកាន់តែជិតស្និទ្ធនឹងពលរដ្ឋម៉ាសាជូសេត។

Springfield: 413-784-1376
Fall River: 508-646-1374
គេហទំព័រ៖ **www.sec.state.ma.us/wso**

អង្គភាពសហប្រតិបត្តិការ ទទួលខុសត្រូវលើការចុះបញ្ជីស្ថាប័នអាជីវកម្មរកប្រាក់ចំណេញ និងស្ថាប័នអាជីវកម្មមិនរកប្រាក់ចំណេញ និងផ្តល់ព័ត៌មានសង្ខេបភ្លាមៗអំពីស្ថាប័នជាង 400,000 កន្លែងដែលកំពុងធ្វើអាជីវកម្មនៅក្នុងរដ្ឋនេះ។

លេខទូរស័ព្ទ៖ 617-727-2850
គេហទំព័រ៖ **www.sec.state.ma.us/cor**
អ៊ីម៉ែល៖ corpinfo@sec.state.ma.us

**អង្គភាពដទៃទៀត រួមមាន៖**

អ្នកបញ្ចុះបញ្ចូល៖
លេខទូរស័ព្ទ៖ 617-727-9122
គេហទំព័រ៖ **www.sec.state.ma.us/lob**
អ៊ីម៉ែល៖ lob@sec.state.ma.us

ឯកសារបោះពុម្ពផ្សាយរបស់រដ្ឋ និងបទបញ្ញត្តិ
ទូរស័ព្ទ៖ 617-727-2831
គេហទំព័រ៖ **www.sec.state.ma.us/spr**
អ៊ីម៉ែល៖ regs@sec.state.ma.us

ដំណើរទស្សនកិច្ចវិមានរដ្ឋ៖
លេខទូរស័ព្ទ៖ 617-727-3676
គេហទំព័រ៖ **www.sec.state.ma.us/trs**
អ៊ីម៉ែល៖ mastatehousetours@sec.state.ma.us

## ជំនួយសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

រដ្ឋម៉ាសាជូសេតព្យាយាមការពារជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ឬការឈ្លបចាប់ តាមរយៈការជួយពួកគេឱ្យបង្កើនអាសយដ្ឋានសម្ងាត់ថ្មី ដើម្បីការពារកុំឱ្យអ្នកប្រព្រឹត្តិអំពើហិង្សារកកន្លែងជនរងគ្រោះឃើញ។

កម្មវិធីនេះ (ហៅថា កម្មវិធីលាក់ការអាសយដ្ឋាន (ACP)) ត្រូវបានគ្រប់គ្រងដោយលេខាធិការខំមិនវែល។

ដើម្បីទទួលបានការបញ្ជាក់ថាជាអ្នកចូលរួមក្នុងកម្មវិធិ អ្នកដាក់ពាក្យសុំ ត្រូវបង្ហាញថា ការបញ្ចេញព័ត៌មានអាសយដ្ឋានរបស់ពួកគេ នឹងគំរាមកំហែងដល់សុវត្ថិភាពរបស់អ្នកដាក់ពាក្យសុំ ឬកូនចៅរបស់អ្នកដាក់ពាក្យសុំ។ ACP អនុញ្ញាតឱ្យអ្នកចូលរួមកម្មវិធីប្រើប្រាស់អាសយដ្ឋានប្រៃសណីយ៍ជំនួស នៅពេលទាក់ទងជាមួយទីភ្នាក់ងាររដ្ឋាភិបាល។ អាសយដ្ឋានជំនួសនេះ ត្រូវបានប្រើសម្រាប់ទីលំនៅស្របច្បាប់របស់អ្នកចូលរួមកម្មវិធី ក៏ដូចអាសយដ្ឋានកន្លែងធ្វើការ និង/ឬសាលារៀន។ ហេតុនេះ កំណត់ត្រារដ្ឋាភិបាលអាចត្រូវបានបញ្ចេញឱ្យដឹងជាសាធារណៈដោយពុំកំណត់ពីទីតាំងថ្មីរបស់ជនរងគ្រោះឡើយ។

គ្រួសារដែលមានប្រាក់ចំណូលទាប ដែលត្រូវការជំនួយផ្លាស់ប្តូរទីលំនៅដែលមានសិទ្ធិទទួលបាន ACP អាចមានសិទ្ធិដាក់ពាក្យស្នើសុំ ជំនួយលំនៅដ្ឋានសម្រាប់គ្រួសារក្នុងប្រាក់កម្មវិធីអន្តរកាល )RAFT(ជាកម្មវិធីមួយដែលគ្រប់គ្រងតាមរយៈនាយកដ្ឋាន លំនៅដ្ឋាន និង ការអភិវឌ្ឍសហគមន៍ ដែលអាចជួយដល់ថ្លៃចំណាយហិរញ្ញវត្ថុរយៈពេលខ្លះនៃការផ្លាស់ទីលំនៅ ដូចជាថ្លៃឈ្នួលផ្ទះក្នុងខែដំបូងនិងខែចុងក្រោយ និងប្រាក់កក់ធានាជាដើម។

**តើខ្ញុំរកកន្លែងអ្នកផ្តល់ជំនួយដាក់ពាក្យសុំដើម្បីចាប់ផ្តើមដំណើរការដាក់ពាក្យសុំដោយរបៀបណា?**

អ្នកអាចទូរស័ព្ទទៅ ACP តាមរយៈលេខ 1-866-SAFE-ADD ដើម្បីស្វែងរកទីតាំងរបស់អ្នកផ្តល់ជំនួយពាក្យស្នើសុំ។ អ្នកក៏អាចទាក់ទងទីភ្នាក់ងារ ឬកម្មវិធីមិនរកប្រាក់ចំណេញ ដែលផ្តល់ការប្រឹក្សាយោបល់ ការបញ្ជូនបន្ត ទីជម្រក ឬសេវាកម្មឯកទេសផ្សេងទៀត ជូនដល់ជនរងគ្រោះនៃការបំពារបំពានហិង្សា ការចាប់រំលោភ ការរំលោភបំពានផ្លូវភេទ ឬការឈ្លបចាប់។

# ✗ បញ្ជីត្រួតពិនិត្យអ្នកបោះឆ្នោត ហែកចេញ រួចយកតាមខ្លួនទៅកន្លែងបោះឆ្នោត។

សន្លឹកឆ្នោត ▶ សំណួរ

សំណួរទី 1 ☐ គាំទ្រ ☐ ជំទាស់

សំណួរទី 2 ☐ គាំទ្រ ☐ ជំទាស់

សំណួរទី 3 ☐ គាំទ្រ ☐ ជំទាស់

សន្លឹកឆ្នោត ▶ មុខតំណែង

មុខតំណែងដែលត្រូវបោះឆ្នោតក្នុងឆ្នាំ **2022** មានតាមលំដាប់លំដោយខាងក្រោម៖

អភិបាល និងអភិបាលរង ______________________________

អគ្គរដ្ឋអាជ្ញា______________________________

រដ្ឋលេខាធិការ ______________________________

ហេរញ្ញិក ______________________________

សវនករ______________________________

តំណាងនៅព្រឹទ្ធសភា______________________________

ក្រុមប្រឹក្សា ______________________________

សមាជិកព្រឹទ្ធនៅក្នុងសភាធម្មនុញ្ញ ______________________________

តំណាងនៅក្នុងសភាធម្មនុញ្ញ ______________________________

មេធាវីមណ្ឌល______________________________

អាជ្ញាសាលា ______________________________

ស្នងការខេនធី (ជ្រើសរើសខោនធី) ______________________________

ការចុះបញ្ជីប័ណ្ណកម្មសិទ្ធិ (សង្កាត់ Bristol ភាគខាងត្បូងប៉ុណ្ណោះ) ______________________________

**William Francis Galvin**
Secretary of the Commonwealth
One Ashburton Place, Room 1705
Boston, MA 02108

អង្គការមិនមែនរដ្ឋាភិបាល
ECRWSS
ប្រៃសណីយ៍សហរដ្ឋអាមេរិក
បានបង់ប្រាក់រួច
ម៉ាសាជូសេត
លេខាធិការ ខំមិនវែល

OFFICIAL ELECTION MAIL
*Authorized by the U.S. Postal Service* ®

ឯកសារផ្លូវការ

# អ្នកបោះឆ្នោតជា ពលរដ្ឋ
# ប្រើប្រាស់សេវាកម្ម

ព័ត៌មាន សម្រាប់អ្នកបោះឈ្នោត ត្រូវបានផ្ញើតាមសំបុត្រទៅកាន់អាសយដ្ឋានស្នាក់នៅ ទៅកាន់អ្នកបោះឆ្នោតដែលបានស្នាក់នៅកន្លែងស្នាក់នៅជាក្រុម និងទៅកាន់ទីសាធារណៈដែលមានភាពងាយស្រួលនៅទូទាំងខំមិនវែល។ អាចទទួលបានសំណៅថតចម្លងក្នុងចំនួនមានកំណត់ ហើយសាលាក្រុង និងសាលាសង្កាត់ក្នុងមូលដ្ឋាន និងបណ្ណាល័យខ្លះ ឬដោយទូរស័ព្ទទៅលេខាធិការអង្គភាពបោះឆ្នោតរបស់លោក Galvin តាមរយៈលេខ 617-727-2828 ឬ 1-800-462-VOTE (8683); សេវាព័ត៌មានសម្រាប់ពលរដ្ឋ តាមរយៈលេខ 617-727-7030 ឬ 1-800-392-6090។ អ្នកប្រើប្រាស់ TTY អាចទូរសព្ទទៅ MassRelay តាមរយៈលេខ 800-720-3480។ សូមកុំភ្លេចចូលមើលគេហទំព័ររបស់យើងនៅ **www.sec.state.ma.us**។ សំណៅឯកសារព័ត៌មានអ្នកបោះឆ្នោតជាភាសាអេស្ប៉ាញ ភាសាចិន និងភាសាខ្មែរ និងសំណៅឯកសារព្រីនជាអក្សរធំៗសម្រាប់អ្នកដែលមើលពុំសូវច្បាស់ ក៏អាចស្វែងរកបានផងដែរ តាមរយៈលេខទូរស័ព្ទដូចគ្នានេះ។ សំណៅឯកសារជាសំឡេងក៏អាចស្វែងរកបានផងដែរ រាប់ចាប់ពីអក្សរស្ទាប រហូតដល់បណ្ណាល័យសៀវភៅសំឡេងនៅក្នុងក្រុង Watertown តាមរយៈលេខ 1-800-852-3133។

♻ បោះពុម្ពនៅលើក្រដាសកែច្នៃឡើងវិញ